# ព្រះ

# ពុទ្ធដីកា និង អដ្ឋកថា

# សទ្ធម្មប្បដិរូប

## (ធម៌ស្រដៀងនឹងព្រះសទ្ធម្ម)

សមាគមគ្រួសារសតិប្បដ្ឋាន
SATIPATTHANA FAMILY ASSOCIATION

ពុទ្ធសករាជ ២៥៦២

# ព្រះ

# ពុទ្ធដីកា និង អដ្ឋកថា

*ព្រះសទ្ធម្ម*

*និង*

*សទ្ធម្មប្បដិរូប ( ធម៌ស្រដៀងនឹងព្រះសទ្ធម្ម )*

*ព្រះសទ្ធម្មដែលជាព្រះធម្មរតនៈ និងសទ្ធម្មប្បដិរូបដែលមិនមែនជា*
*ព្រះធម្មរតនៈ តើដូចម្តេច*

*បាត់ដំបង , ពុទ្ធសករាជ ២៥៦២*

*រៀបរៀងដោយ*

*ខ្ញុំបាទ អ៊ឹម រ៉ៃយ៉ា*

# សុគតសូត្រទី ១០

[ ១០ ] ម្នាលភិក្ខុទាំងឡាយ កាលព្រះសុគតក្តី វិន័យព្រះសុគតក្តី ប្រតិស្ឋាននៅក្នុងលោក ការនោះប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ។

ម្នាលភិក្ខុទាំងឡាយ ចុះព្រះសុគត ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតកើតឡើងក្នុងលោកនេះ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គបរិបូណ៌ដោយវិជ្ជា និងចរណៈ ព្រះអង្គមានដំណើរល្អ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ព្រះអង្គជាអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ព្រះអង្គជាសាស្តានៃទេវតា និងមនុស្សទាំងឡាយ ព្រះអង្គទ្រង់ត្រាស់ដឹងនូវចតុរារិយសច្ច ព្រះអង្គលែងវិលមកកាន់ភពថ្មីទៀត ។ ម្នាលភិក្ខុទាំងឡាយ នេះជាព្រះសុគត ។

ម្នាលភិក្ខុទាំងឡាយ ចុះវិន័យព្រះសុគត ដូចម្តេច ។ ព្រះសុគតនោះ ទ្រង់សំដែងធម៌ ពីរោះបទដើម ពីរោះបទកណ្តាល ពីរោះបទចុង ប្រកាសនូវព្រហ្មចរិយៈប្រកបដោយអត្ថ ប្រកបដោយព្យញ្ជនៈ ដ៏បរិបូណ៌ បរិសុទ្ធទាំងអស់ ។ ម្នាលភិក្ខុទាំងឡាយ នេះជាវិន័យព្រះសុគត ។

ម្នាលភិក្ខុទាំងឡាយ កាលព្រះសុគតក្តី វិន័យព្រះសុគតក្តី ប្រតិស្ឋាននៅក្នុង

លោកយ៉ាងនេះ កាលនោះប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ។

ម្នាលភិក្ខុទាំងឡាយ ធម៌ ៤ ប្រការនេះ ប្រព្រឹត្តទៅដើម្បីសេចក្តីវិនាសសាបសូន្យនៃព្រះសទ្ធម្ម ។ ធម៌ ៤ ប្រការ គឺ អ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយក្នុងសាសនានេះ រៀនព្រះសូត្រដែលខ្លួនរៀនខុស ដោយបទ និងព្យញ្ជនៈ ដែលរៀបរៀងខុសលំដាប់ ម្នាលភិក្ខុទាំងឡាយ បទ និងព្យញ្ជនៈ ដែលរៀបរៀងខុសលំដាប់ រមែងយល់សេចក្តីបានដោយលំបាក ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ១ ដែលប្រព្រឹត្តទៅ ដើម្បីសេចក្តីវិនាសសាបសូន្យនៃព្រះសទ្ធម្ម ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយជាមនុស្សដែលគេប្រដៅបានដោយក្រ ប្រកបដោយធម៌ដែលធ្វើឲ្យគេប្រដៅក្រ ជាអ្នកមិនចេះអត់ធន់ មិនទទួលពាក្យប្រៀនប្រដៅខាងស្តាំ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ២ ដែលប្រព្រឹត្តទៅ ដើម្បីសេចក្តីវិនាសសាបសូន្យនៃព្រះសទ្ធម្ម ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយណា ជាអ្នកមានសេចក្តីចេះដឹងច្រើន មានអាគម គឺនិកាយដ៏ស្ទាត់ ចងចាំនូវធម៌ ចងចាំនូវវិន័យ ចងចាំនូវមាតិកា ភិក្ខុទាំងនោះមិនញ៉ាំងបុគ្គលដទៃឲ្យរៀនព្រះសូត្រដោយគោរព លុះអំណើះទៅមុខ ព្រះសូត្ររបស់ភិក្ខុទាំងនោះក៏ដាច់មូល លែងប្រតិស្ឋានទៅ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៣ ដែលប្រព្រឹត្តទៅ ដើម្បីសេចក្តីវិនាសសាបសូន្យនៃ

ព្រះសទ្ធម្ម ។

ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុទាំងឡាយជាថេរៈ ជាអ្នកប្រតិបត្តិដើម្បីឲ្យកើតបច្ច័យច្រើន ប្រតិបត្តិបន្ធូរបន្ថយ ជាប្រធានក្នុងការប្រតិបត្តិបន្ធូរបន្ថយ ជាអ្នកដាក់ធុរៈក្នុងវិវេក មិនប្រារព្ធព្យាយាម ដើម្បីដល់នូវគុណវិសេសដែលខ្លួនមិនទាន់ដល់ ដើម្បីសម្រេចគុណវិសេស ដែលខ្លួនមិនទាន់បានសម្រេច ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់ធ្វើឲ្យជាក់ច្បាស់ ប្រជុំនៃជនដែលកើតខាងក្រោយ គឺ សទ្ធិវិហារិក និងអន្តេវាសិក ក៏យកតម្រាប់តាមភិក្ខុជាថេរៈទាំងនោះ ប្រជុំនៃជនទាំងនោះឯង ជាអ្នកប្រតិបត្តិដើម្បីឲ្យកើតបច្ច័យច្រើន ប្រតិបត្តិបន្ធូរបន្ថយ ជាប្រធានក្នុងការប្រតិបត្តិបន្ធូរបន្ថយ ជាអ្នកដាក់ធុរៈក្នុងវិវេក មិនប្រារព្ធព្យាយាម ដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់ដល់ ដើម្បីសម្រេចគុណវិសេស ដែលខ្លួនមិនទាន់បានសម្រេច ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់ធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៤ ដែលប្រព្រឹត្តទៅ ដើម្បីសេចក្តីវិនាសសាបសូន្យនៃព្រះសទ្ធម្ម ។

ម្នាលភិក្ខុទាំងឡាយ ធម៌ ៤ យ៉ាងនេះឯង ដែលប្រព្រឹត្តទៅ ដើម្បីសេចក្តីវិនាសសាបសូន្យនៃព្រះសទ្ធម្ម ។

ម្នាលភិក្ខុទាំងឡាយ ធម៌ ៤ នេះ ប្រព្រឹត្តទៅ ដើម្បីតាំងនៅនៃព្រះសទ្ធម្ម មិនឲ្យវិនាសសាបសូន្យទៅ ។ ធម៌ ៤ គឺ អ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយក្នុងសាសនានេះ រៀនព្រះសូត្រដែលខ្លួនរៀនត្រូវ ដោយបទនិងព្យញ្ជនៈ

ដែលរៀបរៀងត្រូវ ម្នាលភិក្ខុទាំងឡាយ បទ និងព្យញ្ជនៈ ដែលរៀបរៀងត្រូវ រមែងយល់សេចក្តីបានងាយ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ១ ដែលប្រព្រឹត្តទៅ ដើម្បីតាំងនៅនៃព្រះសទ្ធម្ម មិនឲ្យវិនាសសាបសូន្យទៅ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយជាអ្នកប្រដៅងាយ ប្រកបដោយធម៌ធ្វើឲ្យ ជាអ្នកប្រដៅងាយ ជាអ្នកចេះអត់ធន់ ទទួលនូវពាក្យប្រៀនប្រដៅខាងស្តាំ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ២ ដែលប្រព្រឹត្តទៅដើម្បីតាំងនៅនៃព្រះសទ្ធម្ម មិនឲ្យវិនាសសាបសូន្យទៅ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយណា ជាអ្នកមានសេចក្តីចេះដឹងច្រើន មានអាគម គឺ និកាយដ៏ស្ទាត់ ចងចាំនូវធម៌ ចងចាំនូវវិន័យ ចងចាំនូវមាតិកា ភិក្ខុទាំងនោះ ញុំាងបុគ្គលដទៃឲ្យរៀននូវព្រះសូត្រដោយគោរព លុះអំណើះទៅមុខ ព្រះសូត្ររបស់ភិក្ខុទាំងនោះ មិនបានដាច់ឫស តាំងនៅតៗ គ្នា ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៣ ដែលប្រព្រឹត្តទៅ ដើម្បីតាំងនៅនៃព្រះសទ្ធម្ម មិនឲ្យវិនាសសាបសូន្យទៅ ។

ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុទាំងឡាយជាថេរៈ មិនប្រតិបត្តិដើម្បីឲ្យកើតបច្ច័យច្រើន មិនប្រតិបត្តិបន្ធូរបន្ថយ មិនដាក់ធុរៈចុះក្នុងការប្រតិបត្តិបន្ធូរបន្ថយ ជាប្រធានក្នុងវិវេក ប្រារព្ធព្យាយាម ដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់ដល់ ដើម្បីសម្រេចគុណវិសេស ដែលខ្លួនមិនទាន់សម្រេច ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់ធ្វើឲ្យជាក់ច្បាស់ ប្រជុំជន

ដែលកើតខាងក្រោយ គឺសទ្ធិវិហារិក និងអន្តេវាសិក ក៏យកតម្រាប់តាមភិក្ខុទាំងនោះ ប្រជុំជនទាំងនោះឯង មិនជាអ្នកប្រតិបត្តិឲ្យកើតបច្ច័យច្រើន មិនប្រតិបត្តិបន្ធូរបន្ថយ មិនជាអ្នកដាក់ធុរៈចុះក្នុងការប្រតិបត្តិបន្ធូរបន្ថយ ជាប្រធានក្នុងវិវេក ប្រារព្ធព្យាយាម ដើម្បីដល់នូវគុណវិសេសដែលខ្លួនមិនទាន់បានដល់ ដើម្បីសម្រេចគុណវិសេស ដែលខ្លួនមិនទាន់បានសម្រេច ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេសដែលខ្លួនមិនទាន់ធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៤ ដែលប្រព្រឹត្ត ទៅដើម្បីតាំងនៅនៃព្រះសទ្ធម្ម មិនឲ្យវិនាសសាបសូន្យទៅ ។

ម្នាលភិក្ខុទាំងឡាយ ធម៌ ៤ យ៉ាងនេះឯង ដែលប្រព្រឹត្តទៅ ដើម្បីតាំងនៅនៃព្រះសទ្ធម្ម មិនឲ្យវិនាសសាបសូន្យទៅ ។

( បាលីប្រែ ៤៣-១៣ , បិដក-អដ្ឋកថា ២៨-៣១០ )

ឥន្ទ្រិយវគ្គទី ១ ចប់

# អដ្ឋកថា សុគតសូត្រ

[ ១០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសុគតសូត្រទី ១០ ដូចតទៅនេះ បទថា **ទុគ្គហិតំ** បានដល់ ប្រកាន់មកក្រៅលំដាប់ ។ បទថា **បរិយាបុណន្តិ** បានដល់ បន្ទោបង់ចេញមក គឺពោល ។ ក្នុងបទថា **បទព្យញ្ជនេហិ** នេះ លោកពោលថា បទរបស់អត្ថនោះឯងជាព្យញ្ជនៈ ដោយព្យញ្ជនៈ ។ បទថា **ទុន្និក្ខិត្តស្ស** បានដល់ ប្រើខុស គឺតាំងទុកក្រៅលំដាប់ ។ បទថា **អត្ថោបិ ទុន្នយោ ហោតិ** បានដល់ មិនអាចនាំអដ្ឋកថាចេញមកពោលបាន ។ បទថា **ឆិន្នមូលកោ** បានដល់ ឈ្មោះថា ឆិន្នមូលកៈ ព្រោះដាច់ភិក្ខុដែលជាមូល គឺដាច់ភិក្ខុដែលជាអាចារ្យ ។ បទថា **អប្បដិស្សរណោ** គឺមិនមានទីពឹង ។ បទថា **ពាហុលិកា** បានដល់ បដិបត្តិដើម្បីសន្សំបច្ច័យ ។ បទថា **សាថលិកា** បានដល់ កាន់យកនូវត្រៃសិក្ខាធូរថយ។ បទថា **ឱក្កមនេ បុព្វង្គមា** បានដល់ នីវរណៈ ៥ លោកហៅថា **ឱក្កមន** ព្រោះប្រព្រឹត្តទៅ រកទីទាប គឺ វិនាស អធិប្បាយថា បែរមុខទៅក្នុងឱក្កមនៈនោះ គឺ បែរមុខទៅកាន់ផ្លូវលាសិក្ខា ។ បទថា **បវិវេកេ** បានដល់ វិវេក ៣ ។ បទថា **និក្ខិត្តធុរា** បានដល់ មិនមានសេចក្ដីព្យាយាម ។ គប្បីជ្រាបអត្ថក្នុងទីទាំងពួង ក្នុងសូត្រនេះ ៕

អដ្ឋកថា សុគតសូត្រទី ១០

ឥន្ទ្រិយវគ្គទី ១ ចប់

# សីសបាសូត្រទី ១

( ព្រះពុទ្ធសម្តែងតែពាក្យណាប្រព្រឹត្តទៅដើម្បីត្រាស់ដឹងប៉ុណ្ណោះ )

[ ៤១៣ ] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងសីសបាវន ( ព្រៃធ្នង់ ) ទៀបក្រុងកោសម្ពី ។ គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ចាប់ស្លឹកធ្នង់បន្តិចដោយព្រះហស្ត ត្រាស់សួរភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកសម្គាល់សេចក្តីនុ៎ះដូចម្តេច ស្លឹកធ្នង់បន្តិចដែលតថាគតចាប់ដោយដៃក្តី ស្លឹកធ្នង់ដែលនៅឯដើមធ្នង់ក្តី ស្លឹកនោះតើស្លឹកណាច្រើនជាងហ្ន៎ ។ បពិត្រព្រះអង្គដ៏ចម្រើន ស្លឹកធ្នង់ដែលព្រះមានព្រះភាគចាប់ដោយព្រះហស្ត មានប្រមាណតិចណាស់ ឯស្លឹកធ្នង់ទាំងនោះ ដែលនៅដើមធ្នង់ មានចំនួនច្រើនជាង ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះមែនហើយ ពាក្យណា ដែលតថាគតមិនសម្តែងដើម្បីសេចក្តីត្រាស់ដឹងដល់អ្នកទាំងឡាយ ពាក្យនុ៎ះឯងមានចំនួនច្រើនជាង ។ ម្នាលភិក្ខុទាំងឡាយ ពាក្យនុ៎ះ បានជាតថាគតមិនសម្តែង ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា ពាក្យនុ៎ះ មិនប្រកបដោយប្រយោជន៍ មិនមែនជាអាទិព្រហ្មចរិយធម៌ មិនប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ មិនប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេក មិនប្រព្រឹត្តទៅដើម្បីរម្ងត់ទុក្ខ មិនប្រព្រឹត្តទៅដើម្បីស្ងប់រម្ងាប់ មិនប្រព្រឹត្តទៅដើម្បីដឹងច្បាស់ មិនប្រព្រឹត្តទៅដើម្បីត្រាស់ដឹង មិនប្រព្រឹត្តទៅដើម្បីនិព្វាន ។ ព្រោះហេតុនោះ បានជាតថាគត មិនសម្តែងពាក្យនោះឡើយ ។

[ ៤១៤ ] ម្នាលភិក្ខុទាំងឡាយ ចុះតថាគត សម្តែងពាក្យដូចម្តេចវិញ ។ ម្នាលភិក្ខុទាំងឡាយ តថាគតសម្តែងថា នេះជាទុក្ខ តថាគតសម្តែងថា នេះហេតុ

ជាទីកើតឡើងនៃទុក្ខ តថាគតសម្តែងថា នេះជាសេចក្តីរម្ងត់ទុក្ខ តថាគតសម្តែងថា នេះបដិបទាជាដំណើរទៅកាន់ទីរម្ងត់ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យនុ៎ះបានជាតថាគតសម្តែង តើព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា ពាក្យនុ៎ះប្រកបដោយប្រយោជន៍ ពាក្យនុ៎ះជាអាទិព្រហ្មចរិយធម៌ ពាក្យនុ៎ះ ប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីរម្ងត់ទុក្ខ ដើម្បីសេចក្តីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ។ ព្រោះហេតុនោះបានជាតថាគតសម្តែងពាក្យនុ៎ះ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរធ្វើសេចក្តីព្យាយាមថា នេះជាទុក្ខ នេះហេតុជាទីកើតឡើងនៃទុក្ខ នេះទីរលត់ទុក្ខ គួរធ្វើសេចក្តីព្យាយាមថា នេះបដិបទាជាដំណើរទៅកាន់ទីរម្ងត់ទុក្ខ។

## អដ្ឋកថា សីសបាសូត្រ

[ ៤១៣ ] គប្បីជ្រាបអធិប្បាយក្នុងសីសបាសូត្រទី ១ នៃសីសបាបណ្ណវគ្គទី ៤ ។ បទថា **យទិទំ ឧបរិ** គឺស្លឹកឆ្នង់បន្តិច ... ស្លឹកឆ្នង់ដែលនៅឯដើមឆ្នង់ ។ បទថា **សីសបាវនេ** បានដល់ លើដើមឆ្នង់ ។

( បិដក-៣៩ ទំព័រ ២៧៣ )

អដ្ឋកថា សីសបាសូត្រ ចប់

# សទ្ធម្មប្បដិរូបកសូត្រទី ១៣

[ ១៩៩ ] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅវត្តជេតពនរបស់ អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ព្រះមហាកស្សបមាន អាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំ ព្រះមាន ព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះមហាកស្សបមានអាយុ អង្គុយ ក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលសួរព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រ ព្រះអង្គដ៏ចម្រើន ចុះហេតុដូចម្តេច បច្ច័យដូចម្តេច បានជាក្នុងកាលពីដើម មាន សិក្ខាបទតិច តែមានភិក្ខុបានសម្រេចព្រះអរហត្តច្រើន បពិត្រព្រះអង្គដ៏ចម្រើន ហេតុដូចម្តេច បច្ច័យដូចម្តេច បានជាឥឡូវនេះ មានសិក្ខាបទច្រើន តែមានភិក្ខុ បានសម្រេចព្រះអរហត្តតិច ។

[ ២០០ ] ម្នាលកស្សប ហេតុនុ៎ះ តែងមានយ៉ាងនេះឯង កាលបើពួក សត្វសាបសូន្យទៅ ព្រះសទ្ធម្មក៏អន្តរធានទៅដែរ បានជាមានសិក្ខាបទច្រើន មានពួកភិក្ខុបានសម្រេចព្រះអរហត្តតិច ម្នាលកស្សប សទ្ធម្មប្បដិរូប គឺធម៌ដែល ស្រដៀងគ្នានឹងព្រះសទ្ធម្ម មិនបានកើតឡើងក្នុងលោកដរាបណា ការអន្តរធាន នៃព្រះសទ្ធម្ម ក៏មិនមានដរាបនោះ ម្នាលកស្សប សទ្ធម្មប្បដិរូប កើតឡើងក្នុង លោកកាលណា ការអន្តរធាននៃព្រះសទ្ធម្ម ក៏មានកាលនោះ ។ ម្នាលកស្សប ជាតរូបប្បដិរូប គឺរបស់ដែលស្រដៀងនឹងមាស មិនទាន់កើតឡើងក្នុងលោកដរាប ណា ការអន្តរធាននៃមាស ក៏មិនមានដរាបនោះ ម្នាលកស្សប ជាតរូបប្បដិរូប គឺរបស់ដែលស្រដៀងនឹងមាស កើតឡើងក្នុងលោក កាលណា ការអន្តរធាននៃ មាស ក៏មានក្នុងកាលនោះ យ៉ាងណាមិញ ។ ម្នាលកស្សប សទ្ធម្មប្បដិរូបមិនកើត

ឡើងក្នុងលោកដរាបណា ការអន្តរធាននៃព្រះសទ្ធម្ម ក៏មិនមានដរាបនោះ ម្នាលកស្សប សទ្ធម្មប្បដិរូបកើតឡើងក្នុងលោកកាលណា ការអន្តរធាននៃព្រះសទ្ធម្ម ក៏មានក្នុងកាលនោះ យ៉ាងនោះឯង ។

[ ២០១ ] ម្នាលកស្សប បឋវីធាតុ ធ្វើព្រះសទ្ធម្មឲ្យអន្តរធានទៅក៏ទេ អាបោធាតុ ធ្វើព្រះសទ្ធម្មឲ្យអន្តរធានទៅក៏ទេ តេជោធាតុធ្វើព្រះសទ្ធម្មឲ្យអន្តរធានទៅក៏ទេ វាយោធាតុ ធ្វើព្រះសទ្ធម្មឲ្យអន្តរធានទៅក៏ទេ មានតែពួកមោឃបុរសដែលកើតឡើងក្នុងលោកនេះ ទើបធ្វើព្រះសទ្ធម្មនេះឲ្យអន្តរធានទៅបាន ម្នាលកស្សប ដូចទូកលិចចុះដោយការផ្ទុករបស់ យ៉ាងណា ។ ម្នាលកស្សប ការអន្តរធាននៃព្រះសទ្ធម្ម មិនមែនយ៉ាងនោះទេ ។

[ ២០២ ] ម្នាលកស្សប ធម៌ ៥ ប្រការនេះថយចុះ តែងប្រព្រឹត្តទៅ ដើម្បីវិនាស ដើម្បីសាបសូន្យនៃព្រះសទ្ធម្ម ។ ធម៌ ៥ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលកស្សប ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ក្នុងសាសនានេះ ជាអ្នកមិនគោរព មិនកោតក្រែងចំពោះព្រះសាស្តា ១ ជាអ្នកមិនគោរព មិនកោតក្រែងចំពោះព្រះធម៌ ១ ជាអ្នកមិនគោរព មិនកោតក្រែង ចំពោះព្រះសង្ឃ ១ ជាអ្នកមិនគោរព មិនកោតក្រែង ចំពោះសិក្ខា ១ ជាអ្នកមិនគោរព មិនកោតក្រែងចំពោះសមាធិ ១ ។ ម្នាលកស្សប ធម៌ទាំង ៥ ប្រការនេះឯង ថយចុះ តែងប្រព្រឹត្តទៅដើម្បីវិនាស ដើម្បីសាបសូន្យនៃព្រះសទ្ធម្ម ។

[ ២០៣ ] ម្នាលកស្សប ធម៌ទាំង ៥ ប្រការនេះ តែងប្រព្រឹត្តទៅដើម្បីតាំងនៅ ដើម្បីមិនវិនាស មិនសាបសូន្យនៃព្រះសទ្ធម្ម ។ ធម៌ទាំង ៥ ប្រការ តើ

*ដូចម្តេចខ្លះ ។ ម្នាលកស្សប ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ក្នុងសាសនានេះ ជាអ្នកគោរព កោតក្រែង ចំពោះព្រះសាស្តា ១ ជាអ្នកគោរព កោតក្រែង ចំពោះព្រះធម៌ ១ ជាអ្នកគោរព កោតក្រែង ចំពោះព្រះសង្ឃ ១ ជាអ្នកគោរព កោតក្រែង ចំពោះសិក្ខា ១ ជាអ្នកគោរព កោតក្រែង ចំពោះសមាធិ ១ ។ ម្នាលកស្សប ធម៌ទាំង ៥ ប្រការនេះឯង តែងប្រព្រឹត្តទៅ ដើម្បីតាំងនៅ ដើម្បីមិនវិនាស មិនសាបសូន្យនៃព្រះសទ្ធម្ម ។*

*សូត្រទី ១៣ ចប់*

*( បាលីប្រែ ៣២-១៧៧ , បិដក-អ ២១-២៩៣ )*

## អដ្ឋកថាសទ្ធម្មប្បដិរូបកសូត្រ

[ ១៩៩-២០០ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងសទ្ធម្មប្បដិរូបកសូត្រទី ១៣ ដូចតទៅនេះ ។ បទថា* **អញ្ញាយ សណ្ឋហឹសុ** *ភិក្ខុតាំងនៅក្នុងអរហត្តផល ។ បទថា* **សទ្ធម្មប្បដិរូបកំ** *បានដល់ សទ្ធម្មប្បដិរូប ២ គឺសទ្ធម្មប្បដិរូប គឺអធិគម ១ សទ្ធម្មប្បដិរូប គឺបរិយត្តិ ១ ក្នុងសទ្ធម្មប្បដិរូបកនោះ*

*ចិត្តរមែងញាប់ញ័រ ដោយហេតុទាំងឡាយណា ហេតុទាំងនេះមាន ១០ គឺចិត្តញាប់ញ័រព្រោះពន្លឺ ១ ញាណ ១ បីតិ ១ បស្សទ្ធិ ១ សុខ ១ ញាប់ញ័រព្រោះអធិមោក្ខ ១ បគ្គាហៈ ១ ឧបដ្ឋានៈ១ ការពិចារណាដោយឧបេក្ខាក្នុងឧបេក្ខា១ និកន្តិ១ ។*

ភិក្ខុណាសន្ទរំបញ្ហាហើយ ភិក្ខុនោះ ឈ្មោះថា ជាអ្នកធ្លៀវធ្លាស ក្នុងឧទ្ធច្ចៈ ក្នុងធម៌ រមែងមិនដល់នូវសេចក្ដីវង្វេង ដូច្នេះ ។ នេះឈ្មោះថា អធិគម គឺសទ្ធម្មប្បដិរូបក ដែលជាឧបក្កិលេស នៃវិបស្សនាញាណ ។

រីឯ ពាក្យមិនមែនពុទ្ធវចនៈ មានគុឡ្ហវិន័យ គុឡ្ហវេស្សន្តរ គុឡ្ហមហោសថ វណ្ណបិដក អង្គុលិមាលបិដក រដ្ឋបាលគជ្ជិត ការប្រកាសរបស់ពួកអាឡវកគជ្ជិត វេទល្លបិដកជាដើម ក្រៅអំពីកថាវត្ថុទាំង ៤ នេះ គឺ ធាតុកថា អារម្មណកថា អសុភកថា ញាណវត្ថុកថា វិជ្ជាករណ្ឌក ដែលមិនទាន់លើកឡើងកាន់សង្គាយនាទាំង ៣ លើក ឈ្មោះថា សទ្ធម្មប្បដិរូប គឺ បរិយត្តិ ។ បទថា **ជាតរូបប្បដិរូបកំ** សេចក្ដីថា មាសធ្វើដោយទង់ដែង ដែលជាងមាសច្នៃចេញជាគ្រឿងប្រដាប់ក្នុងវេលាមានមហោស្រព មនុស្សទាំងឡាយទៅផ្សារដោយគិតថា អញនឹងទទួលគ្រឿងអាភរណៈ ដូច្នេះ ។ កាលនោះ ពាណិជ្ជករនិយាយនឹងបុគ្គលទាំងនោះ យ៉ាងនេះថា បើអ្នកត្រូវការអាភរណៈ អញ្ជើញទទួលយកអាភរណៈទាំងនេះ ។ អាភរណៈទាំងនេះក្រាស់ ពណ៌ល្អ តម្លៃក៏ថោក ជនទាំងនោះគប្បីស្ដាប់ពាណិជករនោះ ទទួលយកអាភរណៈនោះទៅ ដោយគិតថា ពាណិជករទាំងនេះប្រាប់ហេតុថា អ្នកប្រើអាភរណៈទាំងនេះ លេងនក្ខត្តឫក្សបានស្អាតក៏ស្អាត តម្លៃក៏ថោក ដូច្នេះ ។ មាសធម្មជាតិ គេមិនលក់ កប់រក្សាទុក កាលមាសក្លែងក្លាយកើតឡើង មាសធម្មជាតិនោះ ឈ្មោះថា បាត់ទៅយ៉ាងនេះ ។

បទថា **អថ សទ្ធម្មស្ស អន្តរធានំ ហោតិ** បានដល់ សទ្ធម្មទាំង ៣ គឺ

អធិគមសទ្ធម្ម ១ បដិបត្តិសទ្ធម្ម ១ បរិយត្តិសទ្ធម្ម ១ រមែងអន្តរធាន ។ ក្នុងបឋមពោធិកាល ពួកភិក្ខុបានជាអ្នកដល់បដិសម្ភិទា ។ ក្នុងកាលកន្លងទៅ ដល់នូវបដិសម្ភិទាមិនបាន តែក៏បានអភិញ្ញា ៦ បន្ទាប់មក កាលដល់អភិញ្ញា ៦ មិនបាន ក៏ដល់វិជ្ជា ៣ ។ លុះកន្លងមកដល់ឥឡូវនេះ កាលដល់វិជ្ជា ៣ មិនបាន ដល់ត្រឹមតែការអស់ទៅនៃអាសវៈ កាលដល់នូវការអស់អាសវៈ មិនបាន ក៏នឹងសម្រេចអនាគាមិផល កាលសម្រេចអនាគាមិផលនោះមិនបាន ក៏នឹងសម្រេចសកទាគាមិផល កាលសម្រេចសកទាគាមិផលនោះមិនបាន ក៏សម្រេចត្រឹមតែសោតាបត្តិផល ។ ក្នុងកាលកន្លងទៅ នឹងសម្រេចសោតាបត្តិផលក៏មិនបាន ។ កាលនោះ ក្នុងកាលណា វិបស្សនាផ្តើមសៅហ្មង ដោយឧបក្កិលេសទាំងនេះ ក្នុងកាលនោះ អធិគមរបស់ពួកភិក្ខុទាំងនោះ ក៏ឈ្មោះថា អន្តរធានទៅ ។

គ្រាបឋមពោធិកាល ពួកភិក្ខុញុំាំងបដិបទាដែលសមគួរដល់បដិសម្ភិទា ៤ ឲ្យបរិបូណ៌ កាលកន្លងទៅ មិនអាចបដិបត្តិសេចក្តីនោះបាន ក៏បដិបត្តិសមគួរដល់អភិញ្ញា ៦ ឲ្យបរិបូណ៌ កាលបដិបត្តិសេចក្តីនោះមិនបាន ក៏បដិបត្តិដ៏សមគួរដល់វិជ្ជា ៣ បានបរិបូណ៌ កាលបដិបត្តិវិជ្ជា ៣ មិនបាន ក៏បដិបត្តិសមគួរដល់អរហត្តផលបានបរិបូណ៌ ក្នុងកាលកន្លងទៅ កាលបដិបត្តិសមគួរដល់អរហត្តផលមិនបានបរិបូណ៌ ក៏បដិបត្តិសមគួរដល់អនាគាមិផលបានបរិបូណ៌ កាលបដិបត្តិអនាគាមិផលមិនបាន ក៏បដិបត្តិសមគួរដល់សកទាគាមិផលបានបរិបូណ៌ កាលបដិបត្តិសកទាគាមិផលនោះមិនបាន ក៏បដិបត្តិសមគួរដល់សោតាបត្តិផលបានបរិបូណ៌ ។ ឯក្នុងកាលណា កាលបដិបត្តិសមគួរដល់សោតាបត្តិផលមិនបាន

បរិបូណ៌ ក៏តាំងនៅត្រឹមសីលវិសុទ្ធិ ។ ក្នុងកាលនោះ បដិបត្តិសទ្ធម្ម ឈ្មោះថា អន្តរធានបាត់ទៅ ។

នឹងពោលថា សាសនាមិនអន្តរធានអស់កាលដែលព្រះត្រៃបិដក ពុទ្ធវចនៈ នៅប្រព្រឹត្តទៅ ដូច្នេះក៏គួរ ។ ម្យ៉ាងទៀត បិដក ៣ តាំងនៅ កាលអភិធម្មបិដក អន្តរធានទៅ បិដក ២ ក្រៅអំពីនេះ នៅប្រព្រឹត្តទៅនៅឡើយ មិនគួរពោលថា សាសនាអន្តរធានហើយដូច្នេះឡើយ ។ កាលបិដក ២ អន្តរធានទៅ ក៏ស្ថិតនៅ ត្រឹមតែព្រះវិនយបិដក ក្នុងវិនយបិដកនោះ បើខន្ធកៈ បរិវារវិនាសទៅ ក៏តាំងនៅ ត្រឹមតែឧភតោវិភង្គ កាលមហាវិភង្គវិនាសទៅ បាតិមោក្ខទាំង ២ នៅប្រព្រឹត្តទៅ សាសនាមិនទាន់ឈ្មោះថា អន្តរធានឡើយ តែកាលណាបាតិមោក្ខទាំង ២ វិនាស ទៅ កាលនោះ បរិយត្តិសទ្ធម្ម នឹងអន្តរធាន ។ កាលបរិយត្តិសទ្ធម្មនោះវិនាសទៅ សាសនាឈ្មោះថា អន្តរធានហើយ ព្រោះថា កាលបរិយត្តិវិនាសទៅ បដិបទា ក៏វិនាសទៅ កាលបដិបទាវិនាសទៅ អធិគមក៏វិនាសបាត់បង់ទៅ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា បរិយត្តិនេះ ជាបច្ច័យដល់បដិបទា បដិបទាជាបច្ច័យ ដល់អធិគម ។ តែកាល ពោលដោយបដិបទា កំណត់បរិយត្តិប៉ុណ្ណោះ ដោយ ប្រការដូច្នេះ ។

សួរថា ក្នុងសម័យព្រះកស្សបសម្មាសម្ពុទ្ធ អនាចារភិក្ខុ ឈ្មោះ កបិល ចាប់ផ្ចិតអង្គុយលើអាសនៈ ដោយគិតថា អញនឹងសូធ្យបាតិមោក្ខ ដូច្នេះ ទើប សួរថា ក្នុងទីនេះ អ្នកដែលសូធ្យបាតិមោក្ខបានមានឬ ។ គ្រានោះ ភិក្ខុពួកណា សូធ្យបាតិមោក្ខបានក៏ពិត តែទោះជាដូច្នោះ ភិក្ខុទាំងនោះក៏មិនពោលថា ពួកខ្ញុំសូធ្យ

បាន តែពោលថា ពួកខ្ញុំសួចរមិនបាន ដូច្នេះ ។ ព្រោះខាចភិក្ខុនោះ លោកដាក់ផ្ចិត ក្រោកចាកអាសនៈទៅហើយ ។ សួរថា ក្នុងកាលនោះ សាសនារបស់ព្រះ សម្មាសម្ពុទ្ធវិនាសហើយមិនមែនឬ ឆ្លើយថា វិនាសក៏ពិត តែសូម្បីដូច្នោះ កំណត់ បរិយត្តិដោយចំណែកមួយ ។ ប្រៀបដូចស្រះទឹកធំ មានកណ្ដាប់មាត់មាំទាំ មិន គប្បីពោលថា ទឹកមិនដក់នៅ ដូច្នេះ កាលមានទឹក មិនគប្បីពោលថា ផ្កា មាន ផ្កាបទុមជាដើម នឹងមិនរីកដូច្នេះ យ៉ាងណា សេចក្ដីនេះក៏ដូច្នោះដូចគ្នា បើមាន ព្រះត្រៃបិដក គឺ ពុទ្ធវចនៈ ក៏ដូចជាកណ្ដាប់មាត់ដ៏មាំទាំរបស់ស្រះធំនោះ មិនគប្បី ពោលថា មិនមានកុលបុត្រនៅបដិបត្តិឲ្យបរិបូណ៌បាន ដូចទឹកក្នុងស្រះធំ ដូច្នោះ ។ តែកំណត់ដល់បរិយត្តិ ដោយចំណែកមួយយ៉ាងនេះថា កាលកុលបុត្រទាំងនោះ មាន មិនគប្បីពោលថា ព្រះអរិយបុគ្គល មានសោតាបន្នជាដើមមិនមាន ដូចផ្កា មានផ្កាឈូកជាដើម ក្នុងស្រះធំ ដូច្នោះ ។

[ ២០១ ] បទថា **បឋវីធាតុ** បានដល់ មហាប្រឹថពីដែលមានកម្រាស់ ២ សែន ៤ នហុត ( ២ សែន ៤ ម៉ឺនយោជន៍ ) ។ បទថា **អាបោធាតុ** បានដល់ ទឹកដែលញ៉ាំងកប្បឲ្យវិនាស ចាប់ផ្ដើមតាំងអំពីផែនដីជន់លិចទៅខាងលើ រហូត ដល់ព្រហ្មលោកជាន់សុភកិណ្ហា ។ បទថា **តេជោធាតុ** បានដល់ ភ្លើងដែល ញ៉ាំងកប្បឲ្យវិនាស ផ្ដើមឆេះតាំងអំពីផែនដីឡើងទៅ រហូតដល់ព្រហ្មលោកជាន់ អាភស្សរា ។ បទថា **វាយោធាតុ** បានដល់ ខ្យល់ដែលញ៉ាំងកប្បឲ្យវិនាស ចាប់តាំងអំពីផែនដី បក់ឡើងទៅ រហូតដល់ព្រហ្មលោកជាន់វេហប្ផលា ក្នុងធម៌ មានបឋវីធាតុជាដើមនោះ សូម្បីធម៌ឯណានីមួយ មិនអាចញ៉ាំងសត្ថុសាសនៈ ឲ្យ

អន្តរធានបាន ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់យ៉ាងនេះ ។ បទថា **ឥធេវ តេ ឧប្បជ្ជន្តិ** សេចក្ដីថា មោឃបុរសទាំងនោះ រមែងកើតឡើងក្នុងសាសនារបស់តថាគតនេះឯង ដូចច្រែះកើតអំពីដែកស៊ីដែក ដូច្នោះ ។ បទថា **មោឃបុរិសា** គឺ បុរសទទេ ។

ក្នុងបទថា **អាទិកេនេវ ឱបិលាវេតិ** បានដល់ ដោយខាងដើម គឺដោយការប្រកាន់ បានដល់ ការចាប់ ។ បទថា **ឱបិលាវេតិ** គឺក្រឡាប់ ។ មានអធិប្បាយថា ទូកនៅក្នុងទឹកផ្ទុករបស់ រមែងក្រឡាប់ យ៉ាងណា ព្រះសទ្ធម្ម រមែងមិនអន្តរធានទៅ ព្រោះពេញដោយបរិយត្តិជាដើម ដូច្នោះ ។ ព្រោះកាលបរិយត្តិវិនាស បដិបត្តិក៏វិនាស ។ កាលបដិបត្តិវិនាស អធិគមក៏វិនាស កាលបដិបត្តិនៅបរិបូណ៌ បុគ្គលទ្រទ្រង់បរិយត្តិ គង់បដិបត្តិឲ្យបរិបូណ៌បាន ។ អ្នកបដិបត្តិឲ្យបរិបូណ៌បាន ក៏ញ៉ាំងអធិគម គឺ បដិវេធឲ្យបរិបូណ៌បាន ។ ទ្រង់សម្ដែងថា កាលបរិយត្តិជាដើមចម្រើន សាសនារបស់តថាគតនឹងចម្រើន ដូចព្រះចន្ទចែងចាំងពន្លឺ ដូច្នោះ ។

ឥឡូវនេះ កាលទ្រង់សម្ដែងធម៌ដែលជាហេតុអន្តរធាន និងការតាំងនៅមាំនៃព្រះសទ្ធម្ម ទើបត្រាស់ពាក្យជាដើមថា **បញ្ច ខោ** ដូច្នេះ ។

[ ២០២ ] ក្នុងបទទាំងនោះ បទថា **ឱក្កមនិយា** សេចក្ដីថា ការឈមចុះ គឺហេតុចំណែកខាងក្រោម ។ បទថា **អគារវា** ក្នុងបទថា **សត្ថរិ អគារវា** ជាដើម បានដល់ វៀរចាកការគោរព ។ បទថា **អប្បតិស្សា** បានដល់ ការមិនកោតក្រែង គឺមិនប្រព្រឹត្តឱនលំទោន ។ ក្នុងការមិនគោរពនោះ ភិក្ខុណា ឡើងកាន់លានព្រះ

ចេតិយ បាំងឆត្រ ពាក់ស្បែកជើង សម្លឹងមើលតែទីដទៃ ដើរជជែកគ្នាទៅ ។ ភិក្ខុនេះ ឈ្មោះថា មិនមានការគោរពក្នុងព្រះសាស្តា ។ ភិក្ខុណា កាលគេប្រកាស កាលដើម្បីស្តាប់ធម៌ ដែលភិក្ខុកំលោះ និងសាមណេរអង្គុយចោមរោម ឬកំពុង ធ្វើនវកម្មណាទីមួយដទៃ អង្គុយដេកលក់ក្នុងរោងស្តាប់ធម៌ ឬជាអ្នកមានចិត្ត រាយមាយ អង្គុយជជែករឿងដទៃ ភិក្ខុនេះឈ្មោះថា មិនគោរពក្នុងព្រះធម៌ ។ ឯភិក្ខុណាទៅកាន់ទីបម្រើរបស់ព្រះថេរៈ អង្គុយមិនថ្វាយបង្គំ យកដៃត្របោម ក្បាលជង្គង់ ធ្វើការបិទសំពត់ ឬឃ្នើសឃ្នងដៃ និងជើងណាមួយ មិនបានទទួល ការពោលនិមន្តក្នុងសម្នាក់ព្រះថេរៈ ភិក្ខុនេះឈ្មោះថា មិនគោរពក្នុងព្រះសង្ឃ ។ រីឯបុរសមិនញុំាងសិក្ខា៣ ឲ្យបរិបូណ៌ ជាបុគ្គលឈ្មោះថា មិនគោរពក្នុងសិក្ខា ។ បុគ្គលមិនញុំាងសមាបត្តិ ៨ ឲ្យកើត ឬមិនធ្វើសេចក្តីព្យាយាមដើម្បីការកើតនៃ សមាបត្តិទាំងនោះ ឈ្មោះថា មិនមានការគោរពក្នុងសមាធិ ។ ធម៌ចំណែកស គប្បីជ្រាបដោយផ្ទុយគ្នានឹងធម៌ខ្មៅ ដែលពោលហើយ ដោយប្រការដូច្នេះ ។

អដ្ឋកថា សទ្ធម្មប្បដិរូបកសូត្រ ចប់

# អាណិសូត្រទី ៧

[ ៣៤០ ] ព្រះមានព្រះភាគ ទ្រង់គង់នៅទៀបក្រុងសាវត្ថី ... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពីព្រេងនាយមក មានសម្ភោរមួយ ឈ្មោះ អានកៈ របស់ពួកក្សត្រនាមទសារហៈ ។ កាលបើរាងសម្ភោរឈ្មោះអានកៈនោះ ប្រេះធាហើយ ពួកក្សត្រទសារហៈ ក៏ពាសនូវរាងស្រោបដទៃភ្ជាប់អបទុក ។ ម្នាលភិក្ខុទាំងឡាយ មានសម័យដែលត្រូវតួរាងចាស់របស់សម្ភោរ ឈ្មោះ អានកៈ ខូចបាត់ទៅ សល់នៅតែរាងស្រោប ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីនេះមានឧបមេយ្យ ដូចក្នុងកាលជាអនាគត ព្រះសូត្រទាំងឡាយណា ដែលតថាគតសម្តែងហើយ ជាព្រះសូត្រដ៏ជ្រៅ មានអត្ថដ៏ជ្រៅ ជាលោកុត្តរ ប្រកបដោយសភាពដ៏សូន្យ ព្រះសូត្រទាំងនោះ កាលបើបុគ្គលពោល ពួកមហាជននឹងមិនស្តាប់ មិនដាក់ចុះនូវសោតៈ មិនយកចិត្តទុកដាក់ដើម្បីដឹង ទាំងមិនសម្គាល់ធម៌ទាំងនោះថា គួររៀន ឬ គួរទន្ទេញឡើយ ។ បើព្រះសូត្រទាំងឡាយណា ដែលអ្នកប្រាជ្ញជាកវីបានធ្វើជាពាក្យកាព្យឃ្លោង មានអក្សរដ៏វិចិត្រ មានព្យញ្ជនៈដ៏វិចិត្រជាខាងក្រៅ ជាសាវកភាសិត ព្រះសូត្រទាំងនោះ កាលបុគ្គលពោល ទើបមហាជននឹងស្តាប់ នឹងដាក់ចុះនូវសោតៈ នឹងយកចិត្ត ទុកដាក់ដើម្បីដឹង នឹងសម្គាល់នូវធម៌ទាំងនោះថា គួររៀន គួរទន្ទេញ ។

[ ៣៤១ ] ម្នាលភិក្ខុទាំងឡាយ ការវិនាសទៅនៃព្រះសូត្រដែលតថាគតសម្តែងហើយទាំងនោះ ជាព្រះសូត្រដ៏ជ្រៅ មានអត្ថដ៏ជ្រៅ ជាលោកុត្តរ ប្រកបដោយសភាពដ៏សូន្យ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ហេតុដូច្នោះ ក្នុងសាសនានេះ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះថា ព្រះសូត្រទាំងឡាយណា

ដែលព្រះតថាគតសម្ដែងហើយ ជាព្រះសូត្រដ៏ជ្រៅ មានអត្ថដ៏ជ្រៅ ជាលោកុត្តរ ប្រកបដោយសភាពដ៏សូន្យ ព្រះសូត្រទាំងនេះ កាលបុគ្គលពោល យើងនឹងប្រុងស្តាប់ ដាក់ចុះនូវសោតៈ យកចិត្តទុកដាក់ដើម្បីដឹង នឹងសម្គាល់នូវធម៌ទាំងនោះថា គួររៀន គួរទន្ទេញ ដូច្នេះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះចុះ ។

សូត្រទី ៧ ចប់

( បិដក ៣២ ទំព័រ ២៦៣ )

# អដ្ឋកថា អាណិសូត្រ

[ ៣៤០ ] ក្នុងអាណីសូត្រទី ៧ មានវិនិច្ឆ័យដូច្នេះ បទថា **ឧសារបាធំ** បានដល់ ពួកក្សត្រដែលមានឈ្មោះយ៉ាងនេះ ។ បានឮថា ស្តេចទាំងនោះ បានកាន់យក ១០ ចំណែកអំពីស្រូវ ដូច្នោះ ទើបប្រាកដឈ្មោះថា **ឧសារបា** ។ បទថា **អាណកោ** បានដល់ ស្គរមានឈ្មោះយ៉ាងនេះ ។

បានឮថា ក្នុងព្រៃហិមពាន្ត មានស្រះធំ ក្តាមធំមួយស៊ីដំរីដែលចុះទៅក្នុងស្រះនោះ ។ គ្រានោះ ពួកដំរីត្រូវក្តាមបៀតបៀន មានការឃើញរួមគ្នាថា ព្រោះអាស្រ័យកូនរបស់ដំរីញីនេះ ទើបពួកយើងនឹងមានសួស្តីបាន ទើបនាំគ្នាធ្វើការបូជាដំរីញីនោះ ។ ដំរីញីនោះក៏បានកើតកូន ជាដំរីមហេសក្តិ ។ ដំរីទាំង-ឡាយនាំគ្នាសក្ការៈកូនដំរីនោះផងដែរ ។ កូនដំរីចម្រើនវ័យហើយ សួរមេថា ហេតុអ្វីដំរីទាំងនេះ ធ្វើសក្ការៈដល់យើង ទើបដំរីញីតំណាលរឿងឲ្យស្តាប់ ។ កូនដំរីពោលថា ក្តាមនឹងធ្វើអ្វីខ្ញុំ ពួកយើងទៅទីនោះទាំងអស់គ្នាចុះ ដំរីនោះហែហមទៅដោយដំរីជាច្រើន ទៅក្នុងទីនោះ ហើយចុះក្នុងស្រះមុនគេនោះឯង ក្តាមកៀបជើងដំរីទុក ព្រោះសំឡេងទឹកនោះឯង ។ ក្តាមមានដង្កៀបធំ កូនដំរីមិនអាចធ្វើក្តាមឲ្យឃ្លាតទៅខាងនោះ ខាងនេះបាន ទើបស៊កប្រមោយចូល ក្នុងមាត់អន្ធចលាន់រំពង ។ ដំរីទាំងឡាយពោលថា កូនដំរីដែលពួកយើងយល់ថា បានអាស្រ័យហើយ នឹងមានសួស្តីនោះ ត្រូវក្តាមកៀបហើយ ទើបនាំគ្នារត់ខ្ចាត់ខ្ចាយទៅ ។

លំដាប់នោះ មេរបស់ដំរីឈរនៅក្នុងទីមិនឆ្ងាយ ពោលនឹងក្តាមដោយពាក្យជាទីស្រឡាញ់ថា ពួកយើងឈ្មោះថា ជាសត្វប្រសើរលើគោក ឯអ្នកឈ្មោះ

ថា ជាសត្វប្រសើរក្នុងទឹក បុគ្គលប្រសើរ មិនគួរបៀតបៀនបុគ្គលប្រសើរ ដូច្នេះ ហើយ ពោលគាថាថា

**យេ កុញ្ជរា សមុទ្ទស្មឹ គង្គាយ យមុនាយ ច**
**តេសំ ត្វំ វារិជោ សេដ្ឋោ មុញ្ច រោទន្តិយា បជំ ។**

ពួកក្ដាមណា ដែលនៅក្នុងសមុទ្រក្ដី ក្នុងទន្លេគង្គាក្ដី យមុនាក្ដី អ្នកជាសត្វទឹកប្រសើរជាងក្ដាមទាំងនោះ សូមអ្នកមេត្តាលែងកូន កាលដែលខ្ញុំកំពុងទួញយំរកកូន សូមអ្នកមេត្តាលែងកូន( របស់ខ្ញុំ )មកវិញ ក្នុងកាលឥឡូវនេះ ។

ធម្មតាសំឡេងមាតុគ្រាម រមែងធ្វើឲ្យបុរសវង្វេង ដូច្នោះ ទើបក្ដាមបានលាដង្កៀប កូនដំរីប្រញាប់ដកជើងទាំង ២ ឡើងជាន់លើខ្នងក្ដាម ។ ក្ដាមកាលត្រូវជាន់ស្នូកត្រូវបែកដូចភាជនៈដី ។ លំដាប់នោះ កូនដំរីយកក្អកទាំង ២ ចាក់ក្ដាមលើកឡើងបោះទៅលើគោក ហើយបន្លឺសំឡេង សម្ដែងសេចក្ដីត្រេកអរ ដំរីទាំងឡាយមកអំពីទីផ្សេងៗជាន់ក្ដាមនោះ ។ ដង្កៀបក្ដាម ១ បានបាក់ សក្កទេវរាជទ្រង់កាន់យកដង្កៀបក្ដាមនោះទៅ ។

ចំណែកដង្កៀបមួយទៀត ត្រូវខ្យល់ និងកម្ដៅថ្ងៃ ដុតរោលទាល់តែធ្មិនមានពណ៌ដូចទឹកល័ក្ខនោះឯង ។ កាលភ្លៀងធ្លាក់មក ដង្កៀបក្ដាមនោះត្រូវខ្សែទឹកបន្សាត់មកជាប់សំណាញ់របស់ព្រះរាជា ១០ នាក់បងប្អូន ដែលសន្ធឹងសំណាញ់ទុកលើទឹក កំពុងលេងទឹកក្នុងស្ទឹងគង្គា ។ កាលលេងទឹកហើយ លើកសំណាញ់ឡើង ព្រះរាជាទាំងនោះទ្រង់ឃើញដង្កៀបនោះ ត្រាស់សួរថា នេះជាអ្វីហ្ន៎ ។ មនុស្សទាំងឡាយប្រាប់ថា ដង្កៀបក្ដាម ព្រះអង្គ ។ ព្រះរាជា

ទាំងឡាយត្រាស់ថា ដង្កៀបក្ដាមនេះមិនអាចនាំទៅជាគ្រឿងប្រដាប់បាន ពួកយើងនឹងឲ្យពាសដង្កៀបក្ដាមនេះធ្វើស្គរ បញ្ជាឲ្យពាសហើយ ទ្រង់ក៏វាយ ។ សំឡេងស្គរលាន់ទូទៅពេញព្រះនគរ ១២ យោជន៍ ។ បន្ទាប់អំពីនោះ ព្រះរាជាទាំងឡាយត្រាស់ថា យើងមិនអាចប្រគំស្គរនេះរាល់ថ្ងៃបានទេ ចូរទុកជាមង្គលភេរីសម្រាប់ថ្ងៃមហោស្រពចុះ ទើបឲ្យធ្វើជាមង្គលភេរី ។ កាលប្រគំស្គរនោះ ប្រជានុរាស្ដ្រ ទោះមិនទាន់ផឹកទឹក មិនទាន់តែងខ្លួន ប្រញាប់ប្រញាល់ឡើងជិះជំរីជាដើមទៅប្រជុំ ។ ស្គរនោះក៏មានឈ្មោះថា អាណកៈ ព្រោះហាក់ដូចជាហៅប្រជាជនមក ដោយប្រការដូច្នេះ ។

បទថា **អញ្ញំ អាណឹ ឱទហឹសុ** សេចក្ដីថា ស្នៀតដទៃដែលសម្រេចដោយមាស និងប្រាក់ជាដើម ។ បទថា **អាណិសង្ឃាតោ វ អវសិស្សិ** សេចក្ដីថា ត្រឹមតែការបោះស្នៀតដែលសម្រេចដោយមាសជាដើមប៉ុណ្ណោះ បានសេសសល់នៅ ។ លំដាប់នោះ សំឡេងរបស់ស្គរនោះ ដែលឮប្រមាណ ១២ យោជន៍ សូម្បីនៅខាងក្នុងរាំងនន ក៏លំបាកនឹងឮ ។ បទថា **គម្ភីរា** សេចក្ដីថា ពោលដោយបាលី ព្រះសូត្រទាំងឡាយជ្រាលជ្រៅ ដូចជាសល្លសូត្រជាដើម ។ បទថា **គម្ភីរត្ថា** សេចក្ដីថា ពោលដោយអត្ថ ព្រះសូត្រទាំងឡាយដែលជ្រៅដូចជាមហាវេទល្លសូត្រជាដើម ។ បទថា **លោកុត្តរា** បានដល់ សម្ដែងអត្ថដែលជាលោកុត្តរ ។ បទថា **សុញ្ញតប្បដិសញ្ញុត្តា** សេចក្ដីថា ប្រកបសេចក្ដីដែលប្រកាសត្រឹមតែសុញ្ញតធម៌ប៉ុណ្ណោះ ។ បទថា **ឧគ្គហេតព្វំ បរិយាបុណិតព្វំ** សេចក្ដីថា ដែលគួរទន្ទេញ និងគួរសិក្សា ។ បទថា **កវិកតា** សេចក្ដីថា ដែលកវី

គឺអ្នកប្រាជ្ញបានរចនា ។ ក្រៅអំពីនោះ ជាវេវចនៈនៃបទថា **កាវិកតា** នោះឯង ។ បទថា **ចិត្តក្ខរា** បានដល់ មានអក្ខរៈវិចិត្រ ។ ក្រៅអំពីនោះ ជាវេវចនៈនៃបទថា **ចិត្តក្ខរា** នោះឯង ។ បទថា **ពាហិរកា** បានដល់ មានខាងក្រៅព្រះសាសនា ។ បទថា **សាវកភាសិតា** សេចក្តីថា ព្រះសូត្រទាំងនោះ ជាសាវកភាសិត ។ បទថា **សុស្សូសិស្សន្តិ** សេចក្តីថា សាមណេរ ភិក្ខុកំលោះ មាតុគ្រាម និងមហាគហបតី ជាដើម មានការពេញចិត្ត ព្រោះព្រះសូត្រទាំងនោះ មានអក្ខរៈវិចិត្រ និងសម្បូរដោយការស្តាប់ និងជាអ្នកប្រាជ្ញាប្រជុំស្តាប់ ដោយគិតថា បុគ្គលនេះជាធម្មកថិក ។

[ ៣៨១ ] បទថា **តស្មា** សេចក្តីថា ព្រោះហេតុនោះ ព្រះសូត្រទាំងឡាយដែលជាតថាគតភាសិត កាលពួកយើងមិនសិក្សា រមែងអន្តរធានបាត់ទៅ ។០៚

អដ្ឋកថា អាណិសូត្រ ចប់

# តតិយអនាគតសូត្រទី ៩

[ ៧៩ ] ម្នាលភិក្ខុទាំងឡាយ អនាគតភ័យនេះមាន ៥ យ៉ាង មិនទាន់កើតឡើងក្នុងកាលឥឡូវនេះទេ នឹងកើតឡើងតទៅក្នុងខាងមុខ អ្នកទាំងឡាយគួរដឹងច្បាស់ នូវអនាគតភ័យទាំងនោះ លុះដឹងច្បាស់ហើយ គួរព្យាយាមដើម្បីលះបង់ នូវអនាគតភ័យទាំងនោះចេញ ។ អនាគតភ័យ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលដ៏យូរអង្វែងទៅក្នុងអនាគត ភិក្ខុទាំងឡាយ នឹងមិនបានចម្រើនកាយ មិនបានចម្រើនសីល មិនបានចម្រើនចិត្ត មិនបានចម្រើនបញ្ញាទេ បើភិក្ខុទាំងនោះ មិនបានចម្រើនកាយ មិនបានចម្រើនសីល មិនបានចម្រើនចិត្ត មិនបានចម្រើនបញ្ញាហើយ នឹងញុំាងបុគ្គលដទៃឲ្យឧបសម្បទ ភិក្ខុទាំងនោះឯង នឹងមិនអាចដើម្បីទូន្មាន ក្នុងអធិសីល អធិចិត្ត និងអធិប្បញ្ញាបានឡើយ ភិក្ខុទាំងនោះ នឹងមិនបានចម្រើនកាយ មិនបានចម្រើនសីល មិនបានចម្រើនចិត្ត មិនបានចម្រើនបញ្ញា កាលបើភិក្ខុទាំងនោះ មិនបានចម្រើនកាយ មិនបានចម្រើនសីល មិនបានចម្រើនចិត្ត មិនបានចម្រើនបញ្ញាហើយ នឹងញុំាងបុគ្គលដទៃឲ្យឧបសម្បទ ភិក្ខុទាំងនោះឯង នឹងមិនអាចដើម្បីទូន្មានក្នុងអធិសីល អធិចិត្ត និងអធិប្បញ្ញាបានឡើយ ភិក្ខុទាំងនោះ មុខជានឹងមិនបានចម្រើនកាយ មិនបានចម្រើនសីល មិនបានចម្រើនចិត្ត មិនបានចម្រើនបញ្ញាដែរ ។ ម្នាលភិក្ខុទាំងឡាយ ការខូចវិន័យព្រោះខូចធម៌ ការខូចធម៌ព្រោះខូចវិន័យ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះជាអនាគតភ័យ ទី ១ មិនទាន់កើតឡើងក្នុងកាលឥឡូវនេះទេ នឹងកើតឡើងតទៅក្នុងខាងមុខ អ្នកទាំងឡាយ គួរដឹងច្បាស់នូវអនាគតភ័យនោះ លុះដឹងច្បាស់ហើយ គួរព្យាយាមដើម្បីលះបង់នូវអនាគតភ័យនោះបោលចេញ ។ ម្នាលភិក្ខុ

ទាំងឡាយ មួយទៀត ក្នុងកាលដ៏យូរអង្វែងទៅក្នុងអនាគត ភិក្ខុទាំងឡាយនឹងមិនបានចម្រើនកាយ មិនបានចម្រើនសីល មិនបានចម្រើនចិត្ត មិនបានចម្រើនបញ្ញាទេ បើភិក្ខុទាំងនោះមិនបានចម្រើនកាយ មិនបានចម្រើនសីល មិនបានចម្រើនចិត្ត មិនបានចម្រើនបញ្ញាហើយ ឲ្យនិស្ស័យដល់ភិក្ខុទាំងឡាយដទៃ ភិក្ខុទាំងនោះឯង ក៏មិនអាចដើម្បីនឹងទូន្មាន ក្នុងអធិសីល អធិចិត្ត និងអធិប្បញ្ញាបានឡើយ ភិក្ខុទាំងនោះ នឹងមិនបានចម្រើនកាយ មិនបានចម្រើនសីល មិនបានចម្រើនចិត្ត មិនបានចម្រើនបញ្ញា កាលបើភិក្ខុទាំងនោះ មិនបានចម្រើនកាយ មិនបានចម្រើនសីល មិនបានចម្រើនចិត្ត មិនបានចម្រើនបញ្ញាហើយ ឲ្យនិស្ស័យដល់ភិក្ខុទាំងឡាយដទៃ ភិក្ខុទាំងនោះឯងនឹងមិនអាចដើម្បីទូន្មានក្នុងអធិសីល អធិចិត្ត និងអធិប្បញ្ញាបានឡើយ ភិក្ខុទាំងនោះមុខជានឹងមិនបានចម្រើនកាយ មិនបានចម្រើនសីល មិនបានចម្រើនចិត្ត មិនបានចម្រើនបញ្ញាដែរ ។ ម្នាលភិក្ខុទាំងឡាយ ការខូចវិន័យព្រោះខូចធម៌ ការខូចធម៌ព្រោះខូចវិន័យ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះជាអនាគតភ័យទី ២ មិនទាន់កើតឡើងក្នុងកាលឥឡូវនេះទេ នឹងកើតឡើងតទៅក្នុងខាងមុខ អ្នកទាំងឡាយ គួរដឹងច្បាស់នូវអនាគតភ័យនោះ លុះដឹងច្បាស់ហើយ គួរព្យាយាមដើម្បីលះបង់នូវអនាគតភ័យនោះចេញ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ក្នុងកាលដ៏យូរអង្វែងទៅ ក្នុងអនាគត ភិក្ខុទាំងឡាយមិនបានចម្រើនកាយ មិនបានចម្រើនសីល មិនបានចម្រើនចិត្ត មិនបានចម្រើនបញ្ញាទេ កាលបើភិក្ខុទាំងនោះ មិនបានចម្រើនកាយ មិនបានចម្រើនសីល មិនបានចម្រើនចិត្ត មិនបានចម្រើនបញ្ញា ហើយសម្តែងនូវអភិធម្មកថា និងវេទល្លកថា ឈានចុះ

កាន់ធម៌ខ្មៅ ក៏មិនដឹងខ្លួន ។ ម្នាលភិក្ខុទាំងឡាយ ការខូចវិន័យព្រោះខូចធម៌ ការខូចធម៌ព្រោះខូចវិន័យ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះជាអនាគតភ័យទី ៣ មិនទាន់កើតឡើងក្នុងកាលឥឡូវនេះទេ នឹងកើតឡើងតទៅក្នុងអនាគត អ្នកទាំងឡាយ គួរដឹងច្បាស់នូវអនាគតភ័យនោះ លុះដឹងច្បាស់ហើយ គួរព្យាយាមដើម្បីលះបង់នូវអនាគតភ័យនោះចេញ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ក្នុងកាលដ៏យូរអង្វែងទៅ ក្នុងអនាគត ភិក្ខុទាំងឡាយមិនបានចម្រើនកាយ មិនបានចម្រើនសីល មិនបានចម្រើនចិត្ត មិនបានចម្រើនបញ្ញាទេ កាលបើភិក្ខុទាំងនោះ មិនបានចម្រើនកាយ មិនបានចម្រើនសីល មិនបានចម្រើនចិត្ត មិនបានចម្រើនបញ្ញាហើយ ពួកព្រះសូត្រណាដែលជាតថាគតភាសិត ជ្រាលជ្រៅ( ដោយបាលី ) ជ្រាលជ្រៅដោយអត្ថ ជាលោកុត្តរធម៌ ប្រកបដោយការៈសោះសូន្យ កាលបើព្រះសូត្រទាំងនោះ ដែលភិក្ខុកំពុងពោល ( ជនដទៃ ) ក៏មិនប្រាថ្នាដើម្បីស្តាប់ មិនផ្ទៀងត្រចៀកប្រុងស្តាប់ មិនតាំងចិត្តដើម្បីចង់ដឹងសោះ ទាំងមិនសម្គាល់នូវកិច្ចដែលខ្លួនត្រូវរៀន ត្រូវទន្ទេញយកធម៌នោះឡើយ បើពួកព្រះសូត្រណាដែលកវីតាក់តែងជាពាក្យកាព្យឃ្លោង មានអក្ខរៈដ៏វិចិត្រ មានព្យញ្ជនៈដ៏វិចិត្រ ជាពាក្យខាងក្រៅ ជាសាវកភាសិត កាលបើព្រះសូត្រទាំងនោះ ដែលភិក្ខុកំពុងពោល ( ទើបពួកជនដទៃ ) នឹងប្រាថ្នាចង់ស្តាប់ ផ្ទៀងត្រចៀកប្រុងស្តាប់ តាំងចិត្តដើម្បីចង់ដឹង ទាំងសម្គាល់នូវកិច្ចដែលខ្លួនត្រូវរៀន ត្រូវទន្ទេញយកធម៌នោះ ។ ម្នាលភិក្ខុទាំងឡាយ ការខូចវិន័យព្រោះខូចធម៌ ការខូចធម៌ព្រោះខូចវិន័យ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះជាអនាគតភ័យ ទី ៤ មិនទាន់កើត

ឡើងក្នុងកាលឥឡូវនេះទេ នឹងកើតឡើងតទៅខាងមុខ អ្នកទាំងឡាយគួរដឹងច្បាស់នូវអនាគតភ័យនោះ លុះដឹងច្បាស់ហើយ គួរព្យាយាមដើម្បីលះបង់នូវអនាគតភ័យនោះចេញ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ក្នុងកាលដ៏យូរអង្វែងទៅក្នុងអនាគត ភិក្ខុទាំងឡាយមិនបានចម្រើនកាយ មិនបានចម្រើនសីល មិនបានចម្រើនចិត្ត មិនបានចម្រើនបញ្ញាទេ កាលបើភិក្ខុទាំងនោះ មិនបានចម្រើនកាយ មិនបានចម្រើនសីល មិនបានចម្រើនចិត្ត មិនបានចម្រើនបញ្ញាហើយ ភិក្ខុទាំងឡាយជាថេរៈ នឹងមានសេចក្តីល្មោភច្រើន ជាអ្នកបន្ធូរបន្ថយ ជាប្រធានក្នុងការបន្ធូរបន្ថយ ជាអ្នកលះបង់ធុរៈក្នុងវិវេក នឹងមិនប្រាថ្នាសេចក្តីព្យាយាម ដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ប្រជុំជនដែលកើតជាខាងក្រោយ នឹងដល់នូវទិដ្ឋានុគតិតាមពួកភិក្ខុដែលជាអ្នកល្មោភច្រើននោះ សូម្បីប្រជុំជន ដែលកើតខាងក្រោយនោះទៀត ក៏នឹងមានសេចក្តីល្មោភច្រើន ជាអ្នកបន្ធូរបន្ថយ ជាប្រធានក្នុងការបន្ធូរបន្ថយ ជាអ្នកលះបង់ធុរៈក្នុងវិវេក នឹងមិនប្រាថ្នាសេចក្តីព្យាយាម ដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ ការខូចវិន័យព្រោះខូចធម៌ ការខូចធម៌ព្រោះខូចវិន័យ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះជាអនាគតភ័យទី ៥ មិនទាន់កើតឡើងក្នុងកាលឥឡូវនេះទេ នឹងកើតឡើងតទៅក្នុងខាងមុខ អ្នកទាំងឡាយ គួរដឹងច្បាស់នូវ

អនាគតភ័យនោះ លុះដឹងច្បាស់ហើយ គួរព្យាយាមដើម្បីលះបង់ នូវអនាគតភ័យនោះចេញ ។ ម្នាលភិក្ខុទាំងឡាយ អនាគតភ័យទាំង ៥ យ៉ាងនេះឯង មិនទាន់កើតឡើង ក្នុងកាលឥឡូវនេះទេ នឹងកើតឡើងទៅក្នុងខាងមុខ អ្នកទាំងឡាយគួរដឹងច្បាស់នូវអនាគតភ័យទាំងនោះ លុះដឹងច្បាស់ហើយ គួរព្យាយាមដើម្បីលះបង់នូវអនាគតភ័យនោះចេញ ។

# អដ្ឋកថា

## តតិយអនាគតសូត្រ

[ ៧៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងតតិយអនាគតសូត្រទី ៩ ដូចតទៅនេះ បទថា **ធម្មសន្ទោសា វិនយសន្ទោសោ** បានដល់ ការកាត់បង់នូវវិន័យ រមែងមានព្រោះខូចនូវធម៌ ។ សួរថា កាលធម៌ខូច វិន័យឈ្មោះថា ខូចដូចម្តេច ។ ឆ្លើយថា កាលធម៌ គឺសមថវិបស្សនាមិនតាំងគភ៌ វិន័យ ៥ យ៉ាង ក៏មិនមាន ។ កាលធម៌ខូចយ៉ាងនេះ វិន័យក៏ឈ្មោះថា ខូច ចំណែកសម្រាប់ ភិក្ខុទ្រុស្តសីល ឈ្មោះថា សំវរវិន័យមិនមាន កាលសំវរវិន័យនោះមិនមាន សមថៈ និងវិបស្សនាក៏មិនតាំងគភ៌ ។ ការខូចធម៌ ព្រោះខូចវិន័យ ក៏គប្បីជ្រាបដោយន័យយ៉ាងនេះ ។

បទថា **អភិធម្មកថំ** បានដល់ កថាពោលដោយធម៌ដ៏ក្រៃលែង មានសីលជាដើម ។ បទថា **វេទល្លកថំ** បានដល់ កថាលាយដោយញាណដែលប្រកបដោយការដឹង ។ បទថា **កណ្ហំ ធម្មំ ឱក្កមមានា** បានដល់ ឈានចុះកាន់

កម្មចំណែកខ្មៅ ដោយការស្វែងរក ដោយការប្រណាំងប្រជែង ព្រោះស្វែងរកខុស ។ម្យ៉ាងទៀត ភិក្ខុទាំងឡាយ ប្រហារបុគ្គលដោយចិត្តប្រទូស្តក្តី សាងកម្មចំណែកខ្មៅនោះសម្រាប់ខ្លួនក្តី ពោលដើម្បីលាភសក្ការៈក្តី ឈ្មោះថា ឈានចុះកាន់ធម៌ចំណែកខ្មៅដូចគ្នា ។

បទថា **គម្ភីរា** បានដល់ ជ្រៅដោយបាលី ។ បទថា **គម្ភីរត្ថា** បាន ដល់ ជ្រៅដោយអត្ថ ។ បទថា **លោកុត្តរា** បានដល់ សម្តែងលោកុត្តរធម៌ ។ បទថា **សុញ្ញតាបដិសំយុត្តា** បានដល់ ប្រកបដោយខន្ធ ធាតុ អាយតនៈ និងបច្ចយាការ ។ បទថា **ន អញ្ញាចិត្តំ ឧបដ្ឋបេស្សន្តិ** ប្រែថា នឹងមិនតាំងចិត្តដើម្បីដឹង ។ បទថា **ឧគ្គហេតព្វំ បរិយាបុណិតព្វំ** បានដល់ គប្បីសិក្សា គប្បីរៀន ។ បទថា **កាវិកតា** បានដល់ ដែលកវីតែងដោយចងជាពាក្យកាព្យជាដើម ។ បទថា **កាវេយ្យា** ជាវេវចនៈនៃពាក្យថា **កាវិកតា** នោះឯង ។ បទថា **ពាហិរកា** បានដល់ មានខាងក្រៅព្រះសាសនា ។ បទថា **សាវកភាសិតា** បានដល់ ព្រះសូត្រទាំងនោះជាសាវកភាសិត ។ ពាក្យដ៏សេសក្នុងសូត្រនេះ មានអត្ថងាយយល់ទាំងអស់ ព្រោះមានន័យ ដូចបានពោលហើយខាងដើម និងព្រោះដឹងបានងាយ ៕

( បិដក-៤៤ ទំព័រ ២២១ )

អដ្ឋកថា តតិយអនាគតសូត្រទី ៩ ចប់

# ទុតិយសរកានិសូត្រទី ៩

[ ២៣៨ ] កបិលវត្ថុនិទាន ។ សម័យនោះឯង ព្រះសរកានិសក្យរាជ ទ្រង់ទិវង្គតទៅ ។ ព្រះអង្គជាអ្នកដែលព្រះដ៏មានព្រះភាគ ទ្រង់ព្យាករហើយថា ជាសោតាបន្នបុគ្គល មានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ។ បានឮថា ពួកសក្យរាជច្រើនអង្គមកប្រជុំគ្នាក្នុងទីនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា អើហ្ន៎ អស្ចារ្យណាស់តើ អើហ្ន៎ មិនដែលកើតមានទេតើ បើយ៉ាងហ្នឹង នរណានឹងមិនបានជាសោតាបន្នបុគ្គលក្នុងសាសនានេះ ព្រះសរកានិសក្យរាជ ដែលទ្រង់ទិវង្គតទៅហើយ នេះមិនសមបើព្រះដ៏មានព្រះភាគទ្រង់ព្យាករថា ជាសោតាបន្នបុគ្គល មានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខសោះ ។ ដ្បិតព្រះសរកានិសក្យរាជ មិនបានធ្វើឲ្យពេញបរិបូណ៌ក្នុងសិក្ខាទេ ។

[ ២៣៩ ] គ្រានោះឯង ព្រះមហានាមសក្យរាជ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយគង់ក្នុងទីដ៏សមគួរ ។ លុះព្រះមហានាមសក្យរាជ គង់ក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូល ព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អម្បាញ់មិញនេះ ព្រះសរកានិសក្យរាជ ទ្រង់ទិវង្គតទៅហើយ ព្រះអង្គជាអ្នកដែលព្រះដ៏មានព្រះភាគ ទ្រង់ព្យាករថា ជាសោតាបន្នបុគ្គល មានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ។ បពិត្រព្រះអង្គដ៏ចម្រើន បានឮថា ពួកសក្យរាជច្រើនអង្គ មកប្រជុំគ្នាក្នុងទីនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា អើហ្ន៎ អស្ចារ្យណាស់តើ អើហ្ន៎ មិនដែលកើតមានទេតើ បើយ៉ាងហ្នឹង នរណានឹងមិនបាន

ជាសោតាបន្នបុគ្គលក្នុងសាសនានេះ ព្រះសរកានិសក្យរាជ ដែលទ្រង់ទិវង្គតទៅហើយនោះ មិនសមបើព្រះដ៏មានព្រះភាគ ទ្រង់ព្យាករថា ជាសោតាបន្នបុគ្គលមានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខសោះ ។ ដ្បិតព្រះសរកានិសក្យរាជ មិនបានធ្វើឲ្យពេញបរិបូណ៌ក្នុងសិក្ខាទេ ។

[ ២៤០ ] ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា បពិត្រព្រះមហានាម បុគ្គលណាជាឧបាសក ដល់នូវព្រះពុទ្ធជាទីពឹង ដល់នូវព្រះធម៌ជាទីពឹង ដល់នូវព្រះសង្ឃជាទីពឹងអស់រាត្រីវែង បុគ្គលនោះ គប្បីទៅកាន់អបាយដូចម្តេចបាន ។ បពិត្រព្រះមហានាម បុគ្គលកាលពោលដោយប្រពៃ គប្បីពោលតាមហេតុពិត ថាបុគ្គលជាឧបាសក ដល់នូវព្រះពុទ្ធជាទីពឹង ដល់នូវព្រះធម៌ជាទីពឹង ដល់នូវព្រះសង្ឃជាទីពឹង អស់រាត្រីវែង បុគ្គលកាលពោលដោយប្រពៃ គប្បីពោលចំពោះព្រះសរកានិសក្យរាជ បពិត្រព្រះមហានាម ព្រះសរកានិសក្យរាជ ជាឧបាសកដល់នូវព្រះពុទ្ធជាទីពឹង ដល់នូវព្រះធម៌ជាទីពឹង ដល់នូវព្រះសង្ឃជាទីពឹងអស់រាត្រីវែង ព្រះសរកានិសក្យរាជនោះ គប្បីទៅកាន់អបាយ ដូចម្តេចបាន ។

[ ២៤១ ] បពិត្រព្រះមហានាម បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកជ្រះថ្លាក្រៃលែងពិតប្រាកដ ក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ។ បេ ។ ព្រះអង្គជាគ្រូនៃទេវតា និងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត ។ ( បុគ្គលជាអ្នកជ្រះថ្លាក្រៃលែងពិតប្រាកដ ) ក្នុងព្រះធម៌ ។ ក្នុងព្រះសង្ឃ ។ ជាអ្នកមានបញ្ញាជាគ្រឿងរីករាយ

មានបញ្ញារាំងរៃ និងប្រកបដោយវិមុត្តិ ។ បុគ្គលនោះធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយបញ្ញាដ៏ក្រៃលែងដោយខ្លួនឯង ក្នុងបច្ចុប្បន្នហើយសម្រេចសម្រាន្តនៅ ។ បពិត្រព្រះមហានាម បុគ្គលនេះឯង ជាអ្នកបានរួចចាកនរក រួចចាកកំណើតតិរច្ឆាន រួចចាកប្រេតវិស័យ រួចចាកអបាយ ទុគ្គតិ វិនិបាត ។

[ ២៤២ ] បពិត្រព្រះមហានាម មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកជ្រះថ្លាក្រៃលែងពិតប្រាកដ ក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ។បេ។ ព្រះអង្គជាគ្រូនៃទេវតា និងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត ។ (ជាអ្នកជ្រះថ្លាក្រៃលែងពិតប្រាកដ) ក្នុងព្រះធម៌ ។ ក្នុងព្រះសង្ឃ ។ ជាអ្នកមានបញ្ញាជាគ្រឿងរីករាយ មានបញ្ញារាំងរៃ តែមិនប្រកបដោយវិមុត្តិ ។ បុគ្គលនោះ នឹងបរិនិព្វានក្នុងរវាងអាយុនៅមិនទាន់ដល់ពាក់កណ្ដាល នឹងបរិនិព្វានក្នុងអាយុផុតពាក់កណ្ដាលហើយ ជិតដល់ទីបំផុតនឹងបរិនិព្វាន ដោយធ្វើសេចក្ដីព្យាយាមយ៉ាងខ្លាំង នឹងបរិនិព្វានដោយមិនបាច់ធ្វើសេចក្ដីព្យាយាមពេកទេ នឹងមានខ្សែធម៌ខ្ពស់ខាងលើទៅកាន់អកនិដ្ឋភព ព្រោះអស់ពួកសញ្ញោជនៈជាចំណែកខាងក្រោម ៥ ។ បពិត្រព្រះមហានាម បុគ្គលនេះឯង ជាអ្នករួចចាកនរក រួចចាកកំណើតតិរច្ឆាន រួចចាកប្រេតវិស័យ រួចចាកអបាយ ទុគ្គតិ វិនិបាត ។

[ ២៤៣ ] បពិត្រព្រះមហានាម មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកជ្រះថ្លាក្រៃលែងពិតប្រាកដ ក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ។បេ។

ព្រះអង្គជាគ្រូនៃទេវតា និងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត ។ (ជាអ្នកជ្រះថ្លាក្រៃលែងពិតប្រាកដ) ក្នុងព្រះធម៌ ។ ក្នុងព្រះសង្ឃ ។ តែមិនមានបញ្ញាជាគ្រឿងរីករាយ មិនមានបញ្ញាវាងវៃ និងមិនប្រកបដោយវិមុត្តិ ។ បុគ្គលនោះ ជាសកទាគាមី នឹងមកកាន់លោកនេះម្តងទៀត ទើបធ្វើនូវទីបំផុតនៃទុក្ខបាន ព្រោះអស់សញ្ញោជនៈ ៣ ប្រការ ព្រោះធ្វើរាគៈ ទោសៈ មោហៈ ឲ្យស្រាលស្តើង ។ បពិត្រព្រះមហានាម បុគ្គលនេះឯងជាអ្នករួចចាកនរក រួចចាកកំណើតតិរច្ឆាន រួចចាកប្រេតវិស័យ រួចចាកអបាយ ទុគ្គតិ វិនិបាត ។

[ ២៤៤ ] បពិត្រព្រះមហានាម មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកជ្រះថ្លាក្រៃលែងពិតប្រាកដ ក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ។បេ។ ព្រះអង្គជាគ្រូនៃទេវតា និងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត ។ (ជាអ្នកជ្រះថ្លាក្រៃលែងពិតប្រាកដ) ក្នុងព្រះធម៌ ។ ក្នុងព្រះសង្ឃ ។ តែមិនមានបញ្ញាជាគ្រឿងរីករាយ មិនមានបញ្ញាវាងវៃ និងមិនប្រកបដោយវិមុត្តិ ។ បុគ្គលនោះ ជាសោតាបន្នបុគ្គល មានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ព្រោះអស់សញ្ញោជនៈទាំង ៣ ប្រការ ។ បពិត្រព្រះមហានាម បុគ្គលនេះឯងជាអ្នករួចចាកនរក រួចចាកកំណើតតិរច្ឆាន រួចចាកប្រេតវិស័យ រួចចាកអបាយ ទុគ្គតិ វិនិបាត ។

[ ២៤៥ ] បពិត្រព្រះមហានាម មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ ជា

អ្នកមិនជ្រះថ្លាក្រៃលែងពិតប្រាកដក្នុងព្រះពុទ្ធទេ ។ ក្នុងព្រះធម៌ទេ ។ ក្នុងព្រះសង្ឃទេ ។ មិនមានបញ្ញាជាគ្រឿងរីករាយទេ មិនមានបញ្ញារាងរៃទេ មិនប្រកបដោយវិមុត្តិទេ ។ តែថាធម៌អម្បាលនេះ គឺសទ្ធិន្ទ្រិយ ។បេ។ បញ្ញិន្ទ្រិយ តែងមានដល់បុគ្គលនោះ ។ មួយទៀត ធម៌ទាំងឡាយ ដែលព្រះតថាគតទ្រង់ប្រកាសហើយ ជាធម៌គួរដល់ការពិចារណា ដោយបញ្ញាដ៏ក្រៃលែង ដល់បុគ្គលនោះ ។ បពិត្រព្រះមហានាម បុគ្គលនេះឯងជាអ្នកមិនទៅកាន់នរក មិនទៅកាន់កំណើតតិរច្ឆាន មិនទៅកាន់ប្រេតវិស័យ មិនទៅកាន់អបាយ ទុគ្គតិ វិនិបាត ។

[ ២៤៦ ] បពិត្រព្រះមហានាម មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនបានជ្រះថ្លាក្រៃលែងពិតប្រាកដ ក្នុងព្រះពុទ្ធទេ ។ ក្នុងព្រះធម៌ទេ ។ ក្នុងព្រះសង្ឃទេ ។ មិនមានបញ្ញាជាគ្រឿងរីករាយទេ មិនមានបញ្ញារាងរៃទេ មិនប្រកបដោយវិមុត្តិទេ តែថា ធម៌អម្បាលនេះ គឺសទ្ធិន្ទ្រិយ ។បេ។ បញ្ញិន្ទ្រិយ តែងមានដល់បុគ្គលនោះ ។ មួយទៀត បុគ្គលនោះគ្រាន់តែមាន សទ្ធា និងសេចក្តីស្រឡាញ់ ក្នុងព្រះតថាគត ។ បពិត្រព្រះមហានាម បុគ្គលនេះឯង ជាអ្នកមិនទៅកាន់នរក មិនទៅកាន់កំណើតតិរច្ឆាន មិនទៅកាន់ប្រេតវិស័យ មិនទៅកាន់អបាយ ទុគ្គតិ វិនិបាត ។

[ ២៤៧ ] បពិត្រព្រះមហានាម ដូចពូជទាំងឡាយ ដែលបាក់ខ្ទេចដែលស្អុយ ដែលក្រៀមក្រោះ ដោយខ្យល់ និងកម្តៅថ្ងៃ ដែលឥតពន្លក ដែលគេទុកដាក់ក្នុងទីមិនស្អាត ភ្លៀងក៏បង្អុរនូវទឹកភ្លៀងដោយស្រួល ចុះកាន់ស្រែដែលក្រហេងក្រហូង មានផែនដីអាក្រក់ ដែលគេមិនទាន់បានគាស់រានយកជង្គត់ឈើ

ចេញទៅឡើយ ពូជទាំងអម្បាលនោះ នឹងដល់នូវសេចក្តីចម្រើន ដុះដាល លូតលាស់បានដែរឬទេ ។ មិនបានទេ ព្រះអង្គ ។ បពិត្រព្រះមហានាម សេចក្តីឧបមេយ្យក៏ដូច្នោះដែរ ធម៌ក្នុងលោកនេះ ជាធម៌ដែលបុគ្គលពោលមិនល្អ ជាធម៌ដែលបុគ្គលប្រកាសមិនល្អ ជាធម៌មិននាំសត្វចេញចាកទុក្ខបាន មិនប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់ស្ងាត់ ជាធម៌ដែលបុគ្គលមិនមែនសម្មាសម្ពុទ្ធ ប្រកាសហើយ តថាគតពោលថា ធម៌នេះ ដូចស្រែដែលក្រហេងក្រហូង ។ មួយវិញទៀត សាវកដែលប្រតិបត្តិនូវធម៌តាមធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តនូវធម៌ដ៏សមគួរ នៅគ្រប់ឥរិយាបថ ក្នុងធម៌នោះ តថាគតពោលថា សាវកអ្នកប្រតិបត្តិធម៌តាមធម៌ នៅគ្រប់ឥរិយាបថនេះ ដូចជាពូជដ៏អាក្រក់ ។

[ ២៤៨ ] បពិត្រព្រះមហានាម ដូចពូជទាំងឡាយ ដែលមិនបាក់ខ្ទេច ដែលមិនស្អុយ ដែលមិនក្រៀមក្រោះដោយខ្យល់ និងកម្តៅថ្ងៃ មានពន្លកដែលគេទុកដាក់ក្នុងទីដ៏ស្អាត ទាំងភ្លៀងក៏បង្អុរនូវទឹកភ្លៀងដោយស្រួល ចុះកាន់ស្រែដែលល្អ មានផែនដីរាបស្មើ ដែលគេបានគាស់រានយកជង្គត់ឈើចេញហើយ ពូជអម្បាលនោះនឹងដល់នូវសេចក្តីចម្រើន ដុះដាល លូតលាស់ឡើងបានឬទេ ។ យ៉ាងហ្នឹងហើយ ព្រះអង្គ ។ បពិត្រព្រះមហានាម សេចក្តីឧបមេយ្យ ក៏ដូច្នោះដែរ ធម៌ក្នុងលោកនេះ ជាធម៌ដែលបុគ្គលពោលទុកល្អហើយ ធម៌ដែលបុគ្គលប្រកាសទុកល្អហើយ ជាធម៌នាំសត្វចេញចាកទុក្ខបាន ជាធម៌ប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់ស្ងាត់ ជាធម៌ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រកាសហើយ តថាគតពោលថា ធម៌នេះ ដូចជាស្រែដ៏ល្អ ។ មួយវិញទៀត សាវកដែលប្រតិបត្តិនូវធម៌តាម

ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តនូវធម៌ដ៏សមគួរ នៅគ្រប់ឥរិយាបថ ក្នុងធម៌នោះ តថាគតពោលថា សាវកអ្នកប្រតិបត្តិធម៌តាមធម៌ នៅគ្រប់ឥរិយាបថនេះ ដូចជាពូជដ៏ល្អ ។ នឹងបាច់ពោលទៅថ្វី ដល់ព្រះសរកានិសក្យរាជ បពិត្រព្រះមហានាម ព្រះសរកានិសក្យរាជ ជាអ្នកបានធ្វើឲ្យពេញបរិបូណ៌ក្នុងសិក្ខា ក្នុងកាលជិតមរណៈ ។

# អដ្ឋកថា ទុតិយសរកានិសូត្រ

[ ២៤៧ ] គប្បីជ្រាបអធិប្បាយក្នុងទុតិយសរកានិសូត្រទី ៥ ដូចតទៅ បទថា **ទុក្ខេត្តំ** បានដល់ ស្រែដែលមិនស្មើគ្នា ។ បទថា **ទុព្ភូមី** បានដល់ មានផ្ទៃដីរីង ប្រកបដោយជាតិប្រៃ ។ បទថា **ខណ្ឌានិ** បានដល់ បែកទូទៅ ។ បទថា **បូតីនិ** បានដល់ ជាំទឹកហើយ ក៏ស្អុយ ។ បទថា **វាតាតបហតានិ** សេចក្ដីថា ដល់នូវការមិនមានរស ព្រោះខ្យល់ និងកម្ដៅ ប៉ះខ្ទប់ហើយ ។ បទថា **អសារាទានិ** បានដល់ មិនកាន់យកខ្លឹម គឺ មិនទាន់កើតខ្លឹម ។ បទថា **អសុខសយិតានិ** សេចក្ដីថា ដាក់ក្នុងជង្រុកជាដើម មិនរក្សាឲ្យល្អ ។

[ ២៤៨ ] បទថា **សុខសយិតានិ** សេចក្ដីថា មិនផុះអស់ ៤ ខែ អំពីទីដែលរក្សាទុក ។ ល។

អដ្ឋកថា ទុតិយសរកានិសូត្រ ចប់

# បរិស័ទ ២ ពួក

[ ២៩២ ] ម្នាលភិក្ខុទាំងឡាយ បរិស័ទនេះមាន ២ ពួក ។ បរិស័ទ ២ ពួក តើដូចម្តេច ។ គឺបរិស័ទសិក្សាខុសទំនង មិនសិក្សាដោយការសាកសួរ ១ បរិស័ទសិក្សាដោយការសាកសួរ មិនសិក្សាខុសទំនង ១ ។ ម្នាលភិក្ខុទាំងឡាយ បរិស័ទសិក្សាខុសទំនង មិនសិក្សាដោយការសាកសួរ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពួកសូត្រណា ដែលជាភាសិតរបស់តថាគត ដ៏ជ្រាលជ្រៅ មានអត្ថដ៏ជ្រាលជ្រៅ ជាលោកុត្តរ ប្រកបដោយសុញ្ញតធម៌ កាលបើពួកសូត្រនោះដែលគេកំពុងសម្តែង ក៏មិនប្រុងស្តាប់ មិនផ្ទៀងត្រចៀកស្តាប់ មិនទប់ចិត្តដែលរាយមាយ ទាំងមិនសម្គាល់ថា គួររៀន គួរសិក្សាធម៌ទាំងនោះឡើយ ពួកសូត្រណាដែលអ្នកប្រាជ្ញបានតែងទុកជាពាក្យកាព្យ មានអក្ខរៈវិចិត្រ មានព្យញ្ជនៈវិចិត្រ ជាសូត្រខាងក្រៅ ជាសាវកភាសិត កាលបើសូត្រទាំងនោះដែលគេកំពុងសម្តែង ក៏ប្រុងស្តាប់ ផ្ទៀងត្រចៀកស្តាប់ ទប់ចិត្តដែលរាយមាយ ទាំងសម្គាល់ថា គួររៀន គួរសិក្សាធម៌ទាំងនោះផង ភិក្ខុទាំងនោះ លុះសិក្សាធម៌នោះហើយ មិនបានសាកសួរគ្នាទៅវិញទៅមក មិនរើជម្រះផងថា ព្យញ្ជនៈនេះដូចម្តេច អត្ថរបស់ភាសិតនេះដូចម្តេច ភិក្ខុទាំងនោះ មិនបានបើករបស់ដែលកំបាំងផង មិនបានធ្វើរបស់ដែលជ្រៅឲ្យរាក់ផង មិនបន្ទោបង់សេចក្តីសង្ស័យក្នុងធម៌ទាំងឡាយ ដែលជាហេតុគួរឲ្យសង្ស័យជាច្រើនស្ថានផង ក្នុងបរិសទ្យណា ម្នាលភិក្ខុទាំងឡាយ បរិស័ទនេះ ហៅថា បរិស័ទសិក្សាខុសទំនង មិនសិក្សាដោយការសាកសួរឡើយ ។ ម្នាលភិក្ខុទាំងឡាយ ចុះបរិស័ទសិក្សាដោយការសាកសួរ មិនសិក្សាខុសទំនង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុង

សាសនានេះ ពួកសូត្រណា ដែលអ្នកប្រាជ្ញតែងជាពាក្យកាព្យ មានអក្ខរៈវិចិត្ត មានព្យញ្ជនៈវិចិត្ត ជារបស់ខាងក្រៅ ជាសាវកភាសិត កាលបើសូត្រទាំងនោះ ដែលគេកំពុងសំដែង ក៏មិនប្រុងស្តាប់ មិនផ្ទៀងត្រចៀកស្តាប់ មិនទប់ចិត្តរាយមាយ ទាំងមិនសម្គាល់ថា គួររៀន គួរសិក្សាធម៌ទាំងនោះដែរ ឯពួកសូត្រណា ដែលជាភាសិតរបស់តថាគត ដ៏ជ្រាលជ្រៅ មានអត្ថដ៏ជ្រាលជ្រៅ ជាលោកុត្តរ ប្រកបដោយសុញ្ញតធម៌ កាលបើសូត្រទាំងនោះដែលគេកំពុងសំដែង ក៏ប្រុងស្តាប់ ផ្ទៀងត្រចៀកស្តាប់ ទប់ចិត្តរាយមាយ ទាំងសម្គាល់ថា គួររៀន គួរសិក្សាធម៌ទាំងនោះដែរ លុះភិក្ខុទាំងនោះ សិក្សាធម៌នោះហើយ សាកសួរគ្នាទៅវិញទៅមក រើជម្រះថា ព្យញ្ជនៈនេះដូចម្តេច អត្ថរបស់ភាសិតនេះដូចម្តេច ភិក្ខុទាំងនោះ បើករបស់ដែលកំបាំងផង ធ្វើរបស់ដែលជ្រៅឲ្យរាក់ផង បន្ទោបង់សេចក្តីសង្ស័យ ក្នុងធម៌ទាំងឡាយ ដែលជាហេតុគួរឲ្យសង្ស័យជាច្រើនស្ថានបានផង ក្នុងបរិស័ទណា ម្នាលភិក្ខុទាំងឡាយ បរិស័ទនេះ ហៅថា បរិស័ទសិក្សាដោយការសាកសួរ មិនសិក្សាខុសទំនងឡើយ ។ ម្នាលភិក្ខុទាំងឡាយ បរិស័ទមាន ២ ពួកនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបរិស័ទ ២ ពួកនេះ បរិស័ទដែលសិក្សាដោយការសាកសួរ មិនសិក្សាខុសទំនងនុ៎ះ ទើបប្រសើរ ។

( បិដក៤០ ទំព័រ១៦២ )

# អដ្ឋកថា

## សូត្រទី ៦

[ ២៩២ ] ក្នុងសូត្រទី ៦ មានវិនិច្ឆ័យដូចតទៅនេះ បទថា **ឧក្កាចិតវិនីតា** បានដល់ ទូន្មានលំបាក ។ បទថា **នោ បដិបុច្ឆាវិនីតា** បានដល់ មិនជាបុគ្គលប្រៀនប្រដៅដោយសាកសួរ ។ បទថា **គម្ភីរា** បានដល់ ជ្រៅដោយបាលី ដូចជាចូឡវេទល្លសូត្រជាដើម ។ បទថា **គម្ភីរត្ថា** បានដល់ ជ្រៅដោយអត្ថដូចជាមហាវេទល្លសូត្រជាដើម ។ បទថា **លោកុត្តរា** បានដល់ សម្តែងអត្ថជាលោកុត្តរ។ បទថា **សុញ្ញតបដិសំយុត្តា** បានដល់ ប្រកាសត្រឹមតែជាសុញ្ញតធម៌ប៉ុណ្ណោះ ដូចជាអសង្ខតសំយុត្តជាដើម ។ បទថា **ន អញ្ញាចិត្តំ ឧបដ្ឋបេន្តិ** បានដល់ មិនតាំងចិត្តដើម្បីដឹង គឺ ដេកលក់ខ្លះ បញ្ជូនចិត្តទៅកាន់ទីដទៃខ្លះ ។ បទថា **ឧគ្គហេតព្វំ បរិយាបុណិតព្វំ** បានដល់ ដែលគប្បីកាន់យកផង គប្បីរៀនផង ។ បទថា **កវិកតា** បានដល់ កវីតែង ។ បទថា **កាវេយ្យា** ក្រៅអំពីនេះ ជាវេវចនៈនៃបទថា **កវិកតា** នោះឯង ។ បទថា **ចិត្តក្ខរា** ប្រែថា មានអក្ខរៈវិចិត្រ ។ បទថា **ចិត្តព្យញ្ជនា** ក្រៅពីនេះ ជាវេវចនៈនៃបទថា **ចិត្តក្ខរា** នោះដូចគ្នា ។ បទថា **ពាហិរកា** បានដល់ ជាសុត្តន្តៈក្រៅព្រះសាសនា ។ បទថា **សាវកភាសិតា** បានដល់ ដែលពួកសាវកទាំងនោះ បានពោល ។ បទថា **សុស្សូសន្តិ** សេចក្តីថា មានចិត្តជាក់ច្បាស់ តាំងចិត្តស្តាប់យ៉ាងល្អ ព្រោះមានអក្ខរៈវិចិត្រ និងសម្បូរដោយបទ ។ បទថា **នចេវ អញ្ញមញ្ញំ បដិបុច្ឆន្តិ** សេចក្តីថា មិនបានសួរអត្ថ អនុសន្ធិ ឬខាងដើម ខាងចុងនៃគ្នានឹងគ្នា ។ បទថា **ន បដិវិចរន្តិ** សេចក្តីថា មិនបានត្រាច់ទៅសាកសួរ ។ បទថា **ឥទំ កថំ** សេចក្តីថា ព្យញ្ជនៈ

ព្យញ្ជនៈនេះ គប្បីយល់ដូចម្ដេច គឺគប្បីយល់យ៉ាងណា ។ បទថា **ឥមស្ស ក្វត្ថោ** សេចក្ដីថា ភាសិតនេះមានអត្ថដូចម្ដេច មានអនុសន្ធិដូចម្ដេច មានខាងចុង និង ខាងដើមដូចម្ដេច ។ បទថា **អវិវដំ** បានដល់ ដែលនៅបិទបាំង ។ បទថា **ន វិវរន្តិ** បានដល់ មិនបើកផ្សាយ ។ បទថា **អនុត្តានីកតំ** បានដល់ ដែលមិនប្រាកដ ។ បទថា **ន ឧត្តានីករោន្តិ** សេចក្ដីថា មិនបានធ្វើឲ្យប្រាកដ ។ បទថា **កង្ខា-ឋានីយេសុ** បានដល់ ដែលជាហេតុនៃការសង្ស័យ ។ ធម៌ចំណែកស គប្បីជ្រាប ផ្ទុយគ្នាក្នុងធម៌ចំណែកខ្មៅ ដែលពោលហើយនេះ ៕

អដ្ឋកថា សូត្រទី ៦ ចប់

# មហាប្រទេសទាំង៤

[ ១១២ ] គ្រានោះ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងភណ្ឌគ្រាមតាមសមគួរដល់ពុទ្ធអធ្យាស្រ័យ ហើយទ្រង់ត្រាស់ហៅ ព្រះអានន្ទមានអាយុមកថា ម្នាលអានន្ទ មក យើងនឹងទៅកាន់ហត្ថិគ្រាម អម្ពគ្រាម ជម្ពុគ្រាម និងភោគនគរ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរទៅដល់ភោគនគរ ព្រមដោយភិក្ខុសង្ឃជាច្រើនអង្គ ។ បានឮថា ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងអានន្ទចេតិយ ជិតភោគនគរនោះ ។ ក្នុងទីនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងមហាប្រទេសទាំង ៤ នេះ អ្នកទាំងឡាយចូរស្តាប់ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសម្តែងប្រាប់ ។ ភិក្ខុទាំងនោះទទួលព្រះបន្ទូលនៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា

[ ១១៣ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គប្បីពោលយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ពាក្យនុ៎ះ ខ្ញុំបានស្តាប់ បានទទួលចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំអាលត្រេកអរ កុំអាលឃាត់កាសិតរបស់ភិក្ខុនោះឡើយ ។ លុះអ្នកទាំងឡាយ មិនទាន់ត្រេកអរ មិនទាន់ឃាត់ហើយ ត្រូវរៀននូវបទ និងព្យញ្ជនៈទាំងនោះឲ្យចាំល្អ ហើយ ស្ទាបស្ទង់មើលក្នុងព្រះសូត្រ ប្រៀបធៀបមើលក្នុងព្រះវិន័យ ។ បទ និង ព្យញ្ជនៈទាំងនោះ កាលបើអ្នកទាំងឡាយស្ទាបស្ទង់មើលក្នុងព្រះសូត្រ ប្រៀបធៀបមើលក្នុងព្រះវិន័យទៅ

ហើយ មិនប្រជុំចុះ គឺមិនមានក្នុងព្រះសូត្រផង មិនប្រាកដក្នុងព្រះវិន័យផងទេ ។ អ្នកទាំងឡាយគប្បីដល់នូវសេចក្ដីចូលចិត្ត ក្នុងពាក្យនេះថា នេះមិនមែនជាព្រះពុទ្ធដីការបស់ព្រះមានព្រះភាគនោះទេ ជាពាក្យដែលភិក្ខុនេះ រៀនខុសដោយពិត ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយ ត្រូវចោលពាក្យនុ៎ះចេញ ។ បទ និងព្យញ្ជនៈទាំងនោះ កាលបើអ្នកទាំងឡាយ ស្ទាបស្ទង់មើលក្នុងព្រះសូត្រ ប្រៀបធៀបមើលក្នុងព្រះវិន័យទៅហើយ ក៏ប្រជុំចុះក្នុងព្រះសូត្រផង ប្រាកដក្នុងព្រះវិន័យផង ។ អ្នកទាំងឡាយ គប្បីដល់នូវសេចក្ដីចូលចិត្តក្នុងពាក្យនេះថា នេះជាព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគនោះ ដែលភិក្ខុនេះរៀនត្រូវល្អហើយ ដោយពិត ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីចាំទុកនូវមហាប្រទេស ជាបឋមនេះចុះ ។

[ ១១៤ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គប្បីពោលយ៉ាងនេះថា ព្រះសង្ឃនៅក្នុងអាវាសឯណោះ មានទាំងភិក្ខុជាថេរៈ មានទាំងភិក្ខុជាប្រធាន ខ្ញុំបានស្ដាប់បានទទួលចំពោះមុខព្រះសង្ឃនោះថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំអាលត្រេកអរ កុំអាលឃាត់នូវភាសិតរបស់ភិក្ខុនោះឡើយ ។ លុះអ្នកទាំងឡាយ មិនទាន់ត្រេកអរ មិនទាន់ឃាត់ ហើយត្រូវរៀននូវបទ និង ព្យញ្ជនៈទាំងនោះ ឲ្យចាំល្អ ហើយស្ទង់មើលក្នុងព្រះសូត្រ ប្រៀបធៀបមើលក្នុងព្រះវិន័យ ។ បទ និងព្យញ្ជនៈទាំងនោះ កាលបើអ្នកទាំងឡាយ ស្ទង់មើលក្នុងព្រះសូត្រ ប្រៀបធៀបមើលក្នុងព្រះវិន័យទៅហើយ មិនប្រជុំចុះក្នុងព្រះសូត្រផង មិនប្រាកដក្នុងព្រះវិន័យ

ផងទេ ។ អ្នកទាំងឡាយ គប្បីដល់នូវសេចក្ដីចូលចិត្តក្នុងពាក្យនេះថា នេះមិនមែនជាព្រះពុទ្ធដីការបស់ព្រះមានព្រះភាគទេ ជាពាក្យដែលភិក្ខុសង្ឃនោះរៀនខុសដោយពិត ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយគប្បីចោលពាក្យនុ៎ះចេញ ។ បទ និងព្យញ្ជនៈ ទាំងនោះ កាលបើអ្នកទាំងឡាយ ស្ទង់មើលក្នុងព្រះសូត្រ ប្រៀបធៀបមើលក្នុងព្រះវិន័យទៅហើយ ក៏ប្រជុំចុះក្នុងព្រះសូត្រផង ប្រាកដក្នុងព្រះវិន័យផង ។ អ្នកទាំងឡាយ គប្បីដល់នូវសេចក្ដីចូលចិត្តក្នុងពាក្យនោះថា នេះជាព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគនោះ ដែលព្រះសង្ឃនោះរៀនត្រូវល្អហើយដោយពិត ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីចាំទុកនូវមហាប្រទេសជាគម្រប់ពីរនេះចុះ ។

[ ១១៥ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គប្បីពោលយ៉ាងនេះថា ភិក្ខុជាថេរៈច្រើនអង្គ នៅក្នុងអាវាសឯណោះ សុទ្ធតែជាពហុស្សូត ចេះចាំក្នុងគម្ពីរនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ខ្ញុំបានស្ដាប់ បានទទួលចំពោះមុខព្រះថេរៈទាំងនោះថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំអាលត្រេកអរនឹងភាសិតរបស់ភិក្ខុនោះឡើយ ។បេ។ បទ និងព្យញ្ជនៈ មិនប្រាកដក្នុងព្រះវិន័យ ។ អ្នកទាំងឡាយ គប្បីដល់នូវសេចក្ដីចូលចិត្តក្នុងពាក្យនេះថា នេះមិនមែនជាព្រះពុទ្ធដីការបស់ព្រះមានព្រះភាគនោះទេ ជាពាក្យដែលព្រះថេរៈទាំងនោះរៀនខុសដោយពិត ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយ គប្បីចោលពាក្យនុ៎ះចេញ ។ បទ និងព្យញ្ជនៈទាំងនោះ កាលបើអ្នកទាំងឡាយស្ទង់មើលក្នុងព្រះសូត្រ ។បេ។

ប្រាកដក្នុងព្រះវិន័យ ។ អ្នកទាំងឡាយគប្បីដល់នូវសេចក្តីចូលចិត្តក្នុងពាក្យនេះថា នេះជាព្រះពុទ្ធដីការបស់ព្រះមានព្រះភាគនោះ ដែលព្រះថេរៈទាំងនោះ រៀនត្រូវល្អ ហើយដោយពិត ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីចាំទុកនូវមហាបទេស ជាគម្រប់ ៣ នេះចុះ ។

[ ១១៦ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គប្បីពោលយ៉ាង នេះថា ភិក្ខុជាថេរៈនៅក្នុងអាវាសឯណោះ ជាពហុស្សូត ចេះចាំក្នុងគម្ពីរ និកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ខ្ញុំបានស្តាប់ បានទទួល ចំពោះមុខព្រះ ថេរៈអង្គនោះថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះ សាស្តា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំអាលត្រេកអរ កុំអាលឃាត់នូវ ភាសិតរបស់ភិក្ខុនោះឡើយ ។ លុះអ្នកទាំងឡាយ មិនទាន់ត្រេកអរ មិនទាន់ឃាត់ ហើយ គប្បីរៀននូវបទ និងព្យញ្ជនៈទាំងនោះឲ្យចាំល្អ ហើយសួង់មើលក្នុងព្រះ សូត្រ ប្រៀបធៀបមើលក្នុងព្រះវិន័យ ។ បទ និង ព្យញ្ជនៈទាំងនោះ កាលបើអ្នក ទាំងឡាយសួង់មើលក្នុងព្រះសូត្រ ប្រៀបធៀបមើលក្នុងព្រះវិន័យទៅហើយ មិន ប្រជុំចុះក្នុងព្រះសូត្រផង មិនប្រាកដក្នុងព្រះវិន័យផងទេ ។ អ្នកទាំងឡាយគប្បីដល់ នូវសេចក្តីចូលចិត្តក្នុងពាក្យនេះ ។បេ។ ថានេះជាព្រះពុទ្ធដីការបស់ព្រះមានព្រះភាគ នោះ ដែលព្រះថេរៈទាំងនោះ រៀនត្រូវល្អហើយដោយពិត ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយ គប្បីចាំទុកនូវមហាបទេសជាគម្រប់ ៤ នេះចុះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីចាំទុកនូវមហាបទេសទាំង ៤ នេះឯង ។ បានឮថា ព្រះមានព្រះភាគទ្រង់គង់នៅក្នុងអានន្ទចេតិយ ជិតភោគនគរនោះឯងទ្រង់

ធ្វើធម្មីកថាជាច្រើនដល់ភិក្ខុទាំងឡាយយ៉ាងនេះថា សីលដូច្នេះ សមាធិដូច្នេះ បញ្ញាដូច្នេះ សមាធិដែលអប់រំដោយសីលហើយ រមែងមានផលច្រើន មានអានិសង្សច្រើន បញ្ញាដែលអប់រំដោយសមាធិហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ចិត្តដែលអប់រំដោយបញ្ញាហើយ រមែងរួចស្រឡះដោយប្រពៃចាកអាសវៈទាំងឡាយ គឺ កាមាសវៈ ភវាសវៈ អវិជ្ជាសវៈ ។

# អដ្ឋកថា មហាប្រទេសទាំង៤

[ ១១២-១១៦ ] បទថា **មហាបទេសេ** បានដល់ឱកាសធំ គឺការអាងធំ អធិប្បាយថា ហេតុធំដែលលោកពោលអាងអាង ដូចជាព្រះពុទ្ធជាដើម ។

បទថា **អនភិនន្ទិត្វា** គឺដែលបុគ្គលត្រេកអរ ឲ្យសាធុការក្នុងកាលសាប់មុនមិនមាន ។ ពិតហើយ កាលធ្វើយ៉ាងនេះ ខាងក្រោយ ត្រូវធ្លាប់ថា ប្រការនេះមិនសមរម្យក៏ធ្វើហើយបានថា កាលមុន ប្រការនេះជាធម៌ ឥឡូវនេះ មិនជាធម៌ ឈ្មោះថា មិនលះបង់សទ្ទិ ។ បទថា **ន បដិក្កោសិតព្វំ** សេចក្តីថា មិនគប្បីពោលមុនយ៉ាងនេះថា បុគ្គលពាលនេះនិយាយអ្វី ។ កាលត្រូវធ្លាប់ថា នឹងមិនពោលសូម្បីតែពាក្យដែលគួរពោល ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **អនភិនន្ទិត្វា អប្បដិក្កោសិត្វា** ។ បទថា **បទព្យញ្ជនានិ** បានដល់ពព្យញ្ជនៈ ពោលគឺ បទ ។ បទថា **សាធុកំ ឧគ្គហេត្វា** បានដល់ការយកដោយល្អថា លោកពោលបាលីទុកក្នុងទីនេះ ពោលសេចក្តីទុកក្នុងទីនេះ ពោលខាងដើម និងខាងចុងទុកក្នុងទីនេះ ។ បទថា **សុត្តេ ឱតារេតព្វានិ** បានដល់គប្បីសាកសួរក្នុងព្រះ

សូត្រ ។ បទថា **វិនយេ សន្ទស្សេតព្វានិ** បានដល់ផ្ទៀបផ្ទៀបក្នុងព្រះវិន័យ ។ ក្នុងទីនេះ ដែលឈ្មោះថា សូត្រ បានដល់វិន័យ ។ ដូចដែលលោកពោលថា ហាមទុកក្នុងទីណា ហាមទុកក្នុងក្រុងសាវត្ថី ហាមទុកក្នុងសុត្តវិភង្គ ( សុត្តក្នុងទីនេះសំដៅដល់វិន័យ ) ដែលឈ្មោះវិន័យ បានដល់ ខន្ធកៈ ដូចដែលលោកពោលទុកថា **កោសម្ពិយំ វិនយាតិសារេ** ក្នុងរឿងល្មើសព្រះវិន័យ ( វិន័យក្នុងទីនេះសំដៅដល់ខន្ធកៈ ) ក្នុងក្រុងកោសម្ពី ។ កាលបើដូច្នេះ ឈ្មោះថា មិនកាន់យកវិនយបិដក ។ ឈ្មោះថា កាន់យកព្រះវិន័យយ៉ាងនេះ គឺឧភតោវិភង្គ ឈ្មោះថា សុត្ត ខន្ធកៈ បរិវារ ឈ្មោះថា វិន័យ ។ មួយវិញទៀត កាន់យកបិដកទាំង ២ យ៉ាងនេះ គឺសុត្តន្តបិដក ឈ្មោះថា ព្រះសូត្រ ។ វិនយបិដក ឈ្មោះថា វិន័យ ។ មួយវិញទៀត ជាដំបូងមិនកាន់យកបិដកទាំង ៣ ។ សុត្តន្តបិដក និងអភិធម្មបិដក ឈ្មោះថា សូត្រ ។ វិនយបិដក ឈ្មោះថា វិន័យ ។ ធម្មតា ពុទ្ធវចនៈណាមួយ ដែលឈ្មោះថា មិនមែនសូត្រក៏មាន គឺជាតក បដិសម្ភិទា និទ្ទេស សុត្តនិបាត ធម្មបទ ឧទាន ឥតិវុត្តកៈ វិមានវត្ថុ បេតវត្ថុ ថេរគាថា ថេរីគាថា អបទាន ។

ព្រះសុទិន្នត្ថេរ ជំទាស់ពាក្យនេះទាំងអស់ថា ព្រះពុទ្ធវចនៈ ឈ្មោះថា មិនមែនសូត្រមាន ដូច្នេះហើយពោលថា បិដក ៣ ឈ្មោះថា សូត្រ វិន័យ ឈ្មោះថា ហេតុ ។ បន្ទាប់ពីនោះ កាលនឹងសម្ដែងហេតុនោះ ទើបនាំសូត្រនេះមកអាងថា ម្នាលនាងគោតមី នាងគប្បីដឹងនូវធម៌ទាំងឡាយណា ធម៌ទាំងនោះ រមែងប្រព្រឹត្តទៅដើម្បីមានតម្រេក មិនប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេក ប្រព្រឹត្តទៅដើម្បីប្រកបក្នុងទុក្ខ មិនប្រព្រឹត្តទៅដើម្បីប្រាសចាកទុក្ខ ប្រព្រឹត្តទៅដើម្បីសេចក្ដីប្រកាន់ឥ មិនប្រព្រឹត្តទៅ ដើម្បីប្រាសចាកសេចក្ដីប្រកាន់ឥ ប្រព្រឹត្តទៅដើម្បីសេចក្ដីប្រាថ្នាច្រើន មិនប្រព្រឹត្តទៅដើម្បីសេចក្ដីប្រាថ្នាតិច ប្រព្រឹត្តទៅដើម្បីសេចក្ដីមិនសន្ដោស

មិនប្រព្រឹត្តទៅដើម្បីសេចក្ដីស□ទៅស ប្រព្រឹត្តទៅដើម្បីសេចក្ដី□ប្រអូស មិនប្រព្រឹត្តទៅដើម្បីប្រាសពាសេចក្ដី□□ហាម ប្រព្រឹត្តទៅដើម្បីការប្រឡូក□ប្រឡំដោយពួកគណៈ មិនប្រព្រឹត្តទៅដើម្បីសេចក្ដី□□នាកពួក ប្រព្រឹត្តទៅដើម្បីការសន្សំ មិនប្រព្រឹត្តទៅដើម្បីប្រាសចាកការសន្សំ ។ មាតា□នាងគោតមី នាងគប្បីដឹងដោយចំណែកមួយថា នុ៎ះមិនមែនជាធម៌ នុ៎ះមិនមែនជាវិន័យ នុ៎ះមិនមែនជាពាក□ប្រៀនប្រដៅរបស់ព្រះសាសា□ទេ ។ មាតា□គោតមី នាងគប្បីដឹងធម៌ទាំងឡាយណា ធម៌ទាំងនេះ រមែងប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេក មិនប្រព្រឹត្តទៅដើម្បីតម្រេក ប្រព្រឹត្តទៅ ដើម្បីប្រាសចាកការប្រកបក□ទុក□មិនប្រព្រឹត្តទៅដើម្បីការប្រកបក□ទុក□ប្រព្រឹត្តទៅដើម្បីប្រាសចាកសេចក្ដីប្រកានឥ មិនប្រព្រឹត្តទៅដើម្បីមានសេចក្ដី□ប្រកានឥ ប្រព្រឹត្តទៅដើម្បីសេចក្ដីប្រាថា□ច មិនប្រព្រឹត្តទៅដើម្បីសេចក្ដីប្រាថា□ច្រើន ប្រព្រឹត្តទៅដើម្បីសេចក្ដីស□ទៅស មិនប្រព្រឹត្តទៅ ដើម្បីមិនសទៅស ប្រព្រឹត្តទៅដើម្បីប្រាសពាសេចក្ដី□□ហាម មិនប្រព្រឹត្តទៅ ដើម្បីសេចក្ដី□ប្រអូស ប្រព្រឹត្តទៅដើម្បីសេចក្ដី□□នាកពួក មិនប្រព្រឹត្តទៅ ដើម្បីប្រឡូក□ប្រឡំដោយពួក ប្រព្រឹត្តទៅដើម្បីប្រាសចាកការសន្សំ មិនប្រព្រឹត្តទៅ ដើម្បីការសន្សំ ។ មាតា□នាងគោតមី នាងគប្បីដឹងដោយចំណែកមួយថា នុ៎ះជាធម៌ នុ៎ះជាវិន័យ នុ៎ះជាពាក□ប្រៀនប្រដៅរបស់ព្រះសាសា□ហើយ ។ ព្រោះដូចេះ□គប្បីជេញសាកស្សួរក□ព្រះ□ត្រៃបិដក ពុទ□ចនៈ ដែលឈ្មោះថា សូត្រ គប្បីប្រៀបធៀបក□ធាតុ គឺវិន័យ មានរាគៈជាដើម ដែលឈ្មោះថា វិន័យ សេចក្ដី□□ប្រការនេះ មានដូចពោលមកដូចេះ□ ។

បទថា **ន ចេវ សុត្តេ ឱតរន្តិ** សេចក្ដី□ា បទព□្ញនៈទាំងនោះ មិនមកក□ុ

ណាមួយ តាមលំដាប់សូត្រ វៀរលែងតែខាងមកអំពីគុម្ពវេស្សន្តរ គុម្ពឧម្មគ្គៈ គុម្ពវិន័យ វេទល្លៈ និងបិដកនៅមានប្រាកដ ។ ពិតហើយ បទ ៣ ប្រការនេះដែលមក យ៉ាងនេះ តែមិនប្រាកដក្នុងការកម្ចាត់កិលេស មានរាគៈជាដើម ក៏គប្បីចោល ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ភិក្ខុទាំងឡាយ ដូចនេះ អ្នកគប្បី លះបង់សេចក្តីនោះចេញ ។ គប្បីជ្រាបសេចក្តីក្នុងទីគ្រប់នៃដោយយ៉ាងនេះ ។ បទថា **ឥធំ ភិក្ខវេ ចតុត្ថំ មហាបទេសំ ធារេយ្យាថ** សេចក្តីថា អ្នកគប្បីទ្រទ្រង់នាំ នូវឱកាសជាទីប្រតិស្ឋាននៃធម៌ទាំង ៤ នេះ ។

ក្នុងទីនេះគប្បីជ្រាបបកិណ្ណកៈដូចតទៅ ក្នុងព្រះសូត្រ មានមហាបទេស ៤ ក្នុងខន្ធកៈ មានមហាបទេស ៤ បញ្ហាពិសេសការណ៍ ៤ សុត្តៈ ១ សុត្តានុលោម ១ អាចរិយវាទ ១ អត្តនោមតិ ១ សង្គីតិ ៣ ។

ក្នុងបកិណ្ណកៈទាំងនោះ កាលដល់ការវិនិច្ឆ័យធម៌ថា នេះធម៌ នេះវិន័យ មហាបទេសទាំង ៤ នេះការនាំមកជាប្រមាណ សេចក្តីណាសមក្នុងមហាបទេសទាំង ៤ នេះ សេចក្តីនោះគួរការនាំមក សេចក្តីក្រៅពីនេះ របស់អ្នកនោះខុស មិនគួរ ការនាំមក ។ កាលដល់ការវិនិច្ឆ័យសេចក្តីដែលគួរ និងមិនគួរថា វត្ថុនេះគួរ វត្ថុនេះ មិនគួរ មហាបទេស ៤ ដែលត្រាស់ក្នុងខន្ធកៈដោយន័យថា

ម្នាលភិក្ខុទាំងឡាយ របស់ណាដែលតថាគតមិនបានហាមថា របស់នេះមិន គួរទេ បើរបស់នោះអនុលោមចូលរបស់មិនគួរ ឃាត់របស់គួរ របស់នោះមិនគួរ ដល់អ្នកទាំងឡាយឡើយ ដូចនេះជាដើម ការនាំមកជាប្រមាណ ។ កថាវិនិច្ឆ័យ មហា បទេសទាំងនោះ ពោលទុកក្នុងអដ្ឋកថាព្រះវិន័យ ឈ្មោះថា សមន្តបាសាទិកា ដោយន័យដែលពោលទុកក្នុងទីនោះ គប្បីជ្រើសរើសនិងយ៉ាងនេះថា វត្ថុណាដែល

ចូលគាប់ជាមួយនឹងវត្ថុដែលគួរ វត្ថុនោះគួរ ក្រៅពីនោះមិនគួរ ។

ឯកំសព្យាករណីយបញ្ហា ១ វិភជ្ជព្យាករណីយបញ្ហា ១ បដិបុច្ឆាព្យាករណីយបញ្ហា ១ ឋបនីយបញ្ហា ១ ទាំងនេះ ឈ្មោះថា បញ្ហាព្យាករណ៍ ៤ ។ ក្នុងបញ្ហាព្យាករណ៍ ៤ នោះ ត្រូវគេសួរថា ចក្ខុមិនទៀងឬ គប្បីព្យាករមុនដោយចំណែកតែមួយថា ករុណា មិនទៀង ។ ក្នុងសោតៈជាដើម ក៏មានន័យនេះ ។ នេះ ឈ្មោះថា ឯកំសព្យាករណីយបញ្ហា ។ ត្រូវគេសួរថា ចក្ខុ ឈ្មោះថា មិនទៀង ឬ គប្បីចែក ហើយព្យាករយ៉ាងនេះថា មិនមែនចក្ខុប៉ុណ្ណោះ សូម្បីតែសោតៈក៏មិនទៀង សូម្បីឃានៈ ក៏មិនទៀង ។ នេះឈ្មោះថា វិភជ្ជព្យាករណីយបញ្ហា ។ ត្រូវគេសួរថា ចក្ខុយ៉ាងណា សោតៈក៏យ៉ាងនោះ សោតៈយ៉ាងណា ចក្ខុក៏យ៉ាងនោះ ឬ ដូច្នេះជាដើម ។ ទើបសាកសួរថា លោកសួរ ដោយអត្ថដូចម្តេច កាលគេឆ្លើយថា សួរដោយអត្ថថា ឃើញ ទើបព្យាករថា មិនមែន ។ កាលគេឆ្លើយថា សួរដោយអត្ថថា មិនទៀង ទើបព្យាករថា មែន ។ នេះឈ្មោះថា បដិបុច្ឆាព្យាករណីយបញ្ហា ។ តែត្រូវគេសួរថា ជីវៈនោះ សរីរៈនោះ ឬ ជាដើម គប្បីឃាត់ដោយពោលថា សេចក្ដីនេះព្រះមានព្រះភាគមិនព្យាករ ។ បញ្ហានេះមិនគប្បីព្យាករ ។ នេះឈ្មោះថា ឋបនីយបញ្ហា ។ ដូច្នោះ កាលបញ្ហាមកដល់ដោយអាការនោះ បញ្ហាព្យាករណ៍ទាំង ៤ នេះ កាន់យកជាប្រមាណបាន ។ គប្បីព្យាករបញ្ហានោះ ដោយអំណាចបញ្ហាព្យាករណ៍ ៤ នេះ ។

បិដក ៣ ដែលលើកឡើងកាន់សង្គីតិ ៣ ឈ្មោះថា សុត្តៈ ក្នុងបកិណ្ណកៈ មានសុត្តៈជាដើម ។ សេចក្ដីដែលចូលគាប់ បានជាមួយកប្បិយៈ ឈ្មោះថា សុត្តានុលោម ។ អដ្ឋកថា ឈ្មោះថា អាចរិយវាទ ។ បដិភាណរបស់ខ្លួន តាមការ

គិតគេ□ឈ្មោះថា អត□មតិ ។ ក□កិណ□ទាំងនោះ សុត□បុគ្គលណា ជំទាស□មិនបាន កាលជំទាសសុត□នោះ ក៏ស្មើនឹងជំទាសព្រះពុទ្ធ□ ។ ចំណែក សេចក្តី□លចូលជាមួយនឹងកប្បិយៈបាន គួរកាន់យកចំពោះសេចក្តី□លសម នឹងសុត□ណោ□ ក្រៅពីនោះមិនគួរកាន់យក ។ សូម្បីអាចរិយវាទ ក៏គួរកាន់យក តែសេចក្តី□លសមនឹងសុត□ណោ□ ក្រៅអំពីនោះមិនគួរកាន់យក ។ ចំណែក អត□មតិ អនផាំងគេទាំងអស់ ។ សូម្បីអត□មតិនោះ ក៏គួរកាន់យកតែសេចក្តី□ ដែលសមនឹងសុត□ណោ□ក្រៅពីនោះមិនគួរកាន់យក ។

សង្គីតិមាន ៣ គឺ បញ្ចសតិកសង្គីតិ ( សង្គាយនាលើកទី ១ ) សត្ត-សតិកសង្គីតិ ( លើកទី ២ ) សហស្សិកសង្គីតិ ( លើកទី ៣ ) ។ សូម្បីសុត្តៈ ដែលមកក□សង្គីតិ ៣ នោះ គួរកាន់យកជាប្រមាណ ។ ក្រៅពីនោះ ជាការ ដែលលោកតិះដៀល មិនគួរកាន់យក ។ ពិតហើយ ព□នៈ គឺ បទ ដែលចូល គា□នក□សុត□នោះ គប្បីជ្រាបថា ចូលគា□មិនបានក□ព្រះសូត្រ និងប្រៀបធៀប គា□មិនបានក□ព្រះវិន័យ ។

( ចាកមហាបរិនិព្វានសូត្រ បិដក ១៦ )

# សីហសូត្រទី ៩

[ ៩៩ ] ម្នាលភិក្ខុទាំងឡាយ សត្វសីហៈជាស្តេចម្រឹគ តែងចេញអំពីទីអាស្រ័យក្នុងសម័យរសៀល លុះចេញពីទីអាស្រ័យហើយ ក៏ម្រឹតពត់ខ្លួន លុះម្រឹតពត់ខ្លួនរួចហើយ ក៏ក្រឡេកមៀងមើលទិសទាំង ៤ ជុំវិញ លុះក្រឡេកមៀងមើលទៅទិសទាំង ៤ ជុំវិញខ្លួនហើយ ក៏បន្លឺសីហនាទ ៣ ដង លុះបន្លឺសីហនាទ ៣ ដងរួចហើយ ក៏ដើរចេញទៅស្វែងរកចំណី ។ សត្វសីហៈនោះ កាលបើប្រហារដំរី ក៏ប្រហារយ៉ាងប្រយ័ត្ន មិនមែនប្រហារខ្ជីខ្ជាទេ បើប្រហារក្របី ក៏ប្រហារយ៉ាងប្រយ័ត្ន មិនមែនប្រហារខ្ជីខ្ជាទេ បើប្រហារគោ ក៏ប្រហារយ៉ាងប្រយ័ត្ន មិនមែនប្រហារខ្ជីខ្ជាទេ បើប្រហារខ្លាដំបង ក៏ប្រហារយ៉ាងប្រយ័ត្ន មិនមែនប្រហារខ្ជីខ្ជាទេ បើប្រហារពួកសត្វតូចៗ ដូចទន្សាយ និងឆ្មាជាទីបំផុត ក៏ប្រហារយ៉ាងប្រយ័ត្ន មិនមែនប្រហារខ្ជីខ្ជាទេ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះសត្វសីហៈគិតថា ផ្លូវព្យាយាមរបស់អញ ចូរកុំវិនាសឡើយ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ពាក្យថាសត្វសីហៈនេះ ជាឈ្មោះរបស់ព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគត សម្តែងធម៌ចំពោះបរិស័ទដោយពាក្យណា នេះជាសីហនាទរបស់ព្រះតថាគតនោះ ម្នាលភិក្ខុទាំងឡាយ បើតថាគតសម្តែងធម៌ចំពោះពួកភិក្ខុ តថាគតតែងសម្តែងធម៌ដោយប្រយ័ត្នណាស់ មិនមែនសម្តែងទាំងខ្ជីខ្ជាទេ ម្នាលភិក្ខុទាំងឡាយ បើតថាគតសម្តែងធម៌ចំពោះពួកភិក្ខុនី ក៏តថាគតតែងសម្តែងធម៌ដោយប្រយ័ត្នណាស់ មិនមែនសម្តែងទាំងខ្ជីខ្ជាទេ ម្នាលភិក្ខុទាំងឡាយ បើតថាគតសម្តែងធម៌ចំពោះពួកឧបាសក ក៏តថាគតតែងសម្តែងធម៌ដោយប្រយ័ត្នណាស់ មិនមែនសម្តែងទាំងខ្ជីខ្ជាទេ ម្នាលភិក្ខុទាំងឡាយ បើតថាគតសម្តែងធម៌ចំពោះពួក

ឧបាសិកា ក៏តថាគតតែងសម្តែងធម៌ដោយប្រយ័ត្នណាស់ មិនមែនសម្តែងទាំងវិឃ្នាទេ ម្នាលភិក្ខុទាំងឡាយ បើតថាគតសម្តែងធម៌ចំពោះពួកបុថុជ្ជន ដោយហោចទៅ សូម្បីពួកអ្នកនាំបាយ និងពួកអ្នកនេសាទ ក៏តថាគតតែងសម្តែងធម៌ដោយប្រយ័ត្នណាស់ មិនមែនសម្តែងទាំងវិឃ្នាទេ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះតថាគត មានធម៌ជាទីគោរព ជាអ្នកគោរពធម៌ ។

( បាលីប្រែ ៤៤-២៥០ )

# អដ្ឋកថា សីហសូត្រ

[ ៩៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសីហសូត្រទី ៩ ដូចតទៅនេះ បទថា **សក្កច្ចញ្ញេវ បហារំ ទេតិ នោ អសក្កច្ចំ** សេចក្តីថា មិនឲ្យភ្លាំងភ្លាត់ដោយមិនខ្ជីខ្ជា ។ បទថា **មា មេ យោគ្គបថោ ឆស្ស** សេចក្តីថា ថ្វីដៃ ចាប់សត្វដែលអញជំនាញហើយ របស់អញ ចូរកុំសាបសូន្យទៅឡើយ ។ អធិប្បាយថា មនុស្សទាំងឡាយចូរកុំពោលយ៉ាងនេះថា សីហមិគរាជ ១ កាលក្រោកឡើងចាប់នូវសត្វឆ្មា ក៏ចាប់មិនបាន ដូច្នេះ ។ ក្នុងបទថា **អន្នភារនេសាទានំ** នេះ បាយដំណើប ហៅថា **អន្ន** បាយដំណើបនោះជារបស់ចាំបាច់សម្រាប់មនុស្សទាំងនោះ ព្រោះហេតុនោះ ទើបមនុស្សទាំងនោះ ឈ្មោះថា **អន្នភារា** ពាក្យនោះ ជាឈ្មោះរបស់អ្នកសុំទាន ។ ព្រានបក្សី ហៅថា **នេសាទ** ។ ព្រះតថាគតទ្រង់សម្តែងយ៉ាងធ្ងន់ ដល់អ្នកសុំទាន ឬ ព្រានបក្សីទាំងនោះ ដោយហោច បុគ្គលដែលទាបជាងគេបង្អស់ ដោយប្រការដូច្នេះ ៕

អដ្ឋកថា សីហសូត្រទី ៩ ចប់

# សូត្រទី ១០

[ ២៨៦ ] ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណា ហាមឃាត់អដ្ឋកថាផង បាលីផង ដោយសូត្រទាំងឡាយដែលខ្លួនរៀនខុស តែសមរម្យតាមព្យញ្ជនៈ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ ឈ្មោះថា ប្រតិបត្តិដើម្បីមិនជាប្រយោជន៍ដល់ជនច្រើន ដើម្បីមិនបានសេចក្តីសុខដល់ជនច្រើន ដើម្បីមិនចម្រើនដល់ជនច្រើន ដើម្បីមិនជាប្រយោជន៍ ទាំងបានសេចក្តីទុក្ខដល់ទេវតា និងមនុស្សទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ តែងបាននូវបាបច្រើន មិនតែប៉ុណ្ណោះ ភិក្ខុទាំងនោះ ឈ្មោះថា ធ្វើព្រះសទ្ធម្ម គឺសាសនានេះឲ្យអន្តរធានទៅផង ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណា ប្រព្រឹត្តតាមអដ្ឋកថាផង បាលីផង ដោយសូត្រទាំងឡាយដែលខ្លួនរៀនត្រឹមត្រូវ សមរម្យតាមព្យញ្ជនៈ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ ឈ្មោះថា ប្រតិបត្តិដើម្បីជាប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីសេចក្តីចម្រើនដល់ជនច្រើន ដើម្បីជាប្រយោជន៍ ទាំងបានសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ តែងបាននូវបុណ្យច្រើន មិនតែប៉ុណ្ណោះ ភិក្ខុទាំងនោះ ឈ្មោះថា ធ្វើព្រះសទ្ធម្មនេះឲ្យឋិតថេរបានផង ។

( បិដក ៤០-ទំព័រ ១៥៥ )

# អដ្ឋកថា សូត្រទី ១០

[ ២៨៦ ] ក្នុងសូត្រទី ១០ មានវិនិច្ឆ័យដូចតទៅនេះ បទថា **ទុគ្គហិតេហិ** បានដល់ ដែលប្រកាន់មកខុសរបៀប ។ បទថា **ព្យញ្ជនបដិរូបកេហិ** បានដល់ មានព្យញ្ជនៈល្អ គឺបានមកដោយអក្ខរៈវិចិត្រ ។ បទថា **អត្ថញ្ច ធម្មញ្ច បដិពាហន្តិ** សេចក្ដីថា រមែងជំទាស់ទាំងអដ្ឋកថា និង បាលីនៃសុត្តន្ដៈទាំងឡាយដែលកាន់យកមកត្រឹមត្រូវ ។ ភិក្ខុទាំងនោះ សម្ដែងអត្ថផង បាលីផង របស់សុត្តន្ដៈដែលខ្ទនកាន់មកខុសក្រៃលែងជាង ។ ក្នុងធម៌ចំណែកស គប្បីជ្រាបផ្ទុយគ្នា តាមដែលពោលហើយ ។ ក្នុងសូត្រនេះ ត្រាស់ទាំងសេចក្ដីចម្រើន និងសេចក្ដីវិនាសនៃព្រះសាសនានោះឯង ។៚

អដ្ឋកថា សូត្រទី ១០ ចប់

# សូត្រទី ១០

( សេចក្ដីសាបសូន្យនៃព្រះសទ្ធម្ម )

[ ២៦៦ ] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ២ ប្រការនេះ តែងប្រព្រឹត្តទៅដើម្បីសេចក្ដីភាំងភ្លាត់ ដើម្បីសេចក្ដីសាបសូន្យនៃព្រះសទ្ធម្ម ។ ធម៌ ២ ប្រការ តើដូចម្ដេច ។ គឺ បទ និងព្យញ្ជនៈដែលអាចារ្យតម្កល់ទុកខុស ១ សេចក្ដីដែលអាចារ្យនាំមកខុស ១ ។ ម្នាលភិក្ខុទាំងឡាយ បើបទ និងព្យញ្ជនៈដែលអាចារ្យតម្កល់ទុកខុសហើយ រូបសេចក្ដីដែលអាចារ្យនាំមក ក៏ខុសដែរ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ២ ប្រការនេះ តែងប្រព្រឹត្តទៅដើម្បីសេចក្ដីភាំងភ្លាត់ ដើម្បីសេចក្ដីសាបសូន្យនៃព្រះសទ្ធម្ម ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ២ ប្រការនេះ តែងប្រព្រឹត្តទៅ ដើម្បីឋិតថេរ មិនភាំងភ្លាត់ មិនសាបសូន្យនៃព្រះសទ្ធម្ម ។ ធម៌ ២ ប្រការ តើដូចម្ដេច ។ គឺ បទ និងព្យញ្ជនៈដែលអាចារ្យតម្កល់ទុកត្រូវ ១ សេចក្ដីដែលអាចារ្យនាំមកត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ បើបទ និងព្យញ្ជនៈដែលអាចារ្យតម្កល់ទុកត្រូវហើយ សូម្បីរូបសេចក្ដីដែលអាចារ្យនាំមកក៏ត្រូវដែរ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ២ ប្រការនេះ តែងប្រព្រឹត្តទៅដើម្បីឋិតថេរ មិនភាំងភ្លាត់ មិនសាបសូន្យនៃព្រះសទ្ធម្មឡើយ ។

( បិដក៤០ ទំព័រ១៣០ - អធិករណវគ្គទី ២ )

# អដ្ឋកថាសូត្រទី ១០

[ ២៦៦ ] ក្នុងសូត្រទី ១០ មានវិនិច្ឆ័យដូចតទៅនេះ បទថា **ទុន្និក្ខិត្តញ្ច បទព្យញ្ជនំ** បានដល់ បាលីដែលរៀបរៀងខុសលំដាប់ បទនោះឯង ហៅថា ព្យញ្ជនៈ ព្រោះជាទីប្រាកដច្បាស់នៃអត្ថ ។ បទ និងព្យញ្ជនៈទាំង ២ នោះ ជាឈ្មោះរបស់បាលីនោះឯង ។ បទថា **អត្ថោ ច ទុន្នីតោ** សេចក្ដីថា អដ្ឋកថានៃបាលីដែលប្រែខុសលំដាប់ ។ បទថា **ទុន្និក្ខិត្តស្ស ភិក្ខវេ បទព្យញ្ជនស្ស អត្ថោបិ ទុន្នយោ ហោតិ** សេចក្ដីថា អដ្ឋកថារបស់បាលីដែលប្រែខុសលំដាប់ ឈ្មោះថា នាំមកមិនល្អ ធ្វើមិនល្អ ។ល។

អដ្ឋកថា សូត្រទី ១០ ចប់

# ពាលវគ្គទី៣ សូត្រទី៤

*( ការពោលបង្កាច់ព្រះតថាគត )*

*[ ២៦៨ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ២ ពួកនេះ តែងពោលបង្កាច់ព្រះតថាគត ។ បុគ្គល ២ ពួក តើដូចម្ដេច ។ គឺ បុគ្គលជាអ្នកក្រោធ មានទោសចិត្តនៅខាងក្នុង ១ បុគ្គលជាអ្នកជឿដោយប្រកាន់ខុស ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ២ ពួកនេះ តែងពោលបង្កាច់ព្រះតថាគត ។*

*[ ២៦៩ ] ម្នាលភិក្ខុទាំងឡាយបុគ្គល ២ ពួកនេះ តែងពោលបង្កាច់ព្រះតថាគត ។ បុគ្គល ២ ពួក តើដូចម្ដេច ។ គឺ បុគ្គលសម្ដែងនូវពាក្យដែលព្រះតថាគត មិនបានសម្ដែង មិនបានពោល ថាជាពាក្យដែលព្រះតថាគតបានសម្ដែង បានពោល ១ បុគ្គលសម្ដែងនូវពាក្យដែលព្រះតថាគតបានសម្ដែង បានពោល ថាជាពាក្យដែលព្រះតថាគត មិនបានសម្ដែង មិនបានពោល ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ២ ពួកនេះ តែងពោលបង្កាច់ព្រះតថាគត ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ២ ពួកនេះ មិនពោលបង្កាច់ព្រះតថាគតទេ ។ បុគ្គល ២ ពួក តើដូចម្ដេច ។ គឺបុគ្គលសម្ដែងនូវពាក្យដែលព្រះតថាគត មិនបានសម្ដែង មិនបានពោល ថាជាពាក្យដែលព្រះតថាគត មិនបានសម្ដែង មិនបានពោល ១ បុគ្គលសម្ដែងនូវពាក្យដែលព្រះតថាគត បានសម្ដែង បានពោល ថាជាពាក្យដែលព្រះតថាគត បានសម្ដែង បានពោល ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ២ ពួកនេះឯង មិនពោលបង្កាច់ព្រះតថាគតឡើយ ។*

*[ ២៧០ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ២ ពួកនេះ តែងពោលបង្កាច់ ព្រះ*

តថាគត ។ បុគ្គលទាំង ២ ពួក តើដូចម្តេច ។ គឺបុគ្គលដែលសម្តែងសូត្រមានសេចក្តីជាបុគ្គលាធិដ្ឋាន ថាជាសូត្រមានសេចក្តីជាធម្មាធិដ្ឋានទៅវិញ ១ ដែលសម្តែងសូត្រមានសេចក្តីជា ធម្មាធិដ្ឋាន ថាជាសូត្រមានសេចក្តីជា បុគ្គលាធិដ្ឋានទៅវិញ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ២ ពួក នេះ តែងពោលបង្កាច់ព្រះតថាគត ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ២ ពួកនេះ មិនពោលបង្កាច់ព្រះតថាគតទេ ។ បុគ្គល ២ ពួក តើដូចម្តេច ។ គឺ បុគ្គលសម្តែងសូត្រមានសេចក្តីជាបុគ្គលាធិដ្ឋាន ថាជាសូត្រមានសេចក្តីជា បុគ្គលាធិដ្ឋាន ១ បុគ្គលសម្តែងសូត្រមានសេចក្តីជា ធម្មាធិដ្ឋាន ថាជាសូត្រមានសេចក្តីជា ធម្មាធិដ្ឋាន ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ២ ពួកនេះ មិនពោលបង្កាច់ព្រះតថាគតឡើយ ។

( បិដក៤០ ទំព័រ១៣២ ពាលវគ្គទី ៣ )

# អដ្ឋកថា សូត្រទី ៤

[ ២៧០ ] ក្នុងសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ បទថា **នេយ្យត្ថំ សុត្តន្តំ** សេចក្ដីថា សុត្តន្តៈណាមានអត្ថគួរណែនាំ ។ នូវសុត្តន្តៈដែលមានអត្ថគួរណែនាំនោះ ។ បទថា **នីតត្ថោ សុត្តន្តោតិ ទីបេតិ** សេចក្ដីថា កាលពោលថា សុត្តន្តៈនេះមានអត្ថបានពោលហើយ ក្នុងបាលីប្រភេទនោះ សុត្តន្តៈបែបនេះថា ម្នាលភិក្ខុទាំងឡាយ បុគ្គលពួក ១ បុគ្គលពួក ២ បុគ្គលពួក ៣ បុគ្គលពួក ៤ ដូច្នេះឈ្មោះថា មានអត្ថគួរណែនាំ ។ ក្នុងទីនេះ សូម្បីព្រះសម្មាសម្ពុទ្ធត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលពួក ១ ដូច្នេះជាដើមក៏ពិត តែបើពោលដោយបរមត្ថបុគ្គលមិនមាន គួរណែនាំអត្ថដល់បុគ្គលយ៉ាងនេះ ដោយប្រការដូច្នេះឯង ។ តែបុគ្គលល្ងង់ខ្លៅសម្គាល់ថា សុត្តន្តៈមានអត្ថណែនាំហើយ ។ ព្រោះថា ប្រសិនបើបុគ្គលមិនមានដោយបរមត្ថហើយ ព្រះតថាគតក៏មិនគប្បីត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលពួក ១ ដូច្នេះជាដើម ។ តែព្រោះព្រះអង្គត្រាស់យ៉ាងនោះ ដូច្នោះទើបកាន់យកថា បុគ្គលមានដោយបរមត្ថ ឈ្មោះថា សម្គាល់នូវសុត្តន្តៈដែលមានអត្ថគួរណែនាំថាជា សុត្តន្តៈមានអត្ថណែនាំហើយ ។ បទថា **នីតត្ថំ** បានដល់មានអត្ថដែលត្រាស់យ៉ាងនេះថា **អនិច្ចំ ទុក្ខំ អនត្តា** ក្នុងទីនេះ មានអត្ថជាក់ច្បាស់ហើយថា មិនទៀង ជាទុក្ខ មិនមែនតួខ្លួន តែបុគ្គលល្ងង់ខ្លៅគិតថា នៅមានសុត្តន្តៈដែលមានអត្ថគួរណែនាំ អញ្ជើញនាំអត្ថនៃសុត្តន្តៈនោះមក កាន់យកថា ទៀង ជាសុខ ជាតួខ្លួនក៏មាន ដូច្នេះ ឈ្មោះថា រមែងសម្គាល់សុត្តន្តៈមានអត្ថណែនាំស្រេចហើយថាជា សុត្តន្តៈមានអត្ថគួរណែនាំ ។៚

អដ្ឋកថា សូត្រទី ៤ ចប់

# ពហុការសូត្រទី៤

( គ្រូអាចារ្យអ្នកមានឧបការៈច្រើន ៣ ពួក )

[ ២៤ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល( ជាអាចារ្យ ) មាន ៣ ពួក នេះ មានឧបការៈច្រើនដល់បុគ្គល( ជាសិស្ស ) ។ បុគ្គល ៣ ពួក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដល់នូវព្រះពុទ្ធជាទីពឹង ដល់នូវព្រះធម៌ជាទីពឹង ដល់នូវព្រះសង្ឃជាទីពឹង ព្រោះអាស្រ័យបុគ្គលណា ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះឈ្មោះថា មានឧបការៈច្រើនដល់បុគ្គលនេះ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលដឹងច្បាស់តាមពិតថា នេះជាទុក្ខ ដឹងច្បាស់តាមពិតថា នេះជាទីកើតឡើងនៃទុក្ខ ដឹងច្បាស់តាមពិតថា នេះជាសេចក្តីរលត់ទៅនៃទុក្ខ ដឹងច្បាស់តាមពិតថា នេះបដិបទាជាដំណើរទៅកាន់ទីរម្ងត់ទុក្ខ ព្រោះអាស្រ័យបុគ្គលណា ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះហៅថា មានឧបការៈច្រើនដល់បុគ្គលនេះ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលបានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ននេះ សម្រេចសម្រាន្តនៅ ព្រោះអាស្រ័យបុគ្គលណា ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះឈ្មោះថា មានឧបការៈច្រើនដល់បុគ្គលនេះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះ ឈ្មោះថា មានឧបការៈច្រើនដល់បុគ្គល ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត តថាគតពោលថា បុគ្គលឯទៀត មានឧបការៈច្រើនដល់បុគ្គលនេះ លើសជាងបុគ្គលទាំង ៣ ពួកនេះទៅទៀត មិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត តថាគតពោលថា បុគ្គលនេះមិនងាយនឹងតបគុណដល់បុគ្គលទាំង ៣ ពួកនេះ ដោយការថ្វាយបង្គំ ការក្រោកទទួល ការធ្វើ

អញ្ជលិកម្ម សាមីចិកម្ម និងការប្រគេនចីវរ បិណ្ឌបាត សេនាសនៈ និងគ្រឿងបរិក្ខារជាបច្ច័យដល់អ្នកជំងឺបានទេ ។

( បាលីប្រែ ៤១ ទំព័រ ៥២ , បិ-អ ២៦-៥៥៩ )

## អដ្ឋកថា

## ពហុការសូត្រទី ៤

[ ២៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងពហុការសូត្រទី ៤ ដូចតទៅនេះ បទថា **តយោមេ ភិក្ខវេ បុគ្គលា** បានដល់ បុគ្គលដែលជាអាចារ្យ ៣ ពួក ។ បទថា **បុគ្គលស្ស ពហុការា** បានដល់ មានឧបការៈច្រើនដល់បុគ្គលជាអន្តេវាសិក ។ បទថា **ពុទ្ធំ** បានដល់ ព្រះសព្វញ្ញុពុទ្ធ ។ បទថា **សរណំ គតោ ហោតិ** សេចក្ដីថា ដល់នូវព្រះពុទ្ធជាទីពឹង ។ បទថា **ធម្មំ** បានដល់ នវលោកុត្តរធម៌ព្រមទាំងបែបផែន គឺ ព្រះបរិយត្តិធម៌ ។ បទថា **សង្ឃំ** បានដល់ ប្រជុំព្រះអរិយបុគ្គល ៨ ពួក ។

ការដល់សរណៈនេះ ព្រះមានព្រះភាគត្រាស់ទុក ដោយអំណាចនៃបុគ្គលដែលមិនធ្លាប់ដល់សរណៈ គឺ ដែលមិនធ្លាប់ធ្វើនូវការជឿមាំ ។ ឈ្មោះថាអាចារ្យ ៣ ពួក គឺជាអ្នកឲ្យសរណៈ ១ អ្នកឲ្យដល់សោតាបត្តិមគ្គ ១ អ្នកឲ្យដល់អរហត្តមគ្គ ១ មកហើយក្នុងសូត្រនេះថា មានឧបការៈច្រើន ។ អាចារ្យ

៥ ពួក គឺអាចារ្យអ្នកឲ្យបព្វជ្ជា ១ អាចារ្យអ្នកឲ្យពុទ្ធវចនៈ ១ កម្មវាចាចរិយៈ ១ អាចារ្យអ្នកឲ្យសម្រេចសកទាគាមិមគ្គ ១ អាចារ្យអ្នកឲ្យសម្រេចអនាគាមិមគ្គ ១ មិនបានមកក្នុងសូត្រនេះឡើយ ។

សួរថា អាចារ្យទាំងនេះ មិនមានឧបការៈច្រើនឬ ។ ឆ្លើយថា មិនមែនមិនមានឧបការៈច្រើនទេ តែព្រះធម្មទេសនានេះកំណត់ ២ ចំណែក ព្រោះដូច្នោះ អាចារ្យទាំងនេះ ឈ្មោះថា មានឧបការៈច្រើន ។ ក្នុងបណ្ដាគុណធម៌ទាំងនោះ បុគ្គលមិនបានធ្វើអភិនិវេស រមែងសមគួរក្នុងការដល់សរណគមន៍ប៉ុណ្ណោះ ។ ចំណែកចតុប្បារិសុទ្ធិសីល កសិណបរិកម្ម និងវិបស្សនាញាណ មានគុណធម៌ដែលអាស្រ័យបឋមមគ្គ ។ មគ្គ និងផលខាងលើទាំង ២ យ៉ាង គប្បីជ្រាបថា អាស្រ័យអរហត្តមគ្គ ។

បទថា **ឥមិនា បុគ្គលេន** បានដល់ បុគ្គលដែលជាអន្តេវាសិក ។ បទថា **ន សុប្បដិការំ វទាមិ** សេចក្ដីថា តថាគតពោលការធ្វើនូវការតបស្នងថា មិនមែនជារបស់ដែលធ្វើបានងាយ ។ គប្បីជ្រាបអធិប្បាយយ៉ាងនេះថា ពិតហើយ បណ្ដាអភិវាទនកម្មជាដើម អន្តេវាសិកកាលក្រាបចុះថ្វាយបង្គំ ដោយបញ្ចង្គប្រតិស្ឋាន រាប់រយដង រាប់ពាន់ដង ក្រោកចាកអាសនៈទៅទទួលអាចារ្យ ក្នុងខណៈដែលឃើញគ្រប់គ្រា ប្រណម្យដៃធ្វើសាមីចិកម្មដ៏សមគួរ ប្រគេនចីវរ ១០០ ផ្ទាំង ១០០០ ផ្ទាំង ប្រគេនបិណ្ឌបាត ១០០ ជង ១០០០ ជង រាល់ថ្ងៃ សាងលំនៅវិចិត្រដោយកែវ ៧ ប្រការ ដោយមានចក្រវាលជាព្រំដែន ប្រគេនភេសជ្ជៈច្រើន

ប្រការ មានសប្បិ នវនីតជាដើមជាប្រចាំ ឈ្មោះថា មិនអាចធ្វើការតបស្នង ចំពោះឧបការៈដែលអាចារ្យធ្វើហើយ ឲ្យអស់ទៅបានឡើយ ។៙

អដ្ឋកថា ពហុការសូត្រទី ៤ ចប់

# រឿង ព្រះសារីបុត្តត្ថេរ

*ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះសារីបុត្តត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា* **យម្ហា ធម្មំ វិជានេយ្យ** *ជាដើម ។*

*បានឮថា ព្រះសារីបុត្តនោះ ចាប់តាំងពីកាលដែលលោកស្តាប់ធម៌ ក្នុងសម្នាក់របស់ព្រះអស្សជិត្ថេរ ហើយសម្រេចសោតាបត្តិផល ។ កាលព្រះអស្សជិត្ថេរនៅក្នុងទិសណា ក៏ផ្គងអញ្ជលីទៅក្នុងទិសនោះ សិងបែរក្បាលទៅកាន់ទិសនោះឯង ។*

*ភិក្ខុទាំងឡាយពោលថា ព្រះសារីបុត្តជាមិច្ឆាទិដ្ឋិ សូម្បីថ្ងៃនេះក៏នៅតែសិងនមស្ការទិសទាំងឡាយ ដូច្នេះហើយ ក្រាបទូលសេចក្តីនោះដល់ព្រះដ៏មានព្រះភាគ ។*

*ព្រះសាស្តាត្រាស់ឲ្យហៅព្រះថេរៈមកហើយ ត្រាស់សួរថា ម្នាលសារីបុត្តបានឮថា អ្នកដេកនមស្ការទិសទាំងឡាយ ពិតឬ កាលព្រះថេរៈក្រាបទូលថា បពិត្រព្រះអង្គ ទ្រង់ប៉ុណ្ណោះ រមែងជ្រាបនូវការគោរពទិស ឬមិនគោរពទិសទាំង-ឡាយរបស់ខ្ញុំព្រះអង្គ ដូច្នេះហើយទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សារីបុត្តមិនមែនគោរពទិសទាំងឡាយទេ តែព្រោះសារីបុត្តបានស្តាប់ធម៌អំពីសម្នាក់របស់អស្សជិ ហើយសម្រេចសោតាបត្តិផល ទើបដេកគោរពអាចារ្យរបស់ខ្លួន ព្រោះថាភិក្ខុអាស្រ័យអាចារ្យណាត្រាស់ដឹងធម៌ ភិក្ខុនោះ គប្បីនមស្ការអាចារ្យនោះដោយគោរព ដូចព្រាហ្មណ៍នមស្ការភ្លើងដូច្នោះ ដូច្នេះហើយ កាលទ្រង់សម្តែងធម៌ទើបត្រាស់ព្រះគាថានេះថា*

**យម្ហា ធម្មំ វិជានេយ្យ សម្មាសម្ពុទ្ធទេសិតំ**

**សក្កច្ចំ តំ នមស្សេយ្យ អគ្គិហុត្តំវ ព្រាហ្មណោ ។**

*បុគ្គលចេះធម៌អាថ៌ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់សម្ដែងហើយ អំពីសម្នាក់គ្រូណា គប្បីនមស្ការគ្រូនោះ ដោយគោរព ដូចព្រាហ្មណ៍ដែលគោរពការបូជាភ្លើងដូច្នោះដែរ ។*

## សេចក្ដីអធិប្បាយ

*បណ្ដាបទទាំងនោះ បទថា* **អគ្គិហុត្តំវ** *សេចក្ដីថា បុគ្គលគប្បីដឹងច្បាស់នូវធម៌ដែលតថាគតប្រកាសហើយ អំពីអាចារ្យណា គប្បីនមស្ការអាចារ្យនោះដោយគោរព ដូចព្រាហ្មណ៍នមស្ការការបូជាភ្លើង ដោយគោរព ដោយការបម្រើដោយល្អ និងដោយកិច្ចទាំងឡាយ មានអញ្ជលីកម្មជាដើម ដូច្នោះ ។*

*ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។*

*( បិដក ៥២ ទំព័រ ១០៤ )*

*រឿង ព្រះសារីបុត្តត្ថេរ ចប់*

# នាវាសូត្រ

បុរសបានដឹងធម៌ អំពីសំណាក់អាចារ្យណា គប្បីបូជាអាចារ្យនោះ ដូចជាទេវតាបូជាព្រះឥន្ទ្រ អាចារ្យអ្នកចេះដឹងច្រើន ដែលមានសិស្សបានបូជាហើយនោះ ជាអ្នកមានចិត្តជ្រះថ្លាក្នុងសិស្សនោះ រមែងធ្វើធម៌ឲ្យជាក់ច្បាស់ ។ សិស្សនោះកាលបើបានធ្វើធម៌នោះ ឲ្យតាំងនៅហើយ បានពិចារណា ជាធីរជន ប្រតិបត្តិធម៌សមគួរតាមធម៌ រមែងជាអ្នកដឹង ជាអ្នកធ្វើឲ្យជាក់ច្បាស់ ទាំងជាអ្នកមានបញ្ញាល្អិត បុគ្គលដែលមិនប្រមាទ រមែងសេពគប់អ្នកប្រាជ្ញបែបនោះ ។ សិស្សកាលបើសេពគប់នឹងអាចារ្យ ជាអ្នកទន់ទាប ល្ងង់ខ្លៅ មានប្រយោជន៍មិនទាន់សម្រេច មានតែសេចក្តីច្រណែនគេ រមែងមិនបានធ្វើឲ្យជាក់ច្បាស់ នូវធម៌ក្នុងសាសនានេះ មិនបានឆ្លងផុតសេចក្តីសង្ស័យ ដល់នូវមរណៈ ។ ជនចុះកាន់ទន្លេមានទឹកច្រើន លំហាច ហូរខ្លាំង ជននោះ កាលរសាត់អណ្តែតទៅតាមខ្សែទឹក ធ្វើម្តេច នឹងអាចចម្លងពួកជនឯទៀតបាន យ៉ាងណាមិញ ។ បុគ្គលណា មិនបានធ្វើឲ្យជាក់ច្បាស់នូវធម៌ មិនបានស្តាប់សេចក្តី (ក្នុងសំណាក់)នៃពួកពហុស្សូត មិនទាន់យល់ដោយខ្លួនឯង ជាអ្នកមិនទាន់អស់សេចក្តីសង្ស័យ ធ្វើម្តេច នឹងអាចញុំាងជនឯទៀតឲ្យយល់បាន ក៏យ៉ាងនោះដែរ ។ បុគ្គលឡើងជិះទូកដ៏មាំ បរិបូរណ៍ដោយចែវ និងថ្នាល ជាអ្នកដឹងឧបាយក្នុងការទូកនោះ ជាអ្នកឈ្លាសវៃ មានគំនិត គប្បីចម្លងពួកជនដទៃជាច្រើន ក្នុងទូកនោះបាន យ៉ាងណាមិញ ចំណែកបុគ្គលណា ជាអ្នកដល់នូវវេទ មានចិត្តបានអប់រំហើយ ជាពហុស្សូត មិនញាប់ញ័រ(ក្នុងលោកធម៌)

បុគ្គលនោះឯង ជាអ្នកចេះដឹង ញុំាងពួកជនដទៃដែលជាអ្នកបរិបូរណ៍ដោយការ ត្រងត្រាប់ និងឧបនិស្ស័យ ឲ្យចេះដឹងបាន ក៏យ៉ាងនោះឯង ។

ព្រោះហេតុនោះ បុគ្គលគួរសេពគប់សប្បុរស ជាអ្នកមានប្រាជ្ញា ទាំងជាពហុស្សូត បុគ្គលនោះកាលដឹងសេចក្តីហើយ ប្រតិបត្តិតាម ជាអ្នកដឹងធម៌ច្បាស់ រមែងបាននូវសេចក្តីសុខ ។

ចប់ នាវាសូត្រទី ៨

( បាលីប្រែ ៥៤ ទំព័រ១០១ )

# បុគ្គលជាអាចារ្យ

[ ១៩៥ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល( ជាអាចារ្យ )ណាក្តី បបួលគេក្នុងធម្មវិន័យដែលសាស្តាជាអសព្វញ្ញូ ពោលមិនត្រូវ បបួលនូវបុគ្គល( ជាអន្តេវាសិក )ណាក្តី បុគ្គល( ជាអន្តេវាសិក )ណា ដែលអាចារ្យបបួលហើយប្រតិបត្តិតាមយ៉ាងនោះ បុគ្គលទាំងអស់នោះ តែងបាននូវបាបជាច្រើន ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះធម៌ដែលគេពោលខុស ។

[ ១៩៦ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល( ជាអាចារ្យ )ណាក្តី បបួលគេក្នុងធម្មវិន័យ ដែលសាស្តាជាសព្វញ្ញូពុទ្ធពោលត្រូវ បបួលនូវបុគ្គល( ជាអន្តេវាសិក )ណាក្តី បុគ្គល( ជាអន្តេវាសិក )ណា ដែលអាចារ្យបបួលហើយប្រតិបត្តិតាមយ៉ាងនោះ បុគ្គលទាំងអស់នោះ តែងបាននូវបុណ្យជាច្រើន ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះធម៌ដែលគេពោលត្រឹមត្រូវ ។

## អដ្ឋកថា

[ ១៩៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៥ ជាដើម ដូចតទៅនេះ បទថា **ទុរក្ខាតេ ភិក្ខវេ ធម្មវិនយេ** អធិប្បាយថា ពាក្យប្រៀនប្រដៅរបស់មេលទ្ធិក្រៅសាសនា ឈ្មោះថា ធម៌វិន័យដែលពោលទុកអាក្រក់ ។ ព្រោះថា ក្នុងពាក្យប្រៀនប្រដៅទាំងនោះ អ្នកប្រៀនប្រដៅមិនមែនជាសព្វញ្ញូ ធម៌ ក៏ជាធម៌ដែលពោលទុកអាក្រក់ សូម្បីពួកគណៈក៏ជាអ្នកបដិបត្តិអាក្រក់ ។ បទថា **យោ ច សមាទបេតិ** បានដល់ បុគ្គលដែលជាអាចារ្យណា រមែងដឹកនាំ ។ បទថា **យញ្ច សមាទបេតិ** សេចក្តីថា ដឹកនាំនូវអន្តេវាសិកណា ។ បទថា **យោ ច សមាទបិតោ តថត្តាយ**

**បដិបជ្ជតិ** សេចក្តីថា អន្តេវាសិកណាត្រូវអាចារ្យដឹកនាំ ហើយធ្វើតាមពាក្យអាចារ្យ ឈ្មោះថា បដិបត្តិដើម្បីភាពយ៉ាងនោះ ។ បទថា **ពហុំ អបុញ្ញំ បសវន្តិ** អធិប្បាយថា បុគ្គលដែលដឹកនាំ កាលដឹកនាំបុគ្គល ១០០ នាក់ ក្នុងកម្ម មានបាណាតិបាតជាដើម រមែងបានអកុសលប៉ុនគ្នានឹងអកុសលរបស់បុគ្គលដែលត្រូវដឹកនាំទាំងអស់នោះ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា មនុស្សទាំងអស់នោះ រមែងជួបនូវកម្ម មិនមែនបុណ្យដ៏ច្រើន ។

[ ១៩៦ ] បទថា **ស្វាក្ខាតេ** បានដល់ ក្នុងព្រះធម៌ និងព្រះវិន័យដែលត្រាស់ល្អហើយ គឺសម្តែងទុកល្អហើយ ព្រោះក្នុងព្រះធម៌ និងព្រះវិន័យបែបនេះ ព្រះសាស្តាក៏ទ្រង់ជាព្រះសព្វញ្ញូ ព្រះធម៌ក៏ព្រះសាស្តាត្រាស់ល្អហើយ គណៈក៏ជាអ្នកបដិបត្តិល្អហើយ ។ បទថា **សព្វេ តេ ពហុំ បុញ្ញំ បសវន្តិ** អធិប្បាយថា បុគ្គលដែលដឹកនាំ បានឃើញភិក្ខុទាំងឡាយចូលទៅបិណ្ឌបាត បានដឹកនាំអ្នកដទៃៗឲ្យប្រគេនបបរ និងភត្តជាដើម រមែងបានកុសលប៉ុនគ្នានឹងកុសលរបស់អ្នកឲ្យទានទាំងអស់ ។ ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ថា មនុស្សទាំងអស់នោះ រមែងជួបនូវបុណ្យច្រើន ។

( បាលីប្រែ-៤០ , បិដក-អដ្ឋកថា ២៦-៥៨ )

# សីលសម្បន្នសូត្រ

[ ១០៦ ] ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណា បរិបូណ៌ដោយសីល បរិបូណ៌ដោយសមាធិ បរិបូណ៌ដោយបញ្ញា បរិបូណ៌ដោយវិមុត្តិ បរិបូណ៌ដោយវិមុត្តិញ្ញាណទស្សនៈ ជាអ្នកទូន្មាន ពន្យល់ឲ្យដឹង សម្តែងបញ្ជាក់ឲ្យឃើញងាយ ណែនាំធ្វើឲ្យអង់អាច ធ្វើឲ្យរីករាយ ( ក្នុងកុសលធម៌ ) អាចសម្តែងនូវព្រះសទ្ធម្មបាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការជួបប្រទះនូវភិក្ខុទាំងនោះថា មានឧបការៈច្រើនផង ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការស្តាប់នូវភិក្ខុទាំងនោះថា មានឧបការៈច្រើនផង ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការចូលទៅរកភិក្ខុទាំងនោះថា មានឧបការៈច្រើនផង ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការចូលទៅអង្គុយជិតភិក្ខុទាំងនោះថា មានឧបការៈច្រើនផង ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការរឭកនូវភិក្ខុទាំងនោះថា មានឧបការៈច្រើនផង ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការបួសតាមភិក្ខុទាំងនោះថា មានឧបការៈច្រើនផង ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលសេពគប់ ចូលទៅអង្គុយជិតពួកភិក្ខុបែបនោះហើយ សីលក្ខន្ធដែលមិនទាន់បរិបូណ៌ រមែងដល់នូវការបរិបូណ៌ដោយភាវនាផង សមាធិក្ខន្ធដែលមិនទាន់បរិបូណ៌ រមែងដល់នូវការបរិបូណ៌ដោយភាវនាផង បញ្ញាខន្ធដែលមិនទាន់បរិបូណ៌ រមែងដល់នូវការបរិបូណ៌ដោយភាវនាផង វិមុត្តិក្ខន្ធដែលមិនទាន់បរិបូណ៌ រមែងដល់នូវការបរិបូណ៌ដោយភាវនាផង វិមុត្តិញ្ញាណទស្សនក្ខន្ធដែលមិនទាន់បរិបូណ៌ រមែងដល់នូវការបរិបូណ៌ដោយភាវនាផង ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុបែបនោះហៅថា សាស្តា

ក៏បាន ហៅថា អ្នកនាំទៅនូវពួកក៏បាន ហៅថា អ្នកលះបង់សត្រូវក៏បាន ហៅថា អ្នកបន្ទោបង់ងងឹតក៏បាន ហៅថា អ្នកធ្វើពន្លឺក៏បាន ហៅថា អ្នកធ្វើឲ្យភ្លឺស្វាងក៏បាន ហៅថា អ្នកធ្វើប្រទីបក៏បាន ហៅថា អ្នកធ្វើរស្មីក៏បាន ហៅថា អ្នកទ្រោលបំភ្លឺដោយគប់ភ្លើងក៏បាន ហៅថា អរិយៈក៏បាន ហៅថា អ្នកមានចក្ខុក៏បាន ។

ការដែលបានជួបប្រទះជាដើមនូវពួកអរិយៈ ជាអ្នកដឹងច្បាស់ បានចម្រើនចិត្ត ចិញ្ចឹមជីវិតតាមធម៌នុ៎ះឯង ជាហេតុធ្វើឲ្យមានបាមោជ្ជៈ ។ ពួកអរិយៈនោះ តែងបំភ្លឺ សម្តែងនូវព្រះសទ្ធម្ម អ្នកធ្វើរស្មី ធ្វើពន្លឺ អ្នកមានប្រាជ្ញា មានចក្ខុ លះបង់នូវសឹកសត្រូវ គឺ កិលេស ។ ពួកអ្នកប្រាជ្ញបានស្តាប់នូវពាក្យប្រដៅរបស់ពួកអរិយៈទាំងនោះហើយ រមែងដឹងច្បាស់ដោយប្រពៃ ស្គាល់ច្បាស់នូវធម៌ជាគ្រឿងអស់ទៅនៃជាតិ ហើយមិនត្រឡប់មកកាន់ភពថ្មីទៀតឡើយ ។

សូត្រទី ៥ ។

# អដ្ឋកថា

# សីលសម្បន្នសូត្រ

ក្នុងសីលសម្បន្នសូត្រទី ៥ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ១០៦ ] ក្នុងបទថា **សីលសម្បន្នា** មានអធិប្បាយថា លោកិយសីល និងលោកុត្តរសីលរបស់ព្រះខីណាស្រពទាំងឡាយ ឈ្មោះថា សីល ។ ភិក្ខុទាំងឡាយ ឈ្មោះថា សម្បូរដោយសីល ព្រោះអត្ថថា សម្បូរ គឺ ប្រកបដោយសីលនោះៗ ។ សូម្បីក្នុងសមាធិ និងបញ្ញាក៏មានន័យនេះឯង ។ ឯវិមុត្តិ បានដល់ផលវិមុត្តិនោះឯង ។ វិមុត្តិញ្ញាណទស្សនៈ បានដល់ បច្ចវេក្ខណញ្ញាណ ។ ក្នុងអធិការនេះ ធម៌ ៣ មានសីលជាដើម ជាលោកិយផង លោកុត្តរផង វិមុត្តិជាលោកុត្តរតែម្យ៉ាង វិមុត្តិញ្ញាណទស្សនៈជាលោកិយតែម្យ៉ាង ។

ភិក្ខុទាំងឡាយ ឈ្មោះថា **ឱវាទកា** ព្រោះអត្ថថា ពោលប្រៀនប្រដៅ គឺទូន្មានបុគ្គលដទៃ ដោយទិដ្ឋធម្មិកត្ថប្រយោជន៍ សម្បរាយិកត្ថប្រយោជន៍ និងបរមត្ថប្រយោជន៍ តាមសមគួរ ។ បទថា **វិញ្ញាបកា** បានដល់ ជួយបុគ្គលដទៃឲ្យយល់នូវកម្ម និងផលនៃកម្ម ។ ម្យ៉ាងទៀត ក្នុងបទថា **វិញ្ញាបកា** មានអធិប្បាយថា ជួយបុគ្គលដទៃឲ្យយល់ គឺ ឲ្យដឹងនូវធម៌ទាំងឡាយដោយន័យ ៣ យ៉ាង តាមលក្ខណៈរបស់ខ្លួន គឺ តាមសាមញ្ញលក្ខណៈដោយការចែកជាកុសល ដោយការចែកជាខន្ធជាដើម ដោយន័យជាដើមថា ធម៌ទាំងនេះជាកុសល ធម៌ទាំងនេះជាអកុសល ធម៌ទាំងនេះមានទោស ធម៌ទាំងនេះមិនមានទោស ។ បទថា **សន្ទស្សកា** បានដល់ សម្តែងធម៌ទាំងនោះឯង ឲ្យអ្នកដទៃឃើញច្បាស់ ដូចចាប់

ធម៌ទាំងនោះដោយដៃ ។ បទថា **សមាទបកា** បានដល់ ធ្វើឲ្យអ្នកដទៃសមាទាន សីលជាដើម ដែលមិនទាន់បានសមាទាន គឺ ធ្វើបុគ្គលដទៃឲ្យតាំងនៅក្នុងសីល ជាដើមនោះ ។ បទថា **សមុត្តេជកា** សេចក្តីថា ធ្វើចិត្តនៃបុគ្គលទាំងឡាយដែល តាំងនៅក្នុងកុសលធម៌យ៉ាងនេះ ឲ្យអាចហ៊ានដោយល្អ ដោយការណែនាំក្នុងការ បំពេញអធិចិត្តឲ្យខ្ពស់ឡើង គឺ ធ្វើចិត្តរបស់បុគ្គលនោះឲ្យផូរផង់ ដោយការ ពិចារណា ដោយប្រការដែលបុគ្គលនោះ គប្បីសម្រេចគុណវិសេសបាន ។ បទថា **សម្បហំសកា** សេចក្តីថា ធ្វើចិត្តរបស់បុគ្គលដទៃឲ្យត្រេកអរដោយល្អ ដោយ គុណវិសេសតាមដែលបានហើយ នឹងគប្បីបានក្នុងលំដាប់ខ្ពស់ជាបន្ត គឺ ធ្វើចិត្តនៃ បុគ្គលនោះឲ្យត្រេកអរដោយល្អ ដោយអំណាចនៃការពេញចិត្តដែលបានហើយ ។ បទថា **អលំ សមក្ខាតារោ** បានដល់ ជាអ្នកអាចប្រាប់បរិយត្តិ គឺព្រះសទ្ធម្មតាម ដែលបានពោល មិនឲ្យវិនាស ដោយបំណងនឹងអនុគ្រោះដោយប្រពៃនោះឯង ។

ម្យ៉ាងទៀត បទថា **សន្ទស្សកា** សេចក្តីថា ភិក្ខុកាលសម្តែងធម៌ ក៏សម្តែង ដោយល្អនោះឯង ទាំងបវត្តិ( ការប្រព្រឹត្តទៅ ) និងនិវត្តិ( ការវិលត្រឡប់ ) តាមសភាវលក្ខណៈដែលពិត ។ បទថា **សមាទបកា** សេចក្តីថា ញុំាងអ្នក ស្តាប់ឲ្យកាន់យកសេចក្តីនោះឯង ដោយឲ្យអត្ថនោះ តាំងមាំនៅក្នុងចិត្ត ។ បទថា **សមុត្តេជកា** សេចក្តីថា ញុំាងអ្នកស្តាប់ឲ្យផូរផង់ ឬឲ្យរុងរឿងដោយល្អនោះឯង ដោយការឲ្យកើតឧស្សាហ៍ក្នុងការទទួលយកអត្ថនោះ ។ បទថា **សម្បហំសកា** សេចក្តីថា ញុំាងអ្នកស្តាប់ឲ្យត្រេកអរ គឺឲ្យត្រេកអរដោយល្អនោះឯងនូវអត្ថនោះ ដោយការសម្តែងអានិសង្សក្នុងកិច្ចបដិបត្តិ ។ បទថា **អលំ សមក្ខាតារោ** សេចក្តីថា

ជាអ្នកអាចប្រាប់បានតាមន័យដែលពោលហើយ ។ បទថា **សទ្ធម្មស្ស** បានដល់ ជាអ្នកសម្តែងនូវបដិវេធសទ្ធម្ម ឬ ព្រះសទ្ធម្ម ទាំង ៣ យ៉ាង ។

បទថា **ទស្សនម្បហំ** កាត់បទជា **ទស្សនំ បិ អហំ។** ឯការឃើញនេះ មាន ២ យ៉ាង គឺ ឃើញដោយចក្ខុ ១ ឃើញដោយញាណ ១ បណ្តាការឃើញទាំង ២ យ៉ាងនោះ ការសម្លឹងមើលព្រះអរិយៈទាំងឡាយដោយភ្នែក សម្តែងនូវសេចក្តីជ្រះថ្លា ឈ្មោះថា ឃើញដោយចក្ខុ ។ ឯការសម្រេចធម៌ទាំងឡាយដែលធ្វើឲ្យជាព្រះអរិយៈ និងភាពជាព្រះអរិយៈដោយវិបស្សនា មគ្គ និងផល ឈ្មោះថា ឃើញដោយញាណ ។ តែក្នុងអត្ថនេះ លោកបំណងយកការឃើញដោយចក្ខុ ព្រោះថាការសម្លឹងមើលព្រះអរិយៈទាំងឡាយដោយភ្នែក សម្តែងនូវការជ្រះថ្លា ក៏មានឧបការៈច្រើនដល់សត្វទាំងឡាយ ។ បទថា **សវនំ** បានដល់ ការបានឮដោយត្រចៀក កាលមនុស្សទាំងឡាយនិយាយគ្នាថា ព្រះខីណាស្រពឈ្មោះនោះ នៅក្នុងដែន ឬជនបទ ក្នុងគាម ឬនិគម ក្នុងវិហារ ឬគុហាឈ្មោះនោះ នេះក៏មានឧបការៈច្រើនដូចគ្នា ។ បទថា **ឧបសង្កមនំ** សេចក្តីថា ការចូលទៅរកព្រះអរិយៈទាំងឡាយ ដោយការគិតឃើញបែបនេះថា អញនឹងឲ្យទាន នឹងសួរបញ្ហា នឹងស្តាប់ធម៌ ឬ នឹងធ្វើនូវសក្ការៈ ។ បទថា **បយិរុបាសនំ** បានដល់ ការចូលទៅអង្គុយជិតដើម្បីសួរបញ្ហា អធិប្បាយថា ការបានស្តាប់គុណរបស់ព្រះអរិយៈទាំងឡាយ ចូលទៅរកព្រះអរិយៈទាំងនោះ និមន្តហើយថ្វាយទាន ឬ ធ្វើវត្ត ហើយសួរបញ្ហាដោយ ន័យជាដើមថា បពិត្រលោកម្ចាស់ អ្វីឈ្មោះថាកុសល ការធ្វើការបម្រើជាដើម ចាត់ជាការចូលទៅអង្គុយជិតដូចគ្នា ។ បទថា **អនុស្សតិ** បានដល់

ការដែលបុគ្គលអង្គុយក្នុងទីសម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃ រឭកដល់រឿយៗនូវគុណវិសេស មានទិព្វវិហារធម៌ជាដើមរបស់ព្រះអរិយៈទាំងនោះ ជាអារម្មណ៍ថា ឥឡូវនេះព្រះអរិយៈទាំងឡាយ កំពុងឈប់សម្រាកក្នុងទីទាំងឡាយមានគុម្ពឈើ គុហា និងមណ្ឌបជាដើម ដោយសេចក្ដីសុខដែលកើតអំពីឈាន វិបស្សនា មគ្គ និងផល ។

ម្យ៉ាងទៀត បានដល់ បង្អោនទឹកដល់ឱវាទដែលបានអំពីសម្នាក់របស់ព្រះអរិយបុគ្គលទាំងនោះ ហើយរឭកដល់រឿយៗយ៉ាងនេះថា ព្រះមានបុណ្យត្រាស់សីលក្នុងទីនេះ ត្រាស់សមាធិក្នុងទីនេះ ត្រាស់វិបស្សនាក្នុងទីនេះ ត្រាស់មគ្គក្នុងទីនេះ ត្រាស់ផលក្នុងទីនេះ ។ បទថា **អនុបព្វជ្ជំ** បានដល់ ធ្វើចិត្តឲ្យជ្រះថ្លាក្នុងព្រះអរិយៈទាំងឡាយ ហើយចេញចាកផ្ទះ បួសក្នុងសម្នាក់ព្រះអរិយៈទាំងនោះ អធិប្បាយថា ការធ្វើចិត្តឲ្យជ្រះថ្លាក្នុងព្រះអរិយៈទាំងឡាយហើយបួសក្នុងសម្នាក់ព្រះអរិយៈទាំងនោះឯង ត្រាច់ទៅបំណាងតាំងនៅក្នុងឱវាទានុសាសនីរបស់ព្រះអរិយៈទាំងនោះ ឈ្មោះថា ការបួសតាម ។ ការបួសរបស់បុគ្គលដែលត្រាច់ទៅប្រាថ្នាក្នុងឱវាទានុសាសនី ក្នុងសម្នាក់បុគ្គលពួកដទៃក៏ឈ្មោះថា បួសតាម ។ ការបួសរបស់បុគ្គល ដែលបួសក្នុងសម្នាក់ដទៃ ព្រោះការជ្រះថ្លាក្នុងព្រះអរិយៈទាំងឡាយ ហើយត្រាច់ទៅ ប្រាថ្នាទទួលឱវាទានុសាសនីក្នុងសម្នាក់ព្រះអរិយៈទាំងឡាយ ក៏ឈ្មោះថា បួសតាមដូចគ្នា ។ ឯការបួសរបស់បុគ្គលដែលបួសក្នុងសម្នាក់អ្នកដទៃ ព្រោះជ្រះថ្លាក្នុងបុគ្គលដទៃ ហើយត្រាច់ទៅ ប្រាថ្នាក្នុងឱវាទានុសាសនីរបស់បុគ្គលដទៃដូចគ្នា មិនឈ្មោះថា ជាការបួសតាម ។ បណ្ដាបុគ្គល

ដែលបួសតាមន័យដូចពោលហើយ ជាបឋម បុគ្គលដែលបួសតាមព្រះមហាកស្សបត្ថេរ មានចំនួនមួយសែននាក់ ។ អ្នកបួសតាមព្រះចន្ទគុត្តត្ថេរដែលជាសទ្ធិវិហារិករបស់ព្រះថេរៈនោះឯង ក៏មានចំនួនប៉ុណ្ណោះគ្នា ។ ព្រះសុរិយគុត្តត្ថេរជាសទ្ធិវិហារិករបស់ព្រះចន្ទគុត្តត្ថេរ ព្រះអស្សគុត្តត្ថេរដែលជាសទ្ធិវិហារិករបស់ព្រះសុរិយគុត្តត្ថេរនោះ ព្រះយោនកធម្មរក្ខិតត្ថេរ ដែលជាសទ្ធិវិហារិករបស់ព្រះអស្សគុត្តត្ថេរនោះ មានអ្នកបួសតាមចំនួនប៉ុណ្ណោះដូចគ្នា ឯប្អូនប្រុសរបស់ព្រះបាទអសោក ជាសទ្ធិវិហារិក ព្រះយោនកធម្មរក្ខិតត្ថេរនោះ បានឈ្មោះថា តិស្សត្ថេរ បុគ្គលដែលបួសតាមព្រះតិស្សត្ថេរនោះ មានចំនួន ២ កោដិកន្លះ ។ ចំណែកបុគ្គលដែលបួសតាម ព្រះមហិន្ទត្ថេរ ដែលញុំាងអ្នកកោះឲ្យជ្រះថ្លារាប់ចំនួនមិនបាន ។ ក្នុងកោះលង្កា បុគ្គលបួសដោយការជ្រះថ្លាក្នុងព្រះសាសនាដរាបដល់សព្វថ្ងៃនេះ ឈ្មោះថា បួសតាមព្រះមហិន្ទត្ថេរទាំងអស់ ។

ឥឡូវនេះ ដើម្បីទ្រង់សម្តែងដល់ហេតុដែលទ្រង់ត្រាស់ថា ការឃើញព្រះអរិយៈទាំងនោះជាដើម មានឧបការៈច្រើន ទើបព្រះមានព្រះភាគត្រាស់ពាក្យថា **តថារូបេ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **តថារូបេ** បានដល់ ព្រះអរិយៈបែបនោះ គឺជាអ្នកសម្បូរដោយគុណ មានសីលជាដើម ។

ព្រោះការឃើញ ការស្តាប់ និងការរឭកដល់ជាហេតុនៃការចូលទៅរក និងការចូលទៅអង្គុយជិត ដូច្នោះ ដើម្បីសម្តែងចំពោះការចូលទៅរក និងការចូលទៅអង្គុយជិត មិនអាស្រ័យដល់ការឃើញ ការឮ និងការរឭកដល់ ទើបព្រះមានព្រះ

ភាគត្រាស់ថា **សេវតោ ភជតោ បយិរុបាសតោ** ដូច្នេះ ។ ព្រោះបានឃើញ បានស្តាប់ និងរឭកដល់រឿយៗ ទើបកុលបុត្រកើតសទ្ធាក្នុងព្រះអរិយៈទាំងឡាយ ហើយចូលទៅរក ចូលទៅអង្គុយជិតព្រះអរិយៈទាំងនោះ សួរបញ្ហា បានទូវសវនានុត្តរិយៈ ហើយក៏បំពេញគុណ មានសីលជាដើម ដែលមិនទាន់បរិបូណ៌ឲ្យបរិបូណ៌ដូច្នេះ ។ សមដូចពាក្យដែលលោកពោលក្នុងមជ្ឈិមនិកាយ មជ្ឈិម-បណ្ណាសកថា កុលបុត្រក្នុងសាសនានេះមានសទ្ធា ទើបចូលទៅរក កាលបើចូលទៅរកហើយ ទើបចូលទៅអង្គុយជិត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សេវតោ** បានដល់ ចូលទៅរកតាមពេលដ៏សមគួរដោយការធ្វើវត្ត និងវត្តត្រឡប់ ។ បទថា **ភជតោ** បានដល់ គប់រកដោយអំណាចការស្រឡាញ់ និងការស្មោះត្រង់ ។ បទថា **បយិរុបាសតោ** បានដល់ ចូលទៅអង្គុយជិតដោយការសួរបញ្ហា និងធ្វើតាមបដិបទា ។ អ្នកសិក្សាគប្បីជ្រាបការចែកអត្ថនៃបទទាំង ៣ ដូចពោលមកនេះ ។ ការបរិបូណ៌នៃវិមុត្តិ-ញាណទស្សនៈ គប្បីជ្រាបបានដោយការកើតឡើងនៃបច្ចវេក្ខណញ្ញាណទី១៩ ។

ក្នុងបទថា **ឯវរូបា ច តេ ភិក្ខវេ ភិក្ខូ** ជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅ ភិក្ខុណាមានសភាពបែបនេះ គឺដូច្នេះ បានដល់ ទម្លាយកិលេសបានអស់ហើយ ព្រោះប្រកបដោយគុណតាមដែលពោលហើយ ភិក្ខុទាំងនោះ ហៅថា **សត្ថារោ** ព្រោះទូន្មាន ដោយការប្រកបសត្វទាំងឡាយក្នុងប្រយោជន៍ មានទិដ្ឋធម្មិកត្ថ-ប្រយោជន៍ជាដើមខ្វះ ហៅថា **សត្ថវាហា** ព្រោះជួយសត្វទាំងឡាយឲ្យឆ្លងផុតជាតិសង្សារជាដើមខ្វះ ហៅថា **រណញ្ជហា** ព្រោះលះសត្រូវ គឺកិលេសជាគ្រឿង

សាំញ៉ាំមានរាគៈជាដើម បានដោយខ្លួនឯង និងទូន្មានអ្នកដទៃឲ្យលះតាមខ្លះ ហៅថា **តមោនុទា** ព្រោះបន្ទោបង់នូវងងឹត គឺ អវិជ្ជាដោយខ្លួនឯង និងទូន្មានអ្នកដទៃឲ្យបន្ទោបង់តាមខ្លះ ហៅថា **អាលោកករា** ព្រោះធ្វើឲ្យកើតពន្លឺគឺបញ្ញា ឱភាសគឺបញ្ញា និងជោតិគឺបញ្ញា ក្នុងសន្តានរបស់ខ្លួន និងបុគ្គលដទៃខ្លះ ។ ម្យ៉ាងទៀត ហៅថា **បភង្ករា** គឺអ្នកធ្វើនូវរស្មីខ្លះ **ឧក្កាធារា** អ្នកទ្រទ្រង់នូវគប់ភ្លើងខ្លះ ព្រោះធ្វើធម៌ឲ្យជេរជាស ឲ្យផ្សាយទៅដោយរស្មី គឺញាណ ហៅថា **អរិយា** ព្រោះជាអ្នកឆ្ងាយចាកកិលេសទាំងឡាយ ១ ព្រោះមិនដើរទៅតាមផ្លូវដែលមិនគួរដើរ ១ ព្រោះដើរទៅក្នុងផ្លូវដែលគួរដើរ ១ ព្រោះហេតុឲ្យទៅជាយ៉ាងនោះរបស់ជនពួកដទៃ ១ ព្រោះសត្វលោក និងទេវលោកគប្បីដើរតាម ១ ហៅថា **ចក្ខុមន្តោ** ព្រោះបាននូវបញ្ញាចក្ខុ និងធម្មចក្ខុយ៉ាងល្អក្រៃលែង ។ គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំងឡាយដូច្នេះ បទថា **ចាមោជ្ជករណដ្ឋានំ** បានដល់ ទីតាំង គឺហេតុឲ្យកើតនូវការត្រេកអរដែលប្រាសចាកអាមិស ។ លោកពោលដល់ទិទស្សនៈដែលគប្បីពោលក្នុងឥឡូវនេះថា **ឯតំ** ។ បទថា **វិជានតំ** បានដល់ ស្គាល់សេចក្តី សៅហ្មង និងសេចក្តីផូរផង់តាមសេចក្តីពិត ។ បទថា **ភាវិតត្តានំ** បានដល់ ជាអ្នកមានសភាវៈ គឺ ចិត្តដែលអប់រំហើយ អធិប្បាយថា ជាអ្នកមានសន្តានអប់រំហើយដោយការអប់រំកាយជាដើម ។ បទថា **ធម្មជីវិនំ** សេចក្តីថា ឈ្មោះថា ជាអ្នកមានប្រក្រតីនៅដោយធម៌ ព្រោះលះអាជីវៈហើយ ចិញ្ចឹមជីវិតដោយធម៌ គឺ ដោយញាយធម៌ ព្រោះនាំអត្តភាពទៅដោយធម៌ គឺ ដោយញាយធម៌ខ្លះ ព្រោះរស់នៅដោយផលធម៌ដ៏ប្រសើរទាក់ទងដោយសមាបត្តិខ្លះ ។ ក្នុងទីនោះមានសេចក្តីសង្ខេប

ដូច្នេះថា ការឃើញព្រះអរិយៈទាំងឡាយដែលអប់រំខ្លួនហើយ ជាអ្នកសម្រេចនូវសមាធិភាវនា និងបញ្ញាភាវនាហើយ ជាបុគ្គលឈ្មោះថា អ្នករស់នៅដោយធម៌ ព្រោះការអប់រំខ្លួន និងសម្រេចភាវនានោះឯង ឈ្មោះថា ជាហេតុនៃបីតិ និងបាមោជ្ជៈដោយចំណែកមួយប៉ុណ្ណោះ សម្រាប់បុគ្គលដែលមានបញ្ញាដឹងច្បាស់ ព្រោះជាហេតុនៃការសម្បូរនៃគុណទាំងឡាយ មានសីលជាដើម ដែលមិនក្ដៅក្រហាយជានិមិត្ត ។

ឥឡូវនេះ ដើម្បីសម្ដែងភាពដែលការឃើញព្រះអរិយៈទាំងឡាយនោះ ជាហេតុ ទើបព្រះមានព្រះភាគត្រាស់ ២ គាថាខាងចុងថា **តេ ជោតយន្តិ** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តេ** បានដល់ ព្រះអរិយៈទាំងនោះដែលអប់រំខ្លួនហើយ មានប្រក្រតីនៅដោយធម៌ ។ បទថា **ជោតយន្តិ** បានដល់ សម្ដែង ។ បទថា **ភាសយន្តិ** បានដល់ ធ្វើលោកឲ្យភ្លឺស្វាងដោយពន្លឺនៃព្រះសទ្ធម្ម អធិប្បាយថា សម្ដែងធម៌ ។ បទថា **យេសំ** បានដល់ ព្រះអរិយៈឯណា ។ បទថា **សាសនំ** បានដល់ ឱវាទ ។ បទថា **សម្មទញ្ញាយ** បានដល់ ដឹងដោយប្រពៃនោះឯង ដោយញាណដែលជាចំណែកខាងដើម ។ បទដ៏សេស មានន័យដូចពោលហើយនោះឯង ។ល។

( បាលីប្រែ ៥៣ , បិដក-អដ្ឋកថា ៣៦-៨៤៩ )

# ធម្មកថិកសូត្រទី ៩

[ ១៣៩ ] ម្នាលភិក្ខុទាំងឡាយ ធម្មកថិក ( អ្នកសម្តែងធម៌ ) នេះ មាន ៤ ពួក ។ ធម្មកថិកទាំង ៤ ពួក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ធម្មកថិកខ្លះ ក្នុងសាសនានេះសម្តែងធម៌តិចផង មិនប្រកបដោយប្រយោជន៍ផង ទាំងបរិស័ទក៏ជាអ្នកមិនឈ្លាសវៃ ចំពោះធម៌ដែលប្រកបដោយប្រយោជន៍ និងធម៌ដែលមិនប្រកបដោយប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ ធម្មកថិកមានសភាពយ៉ាងនេះ រមែងដល់នូវការរាប់ថាជាធម្មកថិករបស់បរិស័ទ មានសភាពដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ធម្មកថិកខ្លះ ក្នុងសាសនានេះ សម្តែងធម៌តិចផង ប្រកបដោយប្រយោជន៍ផង ទាំងបរិស័ទក៏ជាអ្នកឈ្លាសវៃចំពោះធម៌ដែលប្រកបដោយប្រយោជន៍ និង ធម៌ដែលមិនប្រកបដោយប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ ធម្មកថិកមានសភាពយ៉ាងនេះ រមែងដល់នូវការរាប់ថាជាធម្មកថិករបស់បរិស័ទមានសភាពដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ធម្មកថិកខ្លះ ក្នុងសាសនានេះ សម្តែងធម៌ច្រើនផង មិនប្រកបដោយប្រយោជន៍ផង ទាំងបរិស័ទក៏ជាអ្នកមិនឈ្លាសវៃ ចំពោះធម៌ដែលប្រកបដោយប្រយោជន៍ និងធម៌ដែលមិនប្រកបដោយប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ ធម្មកថិកមានសភាពយ៉ាងនេះ រមែងដល់នូវការរាប់ថាជាធម្មកថិករបស់បរិស័ទមានសភាពដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ធម្មកថិកខ្លះ ក្នុងសាសនានេះ សម្តែងធម៌ច្រើនផង ប្រកបដោយប្រយោជន៍ផង ទាំងបរិស័ទក៏ជាអ្នកឈ្លាសវៃចំពោះធម៌ដែលប្រកបដោយប្រយោជន៍ និងធម៌ដែលមិនប្រកបដោយប្រយោជន៍ ។ ម្នាល

ភិក្ខុទាំងឡាយ ធម្មកថិកមានសភាពយ៉ាងនេះ រមែងដល់នូវការរាប់ថា ជាធម្មកថិករបស់បរិស័ទ មានសភាពដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ធម្មកថិក ៤ ពួកនេះឯង ។

## អដ្ឋកថា

## ធម្មកថិកសូត្រ

[ ១៣៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងធម្មកថិកសូត្រទី ៩ ដូចតទៅនេះ បទថា **អសហិតំ** គឺមិនប្រកបដោយប្រយោជន៍ ។ បទថា **ន កុសលា ហោតិ** គឺជាបុគ្គលមិនឈ្លាស ។ បទថា **សហិតាសហិតស្ស** សេចក្ដីថា ចំពោះវត្ថុដែលប្រកបដោយប្រយោជន៍ ឬមិនប្រកបដោយប្រយោជន៍ ។ អត្ថក្នុងបទទាំងពួងគប្បីជ្រាបយ៉ាងនេះ ។ល។

( បិដក-អ ២៨-២៧៦ )

អដ្ឋកថា ធម្មកថិកសូត្រទី ៩ ចប់

# ចន្ទូបមសូត្រទី ៣

[ ១៣៨ ] ព្រះមានព្រះភាគ គង់នៅទៀបក្រុងសាវត្ថី ... ក្នុងទីនោះឯង ព្រះមានព្រះភាគ ... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយមានឧបមាដូចជាព្រះចន្ទ្រ ចូរដកកាយដកចិត្តចេញ ធ្វើដូចជាអាគន្តុកភិក្ខុ មិនឃ្នើសឃ្នងក្នុងត្រកូលទាំងឡាយ ហើយចូលទៅកាន់ត្រកូលចុះ ។ ម្នាលភិក្ខុទាំងឡាយ បុរសក្រឡេកមើលនូវរណ្តៅចាស់ក្តី នូវទីដែលមិនរាបស្មើក្នុងភ្នំក្តី នូវទីដែលឆ្លងបានដោយលំបាកក្នុងស្ទឹងក្តី តែងដកកាយដកចិត្តចេញ យ៉ាងណា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ មានឧបមាដូចជាព្រះចន្ទ្រ ចូរដកកាយដកចិត្តចេញ ធ្វើដូចជាអាគន្តុកភិក្ខុ មិនឃ្នើសឃ្នងក្នុងត្រកូលទាំងឡាយ ហើយចូលទៅកាន់ត្រកូលចុះ យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ កស្សបមានឧបមាដូចព្រះចន្ទ្រ តែងដកកាយដកចិត្តចេញ ធ្វើដូចជាអាគន្តុកភិក្ខុ មិនឃ្នើសឃ្នងក្នុងត្រកូលទាំងឡាយ ហើយចូលទៅកាន់ត្រកូល ។

[ ១៣៩ ] ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សម្គាល់ហេតុនោះដូចម្តេច ភិក្ខុមានសភាពដូចម្តេច ដែលគួរចូលទៅកាន់ត្រកូលទាំងឡាយបាន ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយរបស់ពួកខ្ញុំព្រះអង្គ សឹងមានព្រះមានព្រះភាគជាឫស មានព្រះមានព្រះភាគ ជាអ្នកណែនាំ មានព្រះមានព្រះភាគ ជាទីពឹងអាស្រ័យ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់ព្រះមេត្តាប្រោសបំភ្លឺសេចក្តីនៃភាសិតនុ៎ះឲ្យទាន ពួកភិក្ខុបានស្តាប់ព្រះមានព្រះភាគហើយ នឹងបានចងចាំទុក ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់លើកព្រះហស្តទៅក្នុងអាកាសហើយ

ធ្វើឲ្យញ័រ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បាតដៃនេះមិនជាប់ មិនចំពាក់ មិនស្អិតលើអាកាសយ៉ាងណា ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាមួយ ចូលទៅកាន់ត្រកូលទាំងឡាយហើយ មានចិត្តមិនជាប់ មិនចំពាក់ មិនស្អិតក្នុងត្រកូលទាំងឡាយ ដោយគិតថា ពួកជនដែលប្រាថ្នាលាភ ចូរឲ្យបាននូវលាភចុះ ពួកជនប្រាថ្នាបុណ្យ ចូរធ្វើបុណ្យចុះ យ៉ាងនោះឯង បុគ្គលជាអ្នកពេញចិត្ត មានចិត្តល្អ ដោយលាភរបស់ខ្លួនយ៉ាងណា បុគ្គលជាអ្នកពេញចិត្ត មានចិត្តល្អ ដោយលាភរបស់ពួកជនដទៃយ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបែបនេះ ទើបគួរចូលទៅកាន់ត្រកូលទាំងឡាយបាន ។ ម្នាលភិក្ខុទាំងឡាយ កាលកស្សបភិក្ខុចូលទៅកាន់ត្រកូលទាំងឡាយ មានចិត្តមិនជាប់ មិនចំពាក់ មិនស្អិតក្នុងត្រកូលទាំងឡាយ ដោយគិតថា ពួកជនប្រាថ្នាលាភ ចូរបានលាភចុះ ពួកជនប្រាថ្នាបុណ្យ ចូរធ្វើនូវបុណ្យចុះ ជនជាអ្នកពេញចិត្ត មានចិត្តល្អ ដោយលាភរបស់ខ្លួនយ៉ាងណា បុគ្គលជាអ្នកពេញចិត្ត មានចិត្តល្អ ដោយលាភរបស់ពួកបុគ្គលដទៃយ៉ាងនោះដែរ ។

[ ១៤០ ] ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សម្គាល់ហេតុនោះដូចម្តេច ធម្មទេសនារបស់ភិក្ខុបែបណា ដែលមិនបរិសុទ្ធ ធម្មទេសនារបស់ភិក្ខុ បែបណាដែលបរិសុទ្ធ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយរបស់ពួកខ្ញុំព្រះអង្គ សឹងមានព្រះមានព្រះភាគជាឫស មានព្រះមានព្រះភាគជាអ្នកណែនាំ មានព្រះមានព្រះភាគជាទីពឹងអាស្រ័យ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់ព្រះមេត្តាប្រោស សម្តែងសេចក្តីនៃភាសិតនុ៎ះឲ្យទាន ពួកភិក្ខុបានស្តាប់ព្រះមាន-

ព្រះភាគហើយ នឹងបានចងចាំទុក ។ ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយ ចូរប្រុងស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្តែង ។ ភិក្ខុទាំងនោះ ទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ភាសិតនេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាទីមួយ តាំងចិត្តយ៉ាងនេះថា អើហ្ន៎ ពួកជនគប្បីស្តាប់ធម៌របស់អាត្មាអញ លុះស្តាប់រួចហើយ ជ្រះថ្លាចំពោះធម៌ លុះជ្រះថ្លាពិតហើយ គប្បីធ្វើនូវអាការជ្រះថ្លាចំពោះអាត្មាអញទៀត ហើយក៏សម្តែងធម៌ដល់ពួកជនដទៃ ។ ម្នាលភិក្ខុទាំងឡាយ ធម្មទេសនារបស់ភិក្ខុបែបនេះ ឈ្មោះថា មិនបរិសុទ្ធទេ ។ ម្នាលភិក្ខុទាំងឡាយ លុះតែភិក្ខុណាតាំងចិត្តយ៉ាងនេះថា ព្រះធម៌ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយដោយប្រពៃ ជាធម៌ដែលអ្នកប្រាជ្ញគប្បីឃើញច្បាស់ដោយខ្លួនឯង ជាធម៌ឲ្យផលមិនរង់ចាំកាល ជាធម៌មានអាការដូចជាហៅបុគ្គលដទៃ ឲ្យចូលមកមើលបាន ជាធម៌គួរបង្អោនចូលមកទុកក្នុងខ្លួន ជាធម៌ដែលអ្នកប្រាជ្ញទាំងឡាយ គប្បីដឹងចំពោះខ្លួន អើហ្ន៎ ពួកជនដទៃគប្បីស្តាប់ធម៌របស់អាត្មាអញ លុះស្តាប់រួចហើយ គប្បីដឹងច្បាស់នូវធម៌ លុះដឹងច្បាស់នូវធម៌ហើយ គប្បីប្រតិបត្តិតាមបែបនោះ ហើយក៏សម្តែងធម៌ដល់ពួកជនដទៃ ភិក្ខុសម្តែងធម៌ដល់ពួកជនដទៃ ព្រោះអាស្រ័យនូវភាពនៃធម៌ ជាធម៌ល្អ សម្តែងធម៌ដល់ពួកជនដទៃ ព្រោះអាស្រ័យសេចក្តីករុណា សម្តែងធម៌ដល់ពួកជនដទៃ ព្រោះអាស្រ័យសេចក្តីអាណិត សម្តែងធម៌ដល់ពួកជនដទៃ ព្រោះសេចក្តីអនុគ្រោះ ដូចសម្តែងមកនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ធម្មទេសនារបស់ភិក្ខុបែបនេះ ទើបឈ្មោះថា បរិសុទ្ធ ។

[ ១៤១ ] ម្នាលភិក្ខុទាំងឡាយ កស្សបភិក្ខុតាំងចិត្តយ៉ាងនេះថា ព្រះធម៌ដែលព្រះមានព្រះភាគទ្រង់សម្ដែងហើយ ដោយប្រពៃ ជាធម៌ដែលអ្នកប្រាជ្ញគប្បីឃើញច្បាស់ដោយខ្លួនឯង ជាធម៌ឲ្យផលមិនរង់ចាំកាល ជាធម៌មានអាការដូចជាហៅបុគ្គលដទៃ ឲ្យចូលមកមើលបាន ជាធម៌គួរបង្អោនចូលមកទុកក្នុងខ្លួន ជាធម៌ដែលអ្នកប្រាជ្ញទាំងឡាយ គប្បីដឹងចំពោះខ្លួន អើហ្ន៎ ពួកជនដទៃ គប្បីស្ដាប់ធម៌របស់អាត្មាអញ លុះស្ដាប់រួចហើយ គប្បីដឹងច្បាស់នូវធម៌ លុះដឹងច្បាស់ហើយ គប្បីប្រតិបត្តិតាមបែបនោះ ហើយក៏សម្ដែងធម៌ដល់ពួកជនដទៃ កស្សបភិក្ខុរមែងសម្ដែងធម៌ដល់ពួកជនដទៃ ព្រោះអាស្រ័យនូវភាពនៃធម៌ ជាធម៌ល្អ សម្ដែងធម៌ដល់ពួកជនដទៃ ព្រោះអាស្រ័យសេចក្ដីករុណា សម្ដែងធម៌ដល់ពួកជនដទៃ ព្រោះអាស្រ័យសេចក្ដីអាណិត សម្ដែងធម៌ដល់ពួកជនដទៃ ព្រោះអាស្រ័យសេចក្ដីអនុគ្រោះ ដូចសម្ដែងមកនេះឯង ។

ម្នាលភិក្ខុទាំងឡាយ តថាគតនឹងទូន្មានអ្នកទាំងឡាយ តាមបែបកស្សបភិក្ខុ ឬក៏តាមបែបភិក្ខុណា ដែលប្រហែលនឹងកស្សបភិក្ខុ អ្នកទាំងឡាយដែលតថាគតទូន្មានហើយ គប្បីប្រតិបត្តិតាមបែបនោះចុះ ។

## សូត្រទី ៣ ចប់

# អដ្ឋកថា ចន្ទូបមសូត្រ

*[ ១៣៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងចន្ទូបមសូត្រទី ៣ ដូចតទៅនេះ ។ បទថា* **ចន្ទូបមា** *សេចក្ដីថា អ្នកទាំងឡាយ ចូរធ្វើខ្លួនដូចព្រះចន្ទ ដោយភាពជាបរិមណ្ឌល យ៉ាងណា ម្យ៉ាងទៀត ព្រះចន្ទគោចរលើលម្ហមេឃ មិនធ្វើស្និទ្ធស្នាល ជាប់ជំពាក់ ស្រឡាញ់ ប្រាថ្នា ឬព្យាយាមជាមួយនឹងបុគ្គលណាម្នាក់ឡើយ ។ តែមិនជាទីស្រឡាញ់ពេញចិត្តរបស់មហាជនក៏ទេ យ៉ាងណា ពួកអ្នក ក៏ជាទីស្រឡាញ់ពេញចិត្តរបស់មហាជន ព្រោះមិនធ្វើសេចក្ដីស្និទ្ធស្នាលជាដើម ជាមួយបុគ្គលណា ដូចព្រះចន្ទចូលទៅកាន់ ៤ ត្រកូល មានត្រកូលក្សត្រជាដើម ដូច្នោះ ម្យ៉ាងទៀត ព្រះចន្ទកម្ចាត់នូវងងឹត ឲ្យនូវពន្លឺ យ៉ាងណា គប្បីឃើញអត្ថក្នុងសេចក្ដីនេះ ដោយន័យជាដើមយ៉ាងនេះថា ពួកអ្នកដូចជាព្រះចន្ទ ដោយការកម្ចាត់ងងឹត គឺកិលេស និងដោយការបញ្ចេញពន្លឺ គឺបញ្ញា ដូច្នោះ ។*

*បទថា* **អបកស្សេវ កាយំ អបកស្ស ចិត្តំ** *សេចក្ដីថា ដក គឺទាញមកនាំចេញទៅនូវកាយផង នូវចិត្តផង ដោយការមិនធ្វើភាពស្និទ្ធស្នាលជាដើមនោះឯង ព្រោះថា ភិក្ខុណាមិននៅក្នុងព្រៃ ទាំងត្រិះរិះកាមវិតក្កជាដើម ភិក្ខុនេះក៏ឈ្មោះថា មិនដកនូវកាយផង មិនដកចិត្តផង ។ ឯភិក្ខុណា សូម្បីនៅព្រៃ តែត្រិះរិះនូវកាមជាដើម ភិក្ខុនេះឈ្មោះថា ដកកាយតែម្យ៉ាង តែមិនដកចិត្ត ។ ភិក្ខុណានៅក្នុងចន្លោះស្រុក តែមិនត្រិះរិះកាមវិតក្កជាដើម ភិក្ខុនេះ ឈ្មោះថា ដកចិត្តតែម្យ៉ាង តែមិនដកកាយ ។ ចំណែកភិក្ខុណានៅព្រៃផង មិនត្រិះរិះកាមវិតក្កជាដើមផង ភិក្ខុនេះ ឈ្មោះថា ដកទាំង ២ ។ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងថា ពួកអ្នក*

ចូរធ្វើបែបនេះ ចូលទៅកាន់ត្រកូល ទើបត្រាស់ថា **អបកស្សេវ កាយំ អបកស្ស ចិត្តំ** ដូច្នេះ ។

បទថា **និច្ចនវកា** សេចក្ដីថា ពួកអ្នកជាអ្នកថ្មីជានិច្ច គឺដូចជាអាគន្តុក ដូច្នេះ ព្រោះថា អាគន្តុកចូលទៅកាន់ផ្ទះតាមលំដាប់ បើម្ចាស់ផ្ទះឃើញលោក ក៏គិតថា ជាកូន ជាបងប្អូនប្រុសរបស់ខ្លួន ត្រាច់ទៅ និមន្តឲ្យស្នាក់យ៉ាងនេះ ដូច្នេះ កាល អនុគ្រោះ ក៏និមន្តឲ្យគង់ ឲ្យបរិភោគ លុះលោកបរិភោគស្រេចហើយ ក៏គិតថា អ្នកចូរកាន់យកភោជនរបស់អ្នកចុះ ដូច្នេះ ក្រោកឡើងចៀសចេញទៅ រមែងមិនធ្វើ សេចក្ដីស្និទ្ធស្នាលជាមួយម្ចាស់ផ្ទះទាំងនោះ ឬនឹងធ្វើករណីយកិច្ច ។ លោក សម្ដែងថា សូម្បីពួកអ្នកចូលទៅកាន់ផ្ទះ ចូលតាមលំដាប់យ៉ាងនេះហើយ ពួក មនុស្សដែលជ្រះថ្លាក្នុងឥរិយាបថ និងប្រគេនវត្ថុណា ទទួលយកវត្ថុនោះ កាត់បង់ នូវសេចក្ដីស្និទ្ធស្នាល ជាអ្នកមិនខ្វល់ខ្វាយ ក្នុងករណីយកិច្ចរបស់មនុស្ស ទាំង នោះ ចេញទៅ ដូច្នេះ ។ លោកពោលរឿងព្រះថេរៈ ២ នាក់បងប្អូន ដើម្បី ការជាក់ច្បាស់នូវភាពជាភិក្ខុថ្មីជានិច្ច ដូចតទៅនេះថា

## រឿង ព្រះចូឡនាគ និងព្រះមហានាគត្ថេរ

បានឮថា ព្រះថេរៈបងប្អូន ចេញបួសអំពីស្រុករោហនគរ ព្រះថេរៈ បងប្អូននោះ ប្រាកដឈ្មោះថា ចូឡនាគត្ថេរ និងមហានាគត្ថេរ ។ ព្រះថេរៈ ទាំងនោះនៅលើចិត្តលបព៌តអស់ ៣០ ឆ្នាំ សម្រេចអរហត្តហើយ គិតថា អញ នឹងសួរសុខទុក្ខញោមស្រី មកហើយ ស្នាក់នៅក្នុងវិហារនាវរោហនគរ ចូលទៅ កាន់ស្រុកញោមស្រី ដើម្បីបិណ្ឌបាតក្នុងថ្ងៃស្អែក ។ ញោមស្រី នាំបបរចេញទៅ

ដោយត្រឡោក ដើម្បីព្រះថេរៈទាំងនោះ គៀរចូលក្នុងបាត្រនៃព្រះថេរៈមួយរូប កាលនាងសម្លឹងព្រះថេរៈនោះ ក៏កើតសេចក្តីស្រឡាញ់ក្នុងបុត្រ ទើបនាងពោលនឹងលោកថា បពិត្រលោកម្ចាស់ លោកម្ចាស់ឈ្មោះ មហានាគ ជាកូនរបស់ខ្ញុំឬ ។ ព្រះថេរៈពោលថា ឧបាសិកា ចូរនាងសួរព្រះថេរៈឯក្រោយចុះ ហើយចៀសចេញទៅ នាងប្រគេនបបរដល់ព្រះថេរៈរូបក្រោយហើយ សួរថា បពិត្រលោកម្ចាស់ លោកម្ចាស់ឈ្មោះ ចូឡនាគ ជាកូនរបស់ខ្ញុំឬ ។ ព្រះថេរៈពោលថា ឧបាសិកា ម្តេចនាងមិនសួរព្រះថេរៈរូបមុន ដូច្នេះហើយ ចៀសចេញទៅ ។ ភិក្ខុកាត់នូវការស្និទ្ធស្នាលជាមួយមាតា យ៉ាងនេះ ឈ្មោះថា ជាភិក្ខុថ្មីជានិច្ច ។

បទថា **អប្បគព្ភា** គឺ មិនឃ្នើសឃ្នង អធិប្បាយថា វៀរដោយការឃ្នើសឃ្នងកាយមាន ៨ ឋានៈ ដោយការឃ្នើសឃ្នងវាចាមាន ៤ ឋានៈ ដោយការឃ្នើសឃ្នងចិត្តមានឋានៈជាអនេក ការធ្វើដែលមិនសមគួរ ដោយកាយក្នុងសង្ឃ គណៈ បុគ្គល រោងឆាន់ រោងភ្លើង កំពង់ទឹក ផ្លូវភិក្ខាចារ ការចូលទៅក្នុងចន្លោះស្រុក ឈ្មោះថា ឃ្នើសឃ្នងកាយមាន ៨ ឋានៈ ដូច កម្មជាដើមយ៉ាងនេះថា ភិក្ខុរូបខ្លះ ក្នុងធម្មវិន័យនេះ អង្គុយត្របោមក្បាលជង្គង់ក្នុងជំនុំសង្ឃ ឬគ្រលែងកាយក្នុងកណ្តាលគណៈក៏យ៉ាងនោះ ។ បទថា **គណមជ្ឈេ** សេចក្តីថា ក្នុងការប្រជុំបរិស័ទ ៤ ឬប្រជុំសុត្តន្តគណៈជាដើម ក្នុងភិក្ខុដែលចាស់ជាងក៏យ៉ាងនោះ ។ ឯក្នុងរោងឆាន់ មិនឲ្យអាសនៈដល់ភិក្ខុចាស់ ឃាត់អាសនៈដល់ភិក្ខុថ្មី ។ ក្នុងរោងភ្លើងក៏យ៉ាងនោះ ។ ក្នុងរោងភ្លើងនេះ លោកមិនប្រាប់ដល់ភិក្ខុចាស់ ធ្វើការបង្កាត់ភ្លើងជាដើម ។ ឯក្នុងកំពង់ទឹក មានអធិប្បាយថា លោកមិនកំណត់ថា

ភិក្ខុកំលោះ ភិក្ខុចាស់ គប្បីដូចតាមលំដាប់ដែលមក លោកកាលមិនអើពើនូវការកំណត់នោះ មកក្រោយគេ ចុះទឹក រមែងបៀតបៀនភិក្ខុចាស់ និងភិក្ខុថ្មី ៗ ឯក្នុងផ្លូវភិក្ខាចារ មានកម្មជាដើមយ៉ាងនេះថា ដើរមុខដើម្បីប្រយោជន៍ដល់អាសនៈដ៏វិសេស ទឹកដ៏វិសេស ដុំបាយដ៏វិសេស ប៉ះខ្ទប់ដៃ ចូលទៅខាងក្នុងចន្លោះស្រុកមុនពួកភិក្ខុចាស់ ធ្វើនូវការប្រឡែងលេងជាមួយភិក្ខុកំលោះ ដូច្នេះ ។

ការបន្ទឹវាចា ដែលមិនសមគួរក្នុងកណ្ដាលសង្ឃ គណៈ បុគ្គល និងចន្លោះស្រុក ឈ្មោះថា ឃ្នើសឃ្នងវាចាមាន ៤ ឋានៈ ដូចភិក្ខុរូបខ្លះក្នុងធម្មវិន័យនេះ មិនប្រាប់មុន ពោលធម៌ក្នុងកណ្ដាលសង្ឃ ក្នុងកណ្ដាលគណៈ និងក្នុងសម្នាក់បុគ្គល មានប្រការតាមដែលពោលហើយ ក្នុងកាលមុនយ៉ាងនោះ ។ ត្រូវពួកមនុស្សសួរយ៉ាងនោះដូចគ្នា មិនប្រាប់ភិក្ខុដែលជាថេរៈហើយ ឆ្លើយនូវបញ្ហា ។ ឯក្នុងចន្លោះស្រុក រមែងពោលពាក្យជាដើមថា ធ្វើម្ដេចហ្ន៎ បបរ ឬរបស់គួរទំពាគួរបរិភោគនៅមានឬ អ្នកនឹងឲ្យអ្វីដល់អាត្មា ។ ថ្ងៃនេះ អាត្មាទំពាអ្វី នឹងបរិភោគអ្វី នឹងផឹកអ្វី ។ ការមិនដល់អជ្ឈាចារដោយ កាយវាចា ក្នុងឋានៈនោះៗ តែចិត្តត្រិះរិះដល់កាមវិតក្កជាដើម ឈ្មោះថា ឃ្នើសឃ្នងចិត្តដែលមានឋានៈ មិនមែនតិច ។ មយ៉ាងទៀត ភិក្ខុទ្រុស្តសីល មានការប្រាថ្នាលាមក ដែលប្រព្រឹត្តទៅយ៉ាងនេះថា សូមមហាជនដឹងនូវអាត្មាអញថា ជាអ្នកមានសីល ដូច្នេះ ឈ្មោះថាឃ្នើសឃ្នងចិត្ត ។ ព្រះមានព្រះភាគត្រាស់ថា ពួកអ្នកជាអ្នកឃ្នើសឃ្នងចូលទៅរកព្រោះមិនមានការឃ្នើសឃ្នងទាំងអស់នេះ ដោយប្រការដូច្នេះ ។ បទថា **ជរុទបានំ** បានដល់ អណ្ដូងទឹកចាស់ ។ បទថា **បព្ភតាវិសមំ** បានដល់ ជារណ្ដៅ គឺ ជាជ្រោះ

លើក្អំ ។ បទថា **ឆឌ្ឍិឧទ្គត្តំ** បានដល់ ទឹកដែលដាច់ជាអន្លង់ៗ ។ បទថា **អបក្ការស្ស្បាវ កាយំ** បានដល់ បុគ្គលណាខ្វល់ខ្វាយក្នុងការលេងជាដើម មិនដកកាយ មិនរួមគ្នាធ្វើកម្មធ្ងន់ អស់ស្ពានដូច្នោះ មិនកាន់យកអ្នកជួយ មិនដកចិត្ត មិនពិចារណាដល់ដោយលំដាប់ ដោយឃើញទោសថា បុគ្គលដែលធ្លាក់ទៅក្នុងទីនេះ រមែងដល់នូវការបាក់ដៃជើងជាដើម ទើបមានការស្រឡាញ់ សម្លឹងមើល ។ បុគ្គលនោះធ្លាក់ទៅហើយ រមែងជួបនូវវត្ថុមិនជាប្រយោជន៍ មានបាក់ជើងជាដើម ឯបុគ្គលណាត្រូវការទឹក ជាអ្នកប្រាថ្នានឹងពិនិត្យមើល ដោយកិច្ចដទៃ ឬកិច្ចឯណាមួយ ដកកាយ រួមគ្នាធ្វើកម្មធ្ងន់ កាន់យកអ្នកជួយស្រោចស្រង់ ដកនូវចិត្ត សម្លឹងមើល កើតនូវសង្វេគ ព្រោះឃើញទោស ។ បុគ្គលនោះសម្លឹងមើលតាមគាប់ចិត្ត ហើយមានសេចក្ដីសុខ រមែងចៀសទៅតាមសេចក្ដីប្រាថ្នា ។

បទថា **ឯវមេវ ខោ** នេះ ជាគ្រឿងប្រៀបធៀបឧបមា ។ ព្រោះថា ៤ ត្រកូល ដូចអណ្តូងចាស់ជាដើម ។ ភិក្ខុដូចបុរសអ្នកសម្លឹងមើល ។ បុរសមានកាយ និងចិត្តដកមិនបាន កាលសម្លឹងមើលអណ្តូងទឹកចាស់ជាដើមនោះ រមែងធ្លាក់ទៅក្នុងអណ្តូងនោះ យ៉ាងណា ភិក្ខុមានកាយជាដើម មិនរក្សាហើយ កាលចូលទៅកាន់ត្រកូល រមែងជាប់នៅក្នុងត្រកូល បន្ទាប់អំពីនោះ រមែងជួបនូវវត្ថុដែលមិនមែនជាប្រយោជន៍ មានការទម្លាយសីលជាដើម មានប្រការផ្សេងៗ ជាដើមដូច្នោះ ។ ដូចបុរសមានកាយ និងចិត្តដកបានហើយ រមែងមិនធ្លាក់ទៅក្នុងអណ្តូងនោះ យ៉ាងណា ភិក្ខុជាអ្នកមានកាយ និងចិត្តដកបាន ដោយកាយដែលខ្លួនរក្សាហើយ ដោយចិត្តដែលខ្លួនរក្សាហើយ ដោយវាចាដែលខ្លួនរក្សាហើយ ដោយសតិ

*ដ៏មាំទាំ កាលចូលទៅកាន់ត្រកូល រមែងមិនជាប់ក្នុងត្រកូល ។ គ្រានោះ សីល របស់លោកមិនទម្លាយ ដូចជើងរបស់បុរសដែលមិនធ្លាក់ទៅក្នុងអណ្តូងនោះ មិន បាក់ដូច្នោះ ។ ដៃដែលប្រកបដោយសទ្ធា រមែងមិនទម្លាយ ដូចដៃមិនបាក់ដូច្នោះ។ ពោះគឺ សមាធិរមែងមិនបែក ដូចពោះមិនបែក ដូច្នោះ ។ ក្បាល គឺ ញាណ រមែងមិនបែក ដូចក្បាលមិនបែក ដូច្នោះ ។ ម្យ៉ាងទៀត ជង្គត់ និងបន្លាជាដើម រមែងមិនជន់បុរសនោះ យ៉ាងណា បន្លា គឺកិលេសជាដើម រមែងមិនមុតភិក្ខុនោះ ក៏ដូច្នោះ ។ បុរសនោះ មិនមានឧបទ្រវ សម្លឹងមើលបានតាមពេញចិត្ត មានសេចក្តី សុខ ចៀសចេញទៅបានតាមសេចក្តីត្រូវការ យ៉ាងណា ភិក្ខុអាស្រ័យត្រកូល ហើយ សេពនូវបច្ច័យ មានចីវរជាដើម ចម្រើនកម្មដ្ឋាន ពិចារណាក្នុងសង្ខារ ទាំងឡាយ សម្រេចអរហត្ត ជាសុខដោយលោកុត្តរសុខ រមែងទៅកាន់ទិស គឺ និព្វានដែលមិនធ្លាប់ទៅ បានតាមប្រាថ្នា ក៏ដូច្នោះ ។*

*ឥឡូវនេះ ភិក្ខុណាបង្អោនចិត្តទៅក្នុងផ្លូវអាក្រក់ បដិបត្តិខុស គប្បីពោល យ៉ាងនេះថា ព្រះសម្មាសម្ពុទ្ធត្រាស់ថា ពួកអ្នកចូរលះបង់ការឃ្មើសឃ្មង ៣ យ៉ាង ដូចជាព្រះចន្ទ ចូលទៅកាន់ត្រកូល ដោយភាពជាអ្នកថ្មីជានិច្ច តាំងនៅក្នុងអហិរិកៈ ឲ្យលើកការៈដែលអត់ធន់មិនបាន ឲ្យធ្វើវត្ថុដែលបុគ្គលណាម្នាក់ មិនអាចធ្វើបាន។ ព្រះមានព្រះភាគ កាលទ្រង់កាត់នូវគន្លងវាទៈនៃភិក្ខុនោះ សម្តែងថា អ្នកណា មួយអាចធ្វើបានយ៉ាងនេះ ភិក្ខុបែបនេះក៏នៅមានដូច្នេះ ទើបត្រាស់ពាក្យជាដើមថា* **កស្សបោ ភិក្ខវេ** *ដូច្នេះ ។*

*[ ១៣៩ ] បទថា* **អាកាសេ បាណឹ ចាលេសិ** *សេចក្តីថា ទ្រង់គ្រវីបាត*

ព្រះហស្តទៅមកទាំងសងខាង ទាំងខាងក្រោម ទាំងខាងលើ ដូចនាំទៅនូវផ្កែក បន្ទោរជាគូៗ ក្នុងវាំងផ្ទៃមេឃខៀវចាស់ ដូច្នោះ ។ តែសេចក្តីនេះ ឈ្មោះថា ជាបទមិនលាយឡំក្នុងព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ។ បទថា **អត្តមនោ** សេចក្តីថា ជាអ្នកមានចិត្តត្រេកអរ មានចិត្តជារបស់ខ្លួន គឺមិនត្រូវទោមនស្ស កាន់យកបាន ។ បទថា **កស្សបស្ស ភិក្ខវេ** នេះ ព្រះមានព្រះភាគកាត់ពាក្យរបស់អ្នកដទៃដោយន័យមុនដូចគ្នា ទើបត្រាស់ដើម្បីសម្តែងថា ភិក្ខុបែបនេះក៏មាន ។

[ ១៤០ ] បទថា **បសន្នាការំ ករេយ្យុំ** សេចក្តីថា ជនអ្នកជ្រះថ្លាគប្បីឲ្យបច្ច័យ មានចីវរជាដើម ។ បទថា **តថត្តាយ បដិបជ្ជេយ្យុំ** សេចក្តីថា ពួកភិក្ខុបំពេញសីលឲ្យពេញក្នុងទីមកហើយ ឲ្យសីលទាំងនោះដល់ព្រម ក្នុងទីនៃសមាធិ វិបស្សនា មគ្គ និងផល មកហើយ ឈ្មោះថា គប្បីបដិបត្តិដើម្បីភាពជាយ៉ាងនោះ ។ បទថា **អនុទយំ** គឺការរក្សា ។ បទថា **អនុកម្បំ** គឺមានចិត្តទន់ភ្លន់ ឯបទទាំង ២ នោះ ជាវេវចនៈនៃសេចក្តីករុណា ។

[ ១៤១ ] បទថា **កស្សបោ ភិក្ខវេ** នេះ ព្រះមានព្រះភាគទ្រង់កាត់ពាក្យរបស់អ្នកដទៃដោយន័យមុនដូចគ្នា ទើបត្រាស់ដើម្បីសម្តែងថា ភិក្ខុដែលមានសភាពយ៉ាងនេះក៏មាន ។ ក្នុងបទថា **កស្សបេន វា** នេះ លោកតែងប្រកបដោយអំណាចឧបមានឹងព្រះចន្ទជាដើម គប្បីជ្រាបអត្ថដោយន័យមុនដូចគ្នា ។

អដ្ឋកថា ចន្ទូបមសូត្រ ចប់

( បិដក-អដ្ឋកថា ២១-១៨៧ )

# និសន្តិសូត្រទី ៧

[ ៩៨ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ គឺបុគ្គលប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន តែមិនប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ ១ បុគ្គលអ្នកប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ តែមិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន ១ បុគ្គលមិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន ទាំងមិនប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ ១ បុគ្គលអ្នកប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនផង ដើម្បីប្រយោជន៍អ្នកដទៃផង ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលអ្នកប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន តែមិនប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ អាចដឹងឆាប់ក្នុងកុសលធម៌ទាំងឡាយ ជាអ្នកចងចាំនូវធម៌ដែលខ្លួនបានស្តាប់មកផង ជាអ្នកត្រិះរិះនូវសេចក្តីនៃធម៌ ដែលខ្លួនចងចាំមកផង ជាអ្នកដឹងនូវអដ្ឋកថា ដឹងនូវបាលី ហើយប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ផង តែជាអ្នកមានពាក្យមិនពីរោះ មិនបញ្ចេញនូវពាក្យដែលពីរោះ មិនប្រកបដោយពាក្យអ្នកក្រុង មិនពន្យល់ មិនបបួល មិនធ្វើឲ្យក្លាហាន មិនធ្វើឲ្យរីករាយដល់សព្រហ្មចារីបុគ្គលទាំងឡាយ ដោយពាក្យដែលប្រាសចាកសេចក្តីវង្វៀស ជាពាក្យឥតទោស ជាពាក្យពន្យល់នូវសេចក្តី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន តែមិនប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលអ្នកប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ តែមិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកមិនអាចដឹងឆាប់ក្នុងកុសលធម៌

ទាំងឡាយផង ជាអ្នកមិនចងចាំនូវធម៌ដែលខ្លួនបានស្តាប់មកផង ជាអ្នកមិនត្រិះរិះសេចក្តីនៃធម៌ដែលខ្លួនចងចាំមកផង ជាអ្នកមិនដឹងនូវអដ្ឋកថា មិនដឹងនូវបាលី ហើយប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ផង តែជាអ្នកមានពាក្យពីរោះ បញ្ចេញនូវពាក្យពីរោះ ប្រកបដោយពាក្យអ្នកក្រុង ជាអ្នកពន្យល់ បបួល ធ្វើឲ្យក្លាហាន ធ្វើឲ្យរីករាយដល់សព្រហ្មចារីបុគ្គលទាំងឡាយ ដោយពាក្យដែលប្រាសចាកសេចក្តីរអៀស ជាពាក្យឥតទោស ជាពាក្យពន្យល់នូវសេចក្តី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ តែមិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលអ្នកមិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន ទាំងមិនប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនអាចដឹងឆាប់ក្នុងកុសលធម៌ផង ជាអ្នកមិនអាចចងចាំនូវធម៌ដែលខ្លួនបានស្តាប់មកផង ជាអ្នកមិនត្រិះរិះនូវសេចក្តីនៃធម៌ដែលខ្លួនចងចាំមកផង ជាអ្នកមិនដឹងនូវអដ្ឋកថា មិនដឹងនូវបាលី ហើយមិនប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ផង ទាំងជាអ្នកមិនមានពាក្យពីរោះ មិនបញ្ចេញនូវពាក្យពីរោះ មិនប្រកបដោយពាក្យរបស់អ្នកក្រុង មិនពន្យល់ មិនបបួល មិនធ្វើឲ្យក្លាហាន មិនធ្វើឲ្យរីករាយ ដល់សព្រហ្មចារីបុគ្គលទាំងឡាយ ដោយពាក្យប្រាសចាកសេចក្តីរអៀស ជាពាក្យឥតទោស ជាពាក្យពន្យល់នូវសេចក្តី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកមិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន ទាំងមិនប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលអ្នកប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនផង ដើម្បីប្រយោជន៍

អ្នកដទៃផង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកអាចដឹងឆាប់ក្នុងកុសលធម៌ផង ជាអ្នកចងចាំនូវធម៌ ដែលខ្លួនបានស្តាប់មកផង ជាអ្នកត្រិះរិះនូវសេចក្តីនៃធម៌ ដែលខ្លួនចងចាំ មកផង ជាអ្នកដឹងនូវអដ្ឋកថា ដឹងនូវបាលី ហើយប្រតិបត្តិនូវធម៌ដ៏សមគួរ ដល់ធម៌ផង ជាអ្នកមានពាក្យពីរោះ បញ្ចេញនូវពាក្យពីរោះ ប្រកបដោយ ពាក្យរបស់អ្នកក្រុង ជាអ្នកពន្យល់ បបួល ធ្វើឲ្យក្លាហាន ធ្វើឲ្យរីករាយ ដល់សព្រហ្មចារីបុគ្គលទាំងឡាយ ដោយពាក្យប្រាសចាកសេចក្តីរវើរវាយ ជាពាក្យឥតទោស ជាពាក្យពន្យល់នូវសេចក្តី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនផង ដើម្បីប្រយោជន៍អ្នកដទៃផង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះ រមែងមាននៅក្នុងលោក ។៙

# អដ្ឋកថា និសន្តិសូត្រ

[ ៩៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិសន្តិសូត្រទី ៧ ដូចតទៅនេះ បទថា **ខិប្បនិសន្តី** សេចក្តីថា បុគ្គលតាំងចិត្តស្តាប់ អាចដឹងបានរហ័ស ។ បទថា **ធតានញ្ច ធម្មានំ** សេចក្តីថា ធម៌ដែលជាបាលីមានបែបផែន ទ្រទ្រង់ ចាំបានស្ទាត់ជំនាញហើយ ។ បទថា **អត្ថុបបរិក្ខី** សេចក្តីថា ជាបុគ្គលពិចារណាអត្ថ ។ បទថា **អត្ថមញ្ញាយ ធម្មមញ្ញាយ** សេចក្តីថា ដឹងនូវអដ្ឋកថា និងបាលី ។ បទថា **ធម្មានុធម្មប្បដិបន្នោ ហោតិ** សេចក្តីថា ជាអ្នកបដិបត្តិបដិបទាដែលជាចំណែកខាងដើម មួយអន្លើដោយសីល ជាធម៌ដែលសមគួរដល់លោកុត្តរធម៌ ៩ ។ បទថា **នោ ច កល្យាណវាចោ ហោតិ** សេចក្តីថា តែជាអ្នកពោលមិនល្អ ។ បទថា **ន កល្យាណវាក្ករណោ** សេចក្តីថា ជាអ្នកមានសំឡេងមិនពីរោះ ។ **នោ** អក្ខរៈ គួរប្រកបជាមួយ បទថា **បោរិយា** ជាដើម សេចក្តីថា មិនជាអ្នកប្រកបដោយវាចា ដែលអាចចង្អុលបង្ហាញឲ្យបុគ្គលយល់អត្ថ ដោយបទ និងព្យញ្ជនៈ ដែលមិនបាននៅក្នុងក ពេញដោយគុណ មិនត្រដិត មិនមានទោស ។ បទទាំងពួង គប្បីជ្រាបអត្ថដោយឧបាយនេះ ។

*អដ្ឋកថា និសន្តិសូត្រទី ៧ ចប់*

*( បិដក-អ ២៨-១៤៥ )*

# អដ្ឋកថា ធាសរាសិសូត្រ

*ព្រឹត្តិការណ៍ ៧ សប្តាហ៍ បន្ទាប់ពីថ្ងៃត្រាស់ដឹង*

*បានឮមកថា ក្នុងថ្ងៃមហាភិនេស្រ្កម៍ ព្រះពោធិសត្វទតឃើញអាការផ្សេងៗរបស់ស្រីស្នំ ក្នុងអាគារដែលចំហរ ក៏សង្វេគ ទើបត្រាស់ហៅឆន្នមាត្យមកប្រាប់ថា ចូរនាំសេះកណ្ឋកៈមកចុះ មានឆន្នមាត្យជាសម្លាញ់ ទ្រង់ឡើងផែលលើខ្នងសេះ ចេញចាកព្រះនគរ ទ្រង់សម្តែងចេតិយដ្ឋាន ដែលឲ្យសេះកណ្ឋកៈត្រឡប់ ទ្រង់លះរាជសម្បត្តិ ទ្រង់ផ្នួសក្បែរមាត់ស្ទឹងអនោមានទី ទ្រង់ចារិកទៅតាមលំដាប់ ត្រាច់ស្វែងរកអាហារក្នុងក្រុងរាជគ្រឹះ ប្រថាប់គង់ ត្រង់ភ្នំបណ្ឌវៈ ត្រូវព្រះបាទពិម្ពិសារត្រាស់សួរដល់នាម និងគោត្រ ក៏សូមឲ្យទ្រង់ទទួលរាជសម្បត្តិ តែក៏ទូលថា កុំឡើយ មហាបពិត្រ អាត្មាភាពមិនត្រូវការរាជសម្បត្តិទេ អាត្មាភាពលះរាជសម្បត្តិ មកប្រកបសេចក្តីព្យាយាម ដើម្បីជាប្រយោជន៍ដល់សត្វលោក ចេញបួស ដោយបំណងត្រាស់ជាព្រះពុទ្ធ កាត់វដ្តៈក្នុងលោក ទ្រង់ទទួលបដិញ្ញារបស់ព្រះបាទពិម្ពិសារដែលសូមថា បើយ៉ាងនោះកាលព្រះអង្គបានត្រាស់ជាព្រះពុទ្ធហើយ សូមយាងមកនគរទូលបង្គំមុន ដូច្នេះហើយ ទ្រង់ចូលទៅរកអាឡារតាបស កាលាមគោត្រ និងឧទ្ទកតាបស រាមបុត្រ កាលមិនជួបសារៈនៃធម្មទេសនារបស់តាបសទាំង ២ នោះ ទើបចៀសចេញទៅបំពេញទុក្ករកិរិយាអស់ ៦ ឆ្នាំ ត្រង់ឧរុវេលា កាលមិនអាចចាក់ធ្លុះអមតធម៌ ធ្វើព្រះកាយឲ្យឆ្អែតដោយការសោយអាហារដែលគ្រោតគ្រាត ៗ គ្រានោះ ធីតារបស់កុដុម្ពិកៈម្នាក់ ឈ្មោះ សុជាតា ក្នុងឧរុវេលគាម បានបន់ត្រង់ដើមនិគ្រោធ*

មួយថា បើខ្ញុំរៀបការជាមួយមនុស្សមានជាតិស្មើគ្នា បានកូនប្រុសមុន នឹងធ្វើពលីកម្ម ។ នាងសម្រេចសេចក្ដីប្រាថ្នានោះហើយ ។

ថ្ងៃវិសាខបុណ្ណមី នាងត្រៀមមធុបាយាសយ៉ាងល្អ ក្នុងវេលារាត្រី ទៀបភ្លឺ ដោយប្រាថ្នានឹងធ្វើពលីកម្មអំពីព្រលឹម ។ កាលកំពុងចម្អិនមធុបាយាសនោះ ពពុះបាយាសប៉ុនផុសឡើងធំៗ វិលទៅស្ដាំ ។ ចំណែកដែលត្រូវសម្ងួស្សឯណាមួយ ក៏មិនខ្ទាតចេញទៅខាងក្រៅ ។ មហាព្រហ្មបាំងឆត្រ ។ ស្ដេចចតុលោកបាលកាន់ដាវរក្សា ។ សក្កទេវរាជប្រមូលឈើផាប់មកដុតភ្លើង ។ ទេវតាក្នុងទ្វីបទាំង ៤ ប្រមូលឱជៈមកដាក់ចូលក្នុងមធុបាយាសនោះ។ ព្រះពោធិសត្វរង់ចាំវេលាកិច្ចាចារ យាងទៅអំពីព្រលឹម ប្រថាប់គង់នាគល់ឈើ ។ អ្នកបម្រើមកដើម្បីសម្អាតគល់ជ្រៃនោះ ប្រាប់នាងសុជាតាថា ទេវតាមកអង្គុយត្រង់គល់ឈើហើយ ។ នាងសុជាតាប្រដាប់គ្រឿងអលង្ការទាំងពួង ហើយដួសមធុបាយាសដាក់ក្នុងថាសមាសមានតម្លៃមួយសែន គ្របដោយថាសមាសមួយទៀត ហើយ លើកទូលដើរទៅ ឃើញព្រះមហាបុរស ក៏ថ្វាយដល់ដៃ ព្រមទាំងថាសនោះឯង ថ្វាយបង្គំហើយពោលថា មនោរថរបស់ខ្ញុំ សម្រេចហើយយ៉ាងណា សូមមនោរថរបស់លោកសម្រេចយ៉ាងនោះហោង ហើយក៏ត្រឡប់វិញ ។

ព្រះពោធិសត្វ យាងទៅកាន់ប្រាំងស្ទឹងនេរញ្ជរា ហើយដាក់ថាសមាសត្រង់ឆ្នេរស្ទឹង ចុះស្រង់ទឹក ស្ដេចឡើងមកហើយ ទ្រង់ពូតមធុបាយាសចំនួន ៤៩ ពំនូតសោយមធុបាយាសហើយ ទ្រង់អធិដ្ឋានថា ប្រសិនបើអាត្មាអញ ត្រាស់ជាព្រះពុទ្ធក្នុងថ្ងៃនេះ ចូរថាសអណ្ដែតច្រាសខ្សែទឹក ដូច្នេះហើយ ទ្រង់បោះថាសទៅ ថាស

ក៏អណ្តែតច្រាសខ្សែទឹក ហើយឈប់បន្តិច ចូលទៅកាន់ភពរបស់កាឡនាគរាជ ក៏ជៀតចូលទៅខាងក្រោមថាសរបស់ព្រះពុទ្ធ ៣ ព្រះអង្គមុន ។ ព្រះមហាសត្វប្រថាប់សម្រាកនៅពេលថ្ងៃ ក្នុងដងព្រៃ លុះដល់វេលាល្ងាច ទ្រង់ទទួលស្បូវ ៨ ក្តាប់ ដែលសោត្ថិយព្រាហ្មណ៍ប្រគេន រួចទ្រង់ចូលទៅកាន់ពោធិមណ្ឌលដ្ឋាន ប្រថាប់ឈរត្រង់ទិសទក្សិណ ។ ប្រទេសនោះបានញាប់ញ័រ ដូចដំណក់ទឹកលើស្លឹកឈូក ។ ព្រះមហាសត្វទ្រង់ត្រិះរិះថា ត្រង់នេះមិនអាចទ្រទ្រង់គុណរបស់អាត្មាអញបានឡើយ ក៏យាងទៅកាន់ទិសខាងលិច ។ ទីនោះក៏កម្រើកដូចគ្នា ។ ទើបយាងទៅកាន់ទិសខាងជើង ។ ទីនោះក៏កម្រើកដូចគ្នា ។ ទើបយាងទៅត្រង់ទិសខាងកើត ក្នុងទីនោះ មិនញាប់ញ័រឡើយ ដូចសសរគោលដែលបោះល្អហើយ ។ ព្រះមហាសត្វ ទ្រង់ត្រិះរិះថា ទីនេះ ជាទីដែលដកនូវបញ្ជរកិលេសរបស់ព្រះពុទ្ធគ្រប់អង្គ ទ្រង់ចាប់ចុងស្បូវទាំងនោះ រលាស់ចុងស្បូវទាំងនោះ ក៏បានដូចជាជាងចិត្រកម្មគូរដោយចុងជក់ ។ ព្រះពោធិសត្វទ្រង់ចូលទៅជិតគល់ពោធិ ទ្រង់អធិដ្ឋានសេចក្តីព្យាយាមមានអង្គ ៤ ថា ទ្រង់មិនទម្លាយនូវភ្នែននេះ ហើយប្រថាប់គង់ពត់ព្រះភ្នែន ។

រំពេចនោះឯង មារនិម្មិតដៃ ១ ពាន់ ឡើងជិះដំរី ឈ្មោះ គិរិមេខលៈ កម្ពស់ ១៥០ យោជន៍ នាំពលមារ ៩ យោជន៍ សម្លឹងមើលពាក់កណ្តាលភ្នែក ចូលទៅជិត ប្រៀបដូចភ្នំ ។ ព្រះមហាសត្វទ្រង់លាព្រះហស្តត្រាស់ថា អាត្មាអញកំពុងបំពេញបារមី ១០ មិនមានសមណព្រាហ្មណ៍ ទេវតា មារ ឬ ព្រហ្មជាសាក្សីឡើយ តែក្នុងអត្តភាពដែលជាព្រះវេស្សន្តរ មហាប្រឹថពីជាសាក្សីរបស់អាត្មាអញ

ក្នុងទី ៧ កន្លែង សូម្បីឥឡូវនេះ មហាប្រឹថពីក៏មិនមានចិត្ត ឧបមាដោយកំណាត់ឈើ ក៏ជាបន្ទាល់សាក្សី ។ រំពេចនោះឯង មហាប្រឹថពីក៏បន្លឺសំឡេង ១ រយដង ១ ពាន់ដង ដូចជួងដែលត្រូវវាយដោយដុំដែក ហើយប្រមូលពលមារទៅគរទុក ត្រង់កណ្តាប់ចក្រវាល ។ កាលព្រះអាទិត្យមិនទាន់លិចនៅឡើយ ទ្រង់ក៏កម្ចាត់ពលមារបាន ទ្រង់ជម្រះបុព្វេនិវាសញ្ញាណក្នុងបឋមយាម ទ្រង់ជម្រះទិព្វចក្ខុញ្ញាណក្នុងមជ្ឈិមយាម ទ្រង់ឈមចុះកាន់ញាណក្នុងបដិច្ចសមុប្បាទ នាបច្ឆិមយាម ទ្រង់ពិចារណាវដ្ដៈ និងវិវដ្ដៈ ក្នុងវេលាអរុណរះ ក៏បានត្រាស់ជាព្រះពុទ្ធ ទ្រង់ព្រះតម្រិះថា អាត្មាអញធ្វើសេចក្ដីព្យាយាមដើម្បីបល្ល័ង្កនេះ មកអស់ច្រើនសែនកោដិកប្ប ដូច្នេះហើយ ប្រថាប់គង់ពត់ព្រះភ្នែនក្នុងឥរិយាបថមួយអស់មួយសប្ដាហ៍ ។

បន្ទាប់មក ទេវតាពួកខ្លះ កើតសន្ទិះសង្ស័យថា នៅមានធម៌ដែលធ្វើភាពជាព្រះពុទ្ធទៀតឬហ្ន៎ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ចេញចាកសមាបត្តិក្នុងថ្ងៃទី ៨ ទ្រង់ជ្រាបសេចក្ដីសង្ស័យរបស់ពួកទេវតា ទើបទ្រង់ហោះទៅលើអាកាស សម្ដែងយមកប្បាដិហារ្យ ដើម្បីកម្ចាត់សេចក្ដីសង្ស័យ កាលទ្រង់កម្ចាត់សេចក្ដីសង្ស័យរបស់ទេវតាទាំងនោះហើយ ប្រថាប់ឈរត្រង់ **ទិសឦសាន** ឆ្ងាយអំពីបល្ល័ង្កបន្តិច ទ្រង់សម្លឹងស្ថានទីសម្រេចផលនៃព្រះបារមី ដែលទ្រង់បំពេញមកអស់ ៤ អសង្ខេយ្យ និង ១ សែនកប្ប ចំពោះបល្ល័ង្ក និងពោធិព្រឹក្សដោយមិនប៉ព្រិចព្រះនេត្រអស់មួយសប្ដាហ៍ ។ ទីនោះឈ្មោះថា **អនិមិសស្សចេតិយ** ។ បន្ទាប់មក ទ្រង់យាងចង្ក្រមក្នុងផ្ទះកែវ ដែលតអំពីទិសខាងកើត និងទិសខាងលិច

ក្នុងចន្ទោះបល្ល័ង្ក និងទីប្រថាប់ឈរ កន្លងទៅ អស់មួយសប្តាហ៍ ។ ទីនោះឈ្មោះថា **រតនចង្កមចេតិយ** ។ បន្ទាប់អំពីនោះ ពួកទេវតាក្នុងចំណែកទិសខាងលិច និម្មិតផ្ទះជាវិការនៃកែវ ។ ទ្រង់ប្រថាប់ គង់ពត់ព្រះភ្លែនក្នុងផ្ទះនោះ ទ្រង់ពិចារណាអភិធម្មបិដក ដោយចំពោះយ៉ាងក្រៃលែង ក្នុងសមន្តប្បដ្ឋានអនន្តន័យ ក្នុងអភិធម្មនោះ អស់មួយសប្តាហ៍ ។ ទីនោះឈ្មោះថា **រតនឃរចេតិយ** ។ ក្នុងទីក្បែរពោធិមណ្ឌលដ្ឋាននោះឯង កន្លងទៅ ៤ សប្តាហ៍ ដោយអាការយ៉ាងនេះ ក្នុងសប្តាហ៍ទី ៥ ទ្រង់ចេញអំពីគល់ពោធិព្រឹក្ស ទៅគាន់អជបាលនិគ្រោធ ។ ទ្រង់ពិចារណាធម៌ក្នុងទីនោះ ប្រថាប់គង់សោយវិមុត្តិសុខ ។ កាលទ្រង់ពិចារណាធម៌ ទ្រង់ក៏ពិចារណាត្រឹមតែន័យព្រះអភិធម្មក្នុងធម៌នោះ គឺ គម្ពីរដំបូង ឈ្មោះធម្មសង្គណិប្បករណៈ បន្ទាប់អំពីនោះ ឈ្មោះវិភង្គប្បករណៈ ធាតុកថាបករណៈ បុគ្គលប្បញ្ញត្តិប្បករណៈ កថាវត្ថុប្បករណៈ យមកប្បករណៈ បន្ទាប់អំពីនោះក៏ពិចារណា មហាបដ្ឋានប្បករណៈ ។

កាលចិត្តរបស់ព្រះអង្គ ឈមចុះក្នុងបដ្ឋានដ៏ល្អិតសុខុម ក្នុងព្រះអភិធម្មនោះ បីតិក៏កើតឡើង ។ កាលបីតិកើតឡើង ព្រះលោហិតក៏ថ្លា កាលព្រះលោហិតថ្លា ព្រះឆវីក៏ផូរផង់ កាលព្រះឆវីផូរផង់ ព្រះរស្មីទំហំប៉ុនផ្ទះកំពូលក៏ផ្សាយឡើងអំពីព្រះវរកាយចំណែកខាងមុខ ភ្លឺទៅរហូតអនន្តចក្រវាល ក្នុងទិសខាងកើត ដូចដីរឆទ្ទន្តស្ទុះទៅក្នុងអាកាស ។ ព្រះរស្មីផុសឡើងអំពីព្រះកាយចំណែកខាងព្រះបិដ្ឋិ ផ្សាយទៅកាន់ទិសខាងលិច ផុសឡើងអំពីព្រះអង្សាស្តាំ ផ្សាយទៅទិសខាងត្បូង ផុតឡើងពីព្រះអង្សាឆ្វេង ផ្សាយទៅរហូតអនន្តចក្រវាល

ទិសខាងជើង ។ ព្រះរស្មីមានពណ៌ដូចពន្លកនៃកែវប្រពាល ក៏ចេញអំពីផ្ទៃព្រះបាត ទម្លុះមហាប្រឹថពី ញែកទឹកជា ២ ចំណែក ទម្លាយទាំងគំនរ ខ្យល់ទៅ រហូតអជដាកាស កម្រងព្រះរស្មីពណ៌ខៀវ ដូចកម្រងកែវមណី វិលធ្មៀលធ្វាត់ ផុសឡើងអំពីព្រះសីសៈ ទម្លុះទេវលោក ៦ ជាន់ រំលងព្រហ្មលោក ៩ ជាន់ ទៅរហូតដល់អជដាកាស ថ្ងៃនោះ ពួកសត្វមិនមានប្រមាណ ក្នុងចក្រវាឡជាអនន្ត ក៏នាំគ្នាមានពណ៌ដូចមាសទាំងអស់ ។ ថ្ងៃនោះ ព្រះរស្មីទាំងនោះដែលផ្សាយចេញអំពីព្រះសរីរៈ ក៏ប្រព្រឹត្តទៅរហូតអនន្តលោកធាតុ រហូតដល់សព្វថ្ងៃនេះ ។

ព្រះមានព្រះភាគ ប្រថាប់គង់ក្នុងអជបាលនិគ្រោធ អស់មួយសប្តាហ៍ ដោយប្រការយ៉ាងនេះហើយ បន្ទាប់អំពីនោះ ក៏ប្រថាប់គង់ក្នុងមុច្ចលិន្ទអស់មួយសប្តាហ៍ទៀត ។ គ្រាន់តែព្រះមានព្រះភាគប្រថាប់គង់ប៉ុណ្ណោះ មហាមេឃពុំជួកាលក៏ធ្លាក់ចុះមក ធ្វើឲ្យឱកាសសកលចក្រវាលជោកជាំទូទៅ ។ បានឮថា មហាមេឃដូច្នោះធ្លាក់ក្នុងកាលទាំង ២ ប៉ុណ្ណោះ គឺក្នុងកាលនៃស្តេចចក្រពត្តិ ឬព្រះពុទ្ធកើតឡើង មហាមេឃនោះកើតក្នុងពុទ្ធកាលនេះ ។ កាលមហាមេឃនោះកើតឡើងហើយ ស្តេចនាគឈ្មោះមុច្ចលិន្ទ ក៏ត្រិះរិះថា ភ្លៀងនេះកើតឡើង កាលព្រះសាស្តាយាងចូលមកកាន់ទីកន្លែងរបស់អញ ព្រះអង្គគួរតែបានអាគារសម្រាប់បាំងភ្លៀង ។ ស្តេចនាគនោះ ត្រិះរិះថា អញអាចនិម្មិតប្រាសាទជារតនៈ ៧ ប្រការ តែធ្វើយ៉ាងនោះ ក៏មិនមានផលច្រើន ណ្ហើយចុះ អញនឹងធ្វើសេចក្តីខ្វល់ខ្វាយ ដោយការថ្វាយដល់ព្រះទសពល ហើយទើបពង្រីកអត្តភាពឲ្យធំ យករង្វេលព័ទ្ធជុំវិញ ព្រះសាស្តា ៧ ជាន់ យកពពារបាំងខាងលើ ។ ឱកាសខាងក្នុងរង្វេល មានទំហំប៉ុន

លោហប្រាសាទ ។ ស្តេចនាគមានអធ្យាស្រ័យបង្អោនទៅថា ព្រះសាស្តានឹងប្រថាប់នៅតាមឥរិយាបថដែលទ្រង់ត្រូវការ ។ ព្រោះដូច្នោះ ទើបព័ទ្ធឱកាសដ៏ធំយ៉ាងនេះ រៀបចំបល្ល័ង្កត្រង់កណ្តាល មានពិតានសំពត់ មានកម្រងគ្រឿងក្រអូប កម្រងផ្កា រីកស្គុសស្គាយ វិចិត្រដោយផ្កាយមាសនៅខាងលើ ។ រៀបប្រទីបប្រេងក្រអូប មានពន្លឺទាំង ៤ ទិស តាំងជន្ទាប់ខ្លឹមចន្ទន៍ក្នុងទិសទាំង ៤ ។ ព្រះមានព្រះភាគ ទ្រង់ប្រថាប់ក្នុងមុច្ចលិន្ទនោះអស់មួយសប្តាហ៍ ដោយអាការយ៉ាងនោះ បន្ទាប់អំពីនោះ ប្រថាប់គង់ក្នុងរាជាយតនព្រឹក្ស គឺដើមកែសអស់មួយសប្តាហ៍ទៀត ។ ក្នុងសប្តាហ៍ទី ៨ បន្ទាប់ពីរាជាយតនព្រឹក្ស ទ្រង់ទំពាឈើស្ទន់ និងឱសថសម៉ ដែលទេវរាជនាំមកថ្វាយ ទ្រង់ខ្ពុរព្រះឱស្ឋហើយ កាលស្តេចចតុលោកបាលបង្អោនបាត្រថ្ម មានតម្លៃពិសេសថ្វាយ ក៏សោយបិណ្ឌបាតរបស់តបុស្ស: និងភល្លិក: ជាពាណិជបងប្អូន ទ្រង់ត្រឡប់មកប្រថាប់គង់ក្នុងអជបាល-និគ្រោធទៀត ទ្រង់កើតបរិវិតក្កនេះ ដែលព្រះពុទ្ធគ្រប់អង្គ ទ្រង់ក៏ធ្លាប់បរិវិតក្កមកហើយ ។

( បិដក-អ ១៤-៦៤៤ )

# បាសាទិកសូត្រ

( បុគ្គលកាលឃើញ ឈ្មោះថា មិនឃើញ តើដូចម្ដេច )

ម្នាលចុន្ទ ពួថា ឧទ្ទករាមបុត្រ និយាយសម្ដីយ៉ាងនេះថា បុគ្គលកាលឃើញ ក៏ឈ្មោះថា មិនឃើញ ។ ឃើញនូវអ្វី ឈ្មោះថា មិនឃើញ ។ បុគ្គលឃើញបានតែត្រឹមផ្ទៃនៃកាំបិតកោរដែលមុតល្អ តែមិនឃើញមុខកាំបិតកោរទេ ។ ម្នាលចុន្ទ នេះឯងដែលឧទ្ទករាមបុត្រនិយាយថា បុគ្គលកាលឃើញ ក៏ឈ្មោះថា មិនឃើញ ។ ម្នាលចុន្ទ ឯពាក្យដែលឧទ្ទករាមបុត្រពោលនោះ ជាពាក្យថោកទាប ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនរបស់ព្រះអរិយៈ មិនប្រកបដោយប្រយោជន៍ ព្រោះសំដៅកាំបិតកោរ តែម្យ៉ាង ។

ម្នាលចុន្ទ កាលបើបុគ្គលនិយាយពាក្យណាឲ្យត្រូវនោះ គួរនិយាយថា បុគ្គលកាលឃើញ ក៏ឈ្មោះថា មិនឃើញ ។ បុគ្គលកាលនិយាយឲ្យត្រូវ គួរនិយាយពាក្យនេះឯងថា បុគ្គលកាលឃើញ ក៏ឈ្មោះថា មិនឃើញ ។ បុគ្គលឃើញនូវអ្វីខ្លះ ឈ្មោះថា មិនឃើញ ។ ពាក្យថា ព្រហ្មចារ្យដល់ព្រមហើយដោយហេតុគ្រប់យ៉ាង បរិបូណ៌ហើយ ដោយអាការគ្រប់យ៉ាង មិនខ្វះ មិនលើសដែលតថាគតសម្ដែងទុកល្អហើយ បរិបូណ៌ទាំងអស់ បានប្រកាសទុកល្អហើយយ៉ាងនេះ បុគ្គលមិនឃើញសេចក្ដីនុ៎ះ ដូច្នេះសោះ សមជាដកពាក្យនេះចេញក្នុងរឿងនោះ ។ បុគ្គលនោះ ថែមទាំងមិនឃើញ សេចក្ដីនុ៎ះដូច្នេះថា ព្រហ្មចារ្យនុ៎ះបរិសុទ្ធក្រៃលែងយ៉ាងនេះ សមជាបញ្ចូលពាក្យនេះ ក្នុងរឿងនុ៎ះ ។ បុគ្គលនោះឈ្មោះថា **មិនឃើញសេចក្ដីនៃពាក្យថា ព្រហ្មចារ្យនោះ បរិសុទ្ធក្រៃលែង** ដូច្នេះ

យ៉ាងនេះ ។ នេះហៅថា បុគ្គលកាលឃើញ ឈ្មោះថា មិនឃើញ ។

ម្នាលចុន្ទ បុគ្គលកាលនិយាយពាក្យណាឲ្យត្រូវនោះ គួរនិយាយថា ព្រហ្មចារ្យដល់ព្រមហើយ ដោយហេតុគ្រប់យ៉ាង បរិបូណ៌ហើយ ដោយអាការគ្រប់យ៉ាង មិនខ្វះ មិនលើស ដែលតថាគតសម្តែងទុកល្អហើយ បរិបូណ៌ទាំងអស់ បានប្រកាសទុកល្អហើយ ។ បុគ្គលកាលនិយាយឲ្យត្រូវ គួរនិយាយពាក្យនេះឯងថា ព្រហ្មចារ្យដល់ព្រមហើយ ដោយហេតុគ្រប់យ៉ាង បរិបូណ៌ហើយដោយអាការគ្រប់យ៉ាង មិនខ្វះ មិនលើស ដែលតថាគតសម្តែងទុកល្អហើយ បរិបូណ៌ទាំងអស់ ប្រកាសទុកល្អហើយ ដូច្នេះ ។

( បិដក-អ ១២-២៣០ )

# សន្ទកសូត្រ

## ព្រះអានន្ទសម្តែង

[ ៦៧ ] ម្នាលសន្ទកៈ ប្រការមួយទៀត ក្នុងលោកនេះ មានគ្រូខ្លះ ជាអ្នកមានសេចក្តីត្រិះរិះ ពិចារណាជាប្រក្រតី ។ គ្រូនោះ តែងសម្តែងធម៌ដែលខ្លួនស្រាវជ្រាវបានមកដោយសេចក្តីត្រិះរិះ ដែលខ្លួនស្ទាបស្ទង់ដោយការពិចារណា ជាធម៌កើតមានដោយប្រាជ្ញារបស់ខ្លួន ។ ម្នាលសន្ទកៈ ក៏គ្រូអ្នកមានសេចក្តីត្រិះរិះ ពិចារណាជាប្រក្រតី រមែងត្រិះរិះហេតុល្អក៏មាន ត្រិះរិះហេតុអាក្រក់ក៏មាន ពិតក៏មាន មិនពិតក៏មាន ។ ម្នាលសន្ទកៈ វិញ្ញូបុរស រមែងពិចារណាក្នុងដំណើរនោះដូច្នេះថា គ្រូដ៏ចម្រើននេះ ជាអ្នកមានសេចក្តីត្រិះរិះ ពិចារណាជាប្រក្រតី ។ គ្រូនោះ តែងសម្តែងធម៌ដែលខ្លួនស្រាវជ្រាវបានមកដោយសេចក្តីត្រិះរិះ ដែលខ្លួនស្ទាបស្ទង់ដោយការពិចារណា ជាធម៌កើតមានដោយប្រាជ្ញារបស់ខ្លួន ។ ក៏គ្រូជាអ្នកមានសេចក្តីត្រិះរិះ ពិចារណាជាប្រក្រតី រមែងត្រិះរិះហេតុល្អក៏មាន ត្រិះរិះហេតុអាក្រក់ក៏មាន ពិតក៏មាន មិនពិតក៏មាន ។ បុរសនោះ លុះដឹងច្បាស់ថា ព្រហ្មចរិយៈនេះមិនមានទំនងស្រួល ដូច្នេះហើយ ក៏នឿយណាយចាកព្រហ្មចរិយៈនោះ ហើយចៀសចេញទៅ ។ ម្នាលសន្ទកៈ នេះឯងឈ្មោះថា អនស្សាសិក-ព្រហ្មចរិយៈទី ៣ ដែលព្រះភគវន្ត អរហន្តសម្មាសម្ពុទ្ធអង្គនោះទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសម្តែងហើយ ដែលជាធម៌នាំឲ្យវិញ្ញូបុរស លែងប្រព្រឹត្តព្រហ្មចរិយៈដោយដាច់ស្រឡះ ទុកជាកាលប្រព្រឹត្តក៏មិនបានត្រេកអរនឹងកុសលធម៌ដែលខ្លួនគប្បីដឹងឡើយ ។

( បិដក-អដ្ឋកថា ១៦-៣៧៤ )

# សន្ទឹកចង្អុលប្រាប់មាតិកា

មាតិកា លេខទំព័រ

១-សុគតសូត្រ និងអដ្ឋកថា...................................................... ២

អំពី ព្រះសុគត និងវិន័យព្រះសុគត

២-សីសចាសូត្រ និងអដ្ឋកថា...................................................... ៨

អំពី ពាក្យព្រះតថាគត

៣-សទ្ធម្មប្បដិរូបកសូត្រ និងអដ្ឋកថា....................................... ១០

អំពី ធម៌ស្រដៀងនឹងព្រះសទ្ធម្ម

៤-អាណិសូត្រ និងអដ្ឋកថា...................................................... ១៩

អំពី ការវិនាសព្រះសូត្រ

៥-តតិយអនាគតសូត្រ និងអដ្ឋកថា........................................ ២៥

អំពី ការវិនាសព្រះសូត្រ

៦-ទុតិយសរកានិសូត្រ និងអដ្ឋកថា.......................................... ៣១

អំពី ធម៌ដូចស្រែក្រហែងក្រហូង

៧-បរិស័ទ ២ ពួក.................................................................. ៣៨

អំពី បរិស័ទសិក្សាខុសទំនង

៨-មហាប្រទេស ៤ និងអដ្ឋកថា ............................................ ៤២

អំពី ការផ្ទៀងផ្ទាត់ធម៌-វិន័យ

៩-សីហសូត្រ និងអដ្ឋកថា ........................................................ ៥២

*អំពី ការសម្ដែងធម៌របស់ព្រះតថាគត*

១០-សូត្រទី ១០ និងអដ្ឋកថា ...................................................... ៥៥

*អំពី ទោសនៃការហាមឃាត់អដ្ឋកថា និងបាលី*

១១-សូត្រទី ១០ និងអដ្ឋកថា ...................................................... ៥៧

*ធម៌ ២ យ៉ាង ដើម្បីការសាបសូន្យនៃព្រះសទ្ធម្ម*

១២-សូត្រទី ៤ និងអដ្ឋកថា ........................................................ ៥៩

*អំពី ការពោលបង្កាច់ព្រះតថាគត*

១៣-ពហុការសូត្រ និងអដ្ឋកថា .................................................. ៦២

*អំពី អាចារ្យ ៣ ពួក មានឧបការៈច្រើន*

១៤-នាវាសូត្រ និងអដ្ឋកថា ...................................................... ៦៨

*អំពី ការបូជាគ្រូអាចារ្យ*

១៥-បុគ្គលជាអាចារ្យ ............................................................... ៧០

*អំពី ការបបួលអន្តេវាសិករបស់គ្រូអាចារ្យ*

១៦-សីលសម្បន្នសូត្រ និងអដ្ឋកថា ........................................... ៧២

*អំពី បុគ្គលជាគ្រូ ជាសាស្ដា*

១៧-ធម្មកថិកសូត្រ និងអដ្ឋកថា ............................................... ៨២

*អំពី ធម្មកថិក ៤ ពួក*

១៨-ចន្ទូបមសូត្រទី ៣ ........................................................ ៨៤

អំពី ធម្មទេសនាបរិសុទ្ធ និងមិនបរិសុទ

១៩-និសន្តិសូត្រទី ៧ ........................................................ ៩៥

អំពី ពាក្យពន្យល់សេចក្តីជាពាក្យឥតទោស

២០-អដ្ឋកថា ចាសរាសិសូត្រ ........................................ ៩៩

ព្រឹត្តិការណ៍ ៧ សប្តាហ៍ បន្ទាប់ពីថ្ងៃត្រាស់ដឹង

២១-ចាសាធិកសូត្រ ........................................................ ១០៦

អំពី ព្រហ្មចារ្យបរិសុទ្ធក្រៃលែង បរិបូណ៌ដោយហេតុគ្រប់យ៉ាង

២២-សន្ទកសូត្រ ........................................................ ១០៨

អំពី វិញ្ញូបុរសលែងប្រព្រឹត្តព្រហ្មចរិយធម៌ដែលគ្រូសម្តែងធម៌តាម
សេចក្តីត្រិះរិះរបស់ខ្លួន ដោយប្រាជ្ញារបស់ខ្លួន ។

សមាគមគ្រួសារសតិប្បដ្ឋាន

SATIPATTHANA FAMILY ASSOCIATION